ឆ្នាំទី៦ លេខ ៦៦ ខែមិថុនា ឆ្នាំ២០១៨

ព្រឹត្តិបត្រ

# កៅស៊ូធម្មជាតិ

# Natural Rubber Bulletin

ផ្សាយចេញពី អគ្គនាយកដ្ឋានកៅស៊ូ








ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០

## នាយកបណ្ណាធិការ

- ឯកឧត្តម **ប៉ុល សុផា**

## គណៈកម្មាធិការបណ្ណាធិការ

- លោក **ឃុន កក្កដា** ប្រធាន
- លោក **ហ៊ន សាផន** អនុប្រធាន
- លោក **គុយ ភក្ដី** អនុប្រធាន
- កញ្ញា **ថូ ស្រីស** សមាជិកអចិន្ត្រៃយ៍
- លោក **លួង សុខខេង** សមាជិក
- លោក **គួរ ផល្លី** សមាជិក
- លោក **គង់ ថា** សមាជិក
- លោក **ព្រៃ សុភាព** សមាជិក
- លោក **និល សុធន** សមាជិក
- លោកស្រី **ស្វាយ ណាបុល** សមាជិក
- លោក **សូ សុវណ្ណា** សមាជិក
- លោកស្រី **ទូច ពុទ្ធី** សមាជិក
- លោក **តូ ប៊ុនធី** សមាជិក

## ការីកុំព្យូទ័រ

- លោក **ជុំ មៅ**
- លោក **ឈួង ឈី**

## ការីទំនាក់ទំនងនិងបោះពុម្ព

- លោក **គុយ ភក្ដី**
- E-mail phokpheakdey@yahoo.com
- Tel: ០១៦ ២៩៣ ៤២៣

## Editor-in-chief

- H.E. Pol Shopha

## Editorial Board

- Mr. Khun Kakada Director
- Mr. Horn Saphan Vice Director
- Mr. Kuy Pheakdey Vice Director
- Ms. Tho Srey Sor Permanent Member
- Mr. Loung Sokheng Member
- Mr. Kou Phally Member
- Mr. Kong Tha Member
- Mr. Prey Sopheap Member
- Mr. Nil Sokthon Member
- Mrs. Svay Nabol Member
- Mr. So Sovanna Member
- Mrs. Touch Puthy Member
- Mr. Tou Bunthy Member

## Computer Operator

- Mr. Chum Mouv
- Mr. Choung Chhy

## Contact & Publication

- Mr. Kuy Pheakdey
- E-mail: phokpheakdey@yahoo.com
- Tel: 016 293 423



សូមថ្វាយព្រះពរបវរមហាប្រសើរ
សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
ក្នុងព្រះរាជវរោកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម
គម្រប់ព្រះជន្មាយុ ៨២ យាងចូល ៨៣ ព្រះវស្សា
សូមព្រះអង្គប្រកបដោយព្រះបរមសុខគ្រប់ប្រការ និង
ព្រះជន្មាយុយឺនយូរ

ក្រាបបង្គំទូលថ្វាយពីថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់
នៃអគ្គនាយកដ្ឋានកៅស៊ូ

## មាតិកា


ទំព័រ

❖ បទវិចារណកថា ១

### ព័ត៌មានក្នុងប្រទេស

❖ វគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត នៅខេត្តកំពង់ចាម ៣

❖ ការចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ ស្រុកស្នួល ខេត្តក្រចេះ ៥

❖ ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានកៅស៊ូ ចូលរួមសិក្ខាសាលាស្តីពី "ឆ្ពោះទៅរកប្រសិទ្ធិភាពខ្សែច្រវ៉ាក់នៃការផ្គត់ផ្គង់" នៅទីក្រុងហាត់យ៉ៃ ប្រទេសថៃ ៦

❖ សិក្ខាសាលាស្តីអំពីផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការជំរុញការអនុវត្តកសិកម្មល្អ ២៤

❖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែមិថុនា ឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្ត ៣១

### ព័ត៌មានអន្តរជាតិ

❖ ពិព័រណ៍កៅស៊ូឥណ្ឌានឹងប្រារព្ធនៅខែមករាពេលខាងមុខនេះ ៣៦

❖ វៀតណាមនៅតែរក្សាជំហរជាអ្នកនាំចេញកៅស៊ូលំដាប់ទី៣ ៣៦

### ទំព័រស្រាវជ្រាវ

❖ ការដាំដុះនិងថែទាំកូនកៅស៊ូមិនទាន់ផ្តល់ផល ៣៨

### តម្លៃនិងស្ថិតិកៅស៊ូធម្មជាតិតាមបណ្តាប្រទេសនានា

❖ តារាងទី១៖ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅតាមបណ្តាស្រុកប្រចាំសប្តាហ៍ ខែមិថុនា ឆ្នាំ២០១៨ ៤៣

❖ តារាងទី២៖ ស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែមិថុនា ឆ្នាំ២០១៨ ៤៤

❖ តារាងទី៣៖ តម្លៃកៅស៊ូនៅទីផ្សារប្រទេសថៃ ប្រចាំខែមិថុនា ឆ្នាំ២០១៨ ៤៥

❖ តារាងទី៤៖ តម្លៃកៅស៊ូស្តង់ដាម៉ាឡេស៊ី SMR/FOB ប្រចាំខែមិថុនា ឆ្នាំ២០១៨ ៤៦

❖ តារាងទី៥៖ តម្លៃកៅស៊ូស្តង់ដាវៀតណាម SVR/FOB ប្រចាំខែមិថុនា ឆ្នាំ២០១៨ ៤៧

❖ តារាងទី៦៖ តម្លៃកៅស៊ូធម្មជាតិចេញដោយ Association of Natural Rubber Producing Countries ប្រចាំខែមិថុនា ឆ្នាំ២០១៨ ៤៨

❖ តារាងទី៧៖ តម្លៃកៅស៊ូសន្លឹកលេខ៣ (RSS3) នៅលើទីផ្សារហ៊ុន TOCOM ៤៩

❖ តារាងទី៨៖ តម្លៃកៅស៊ូសន្លឹកលេខ៣ (RSS3) នៅលើទីផ្សារហ៊ុនសៀងហៃ ៥០

❖ តារាងទី៩៖ តម្លៃទិញលក់ភ្លាមៗប្រចាំថ្ងៃគិតជាមធ្យមក្នុងខែ ៥១

### ក្រាហ្វិក

❖ ក្រាហ្វិកទី១ ៖ ឥទ្ធិពលនៃតម្លៃទិញលក់កៅស៊ូតាមកិច្ចសន្យានៅទីផ្សារហ៊ុនសៀងហៃទៅលើតម្លៃទិញលក់កៅស៊ូ SMR-20 ភ្លាមៗ ៥២

❖ ក្រាហ្វិកទី២ ៖ ឥទ្ធិពលនៃតម្លៃប្រេងឆៅទៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារសៀងហៃ ៥៣

❖ ក្រាហ្វិកទី៣ ៖ ឥទ្ធិពលនៃតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូទៅលើតម្លៃកៅស៊ូ SMR-20 នៅលើទីផ្សារទិញលក់ភ្លាមៗ ៥៣

❖ ក្រាហ្វិកទី៤៖ ឥទ្ធិពលប្រាក់យ៉េនទៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូ ៥៤

# បទវិចារណកថា

*ប្រិយមិត្តទាំងអស់ជាទីមេត្រី!*

ស្ថានភាពផលិតកម្មនិងធុរកិច្ចកៅស៊ូធម្មជាតិកម្ពុជា ប្រចាំខែមិថុនា ឆ្នាំ២០១៨ បានបង្ហាញថា៖ បរិមាណផលិតផលសរុបក្នុងខែមិថុនាមានចំនួន ១៨ ២៥៩តោន បានកើនឡើងចំនួន ១ ៩៧៩តោន (=+១២%) ធៀបនឹងខែមុន និងកើនឡើងចំនួន ២ ៨១២តោន (=+១៨%) បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។ គិតរហូតមកដល់ខែមិថុនា (ឆមាសទី១ឆ្នាំ២០១៨) បរិមាណផលិតសរុបមានចំនួន ៨៣ ៧១៨តោន បានកើនឡើងចំនួន ១០ ៨៤៧តោន (=+១៥%) បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

បរិមាណបញ្ចេញលក់ក្នុងខែមិថុនា មានចំនួន១៦ ១៥៣តោន បានកើនឡើងចំនួន៣ ៧៧៧តោន (=+៣១%) ធៀបនឹងខែមុន និងបានកើនឡើងចំនួន ៣ ២៥០តោន (=+២៥%) ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ បរិមាណបញ្ចេញលក់សរុបរហូតដល់ខែមិថុនា មានចំនួន ៨៤ ៤១៩តោនបានកើនឡើងចំនួន ១៤ ៣៧៦តោន (=+២១%) ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

តម្លៃលក់ជាមធ្យមក្នុងខែមិថុនាគឺ ១ ៤១៣US$/តោន បានកើនឡើង ២០US$/តោន (=+១,៤១%) ធៀបនឹងខែមុន ប៉ុន្តែបានធ្លាក់ចុះ ២៣US$/តោន (=-១,៦%) បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៧។ រហូតមកដល់ខែមិថុនា ឆ្នាំ២០១៨ តម្លៃលក់ជាមធ្យមគឺ ១ ៤៣៤US$/តោនបានថយចុះ ៣៣៦US$/តោន (=-១៩%) បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ចំពោះស្ថានភាពទិញជ័រកៅស៊ូគ្រួសារតាមតំបន់នានាប្រចាំខែមិថុនាជាមធ្យមមានតម្លៃ ៤ ៤២៥៛/គ.ក្រ (=១,០៩US$/គ.ក្រ) សម្រាប់ ជ័រស្ងួត និង ២ ១៥៨៛/គ.ក្រ (=0,៥៣US$/គ.ក្រ) សម្រាប់ជ័រកក។ ជាការសង្កេតតាមដានប្រចាំខែ តម្លៃទិញជ័រកៅស៊ូគ្រួសារនៅតាមតំបន់នានាទ្រឹងមិនប្រែប្រួលក្នុងរង្វង់ពី ៤ ៥០០៛ - ៤ ៦០០៛/គ.ក្រ សម្រាប់ជ័រស្ងួត និង២ ២០០៛ - ២ ៣០០៛/គ.ក្រ (=0,៥៣US$/គ.ក្រ) សម្រាប់ជ័របើធៀបនឹងសប្តាហ៍ទី១ នៃខែឧសភា ប៉ុន្តែបានធ្លាក់ចុះជាមធ្យមពី ១០០៛ - ២០០៛/គ.ក្រ ចាប់ពីសប្តាហ៍ទី២ រហូតដល់ដំណាច់ខែមិថុនា។

យោងរបាយការណ៍ប្រចាំខែមិថុនា ឆ្នាំ២០១៨ របស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) បានបង្ហាញថា៖ ក្នុងរយៈពេល៦ខែ ឆ្នាំ២០១៨ តម្រូវការកៅស៊ូធម្មជាតិមានចំនួន ៦,៩៦លានតោន (កើនឡើង៥%) ស្របពេលដែលការផ្គត់ផ្គង់មានចំនួន ៦,២១៤លានតោន (កើនឡើង៤,៥%)។ តាមទិន្នន័យនេះ បរិមាណផ្គត់ផ្គង់នឹងតិចជាងតម្រូវការចំនួន ៧៤៦ ០០០តោន នៅក្នុងឆមាសទី១ ឆ្នាំ ២០១៨។ តាមរយៈបច្ចុប្បន្នភាពនៃការព្យាករនាពេលថ្មីៗកន្លងទៅនេះ បានឲ្យដឹងថា៖ បរិមាណផលិតផល

កៅស៊ូពិភពលោកក្នុងឆ្នាំ២០១៨ នឹងមានចំនួន ១៤,០៤លានតោន (កើន៥,២%) ឯបរិមាណតម្រូវការនឹងមានចំនួន ១៤,១៣៦លានតោន (ឡើង៥,៧%)។ មូលដ្ឋានអនុគ្រោះនៃតុល្យភាពរវាងតម្រូវការ និងការផ្គត់ផ្គង់មិនអាស្រ័យលើស្ថានភាពអំណោយផលនៃទីផ្សារទេទាំងទីផ្សារទិញ-លក់ភ្លាមៗ និងទីផ្សារជួញដូរតាមកិច្ចសន្យាដែលទីផ្សារទាំងនេះ ទំនងជាទទួលរងឥទ្ធិពលពីកត្តាខាងក្រៅច្រើនជាងដែលរួមមាន៖ ស្ថានភាពវិវឌ្ឍនៃឧស្សាហកម្មប្រេងឆៅនឹងភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិកនិងចិន។ ចំពោះស្ថានភាព តម្លៃកៅស៊ូនៅលើទីផ្សារវិញបង្ហាញថា៖ តម្លៃកៅស៊ូធម្មជាតិនៅទីផ្សាសៀងហៃមិនទាន់ប្រសើរឡើងច្រើនទេអាស្រ័យដោយការធ្លាក់ចុះនៃតម្លៃប្រាក់យន់របស់ប្រទេសចិន បើធៀបទៅនឹងប្រាក់ដុល្លារអាម៉េរិកចាប់ពីចុងខែមេសាកន្លងទៅ រួមនឹងការសល់បរិមាណសន្និធិកៅស៊ូច្រើននៅក្នុងឃ្លាំងនានាដែលហេតុការណ៍នេះបានធ្វើឲ្យស្រុតចុះរំញោចទីផ្សារកៅស៊ូទិញ-លក់ភ្លាមៗនៅទូទាំងប្រទេស។

ទោះជាយ៉ាងណាក៏ដោយ ក្រុមការងារព្រឹត្តិបត្រកៅស៊ូធម្មជាតិ នៃអគ្គនាយកដ្ឋានកៅស៊ូនឹងនៅតែបន្តយកចិត្តទុកដាក់តាមដានពីគ្រប់មជ្ឈដ្ឋានប្រភពព័ត៌មានដើម្បីផ្តល់ជូនខ្លឹមសារ និងរូបភាពកាន់តែច្បាស់ថែមទៀតអំពីស្ថានភាពវិវឌ្ឍនិន្នាការទីផ្សារ និងទស្សនវិស័យនៃឧស្សាហកម្មកៅស៊ូធម្មជាតិសម្រាប់រយៈពេលខ្លីមធ្យមនិងវែង ទាំងក្នុងក្របខណ្ឌជាតិ តំបន់ និងពិភពលោក។ ជាមួយគ្នានេះ ក្រុមការងារយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក/អ្នកឧកញ៉ា និងមិត្តអ្នកអានទាំងអស់ និងរង់ចាំទទួលមតិរិៈគន់ស្ថាបនាពីគ្រប់មជ្ឈដ្ឋាន ដើម្បីកែលម្អព្រឹត្តិបត្រកៅស៊ូធម្មជាតិប្រចាំខែរបស់យើងខ្ញុំឲ្យកាន់តែមានគុណភាពប្រសើរឡើងថែមទៀត៕

# ព័ត៌មានក្នុងប្រទេស

## វគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត នៅខេត្តកំពង់ចាម

ចាប់ពីថ្ងៃទី៥-៨ ខែមិថុនា ឆ្នាំ២០១៨ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនាយកដ្ឋានរដ្ឋបាល និងនីតិកម្មបានចុះបើកវគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធវិស័យកៅស៊ូ នៅស្រុកចំការលើ ខេត្តកំពង់ចាម។ វគ្គផ្សព្វផ្សាយនេះ បានការអញ្ជើញចូលរួមជាអធិបតីដោយលោក **សេក ឥទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ កញ្ញា **ហាក់ សុទីរ៉ានី** អភិបាលរងស្រុកចំការលើ និងលោក **ស៊ឹម ថាវិទ:** អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម ព្រមទាំងមានការចូលរួមពីកសិករកៅស៊ូគ្រួសារសរុបចំនួន៥២នាក់ (ស្រី១៣នាក់) បានចូលរួម។

គោលបំណងនៃវគ្គផ្សព្វផ្សាយនេះ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍ និងលើកកម្ពស់ការគ្រប់គ្រងវិស័យកៅស៊ូប្រកបដោយប្រសិទ្ធភាពស្របតាមលិខិតបទដ្ឋានគតិយុត្ត បញ្ជ្រាបការយល់ដឹងដល់ប្រតិបត្តិករកៅស៊ូពីដំណើរការប្រព្រឹត្តទៅរចនាសម្ព័ន្ធដឹកនាំ និងភារកិច្ចចម្បងៗរបស់អគ្គនាយកដ្ឋានកៅស៊ូ និងអង្គភាពចំណុះដូចមានចែងក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានសុពលភាពក្នុងការគ្រប់គ្រងវិស័យកៅស៊ូ។




*លោក **សេក ឥទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ អញ្ជើញចូលរួមជាអធិបតី*

ជាកិច្ចចាប់ផ្តើមកញ្ញា **ហាក់ សុទីរ៉ានី** បានមានមតិស្វាគមន៍និងថ្លែងអំណរគុណដល់អគ្គនាយកដ្ឋានកៅស៊ូ ដែលបានមកបើកវគ្គផ្សព្វផ្សាយនៅក្នុងស្រុកចំការលើនេះ។ កញ្ញាបានលើកឡើងអំពីស្ថានភាពទូទៅក្នុងភូមិសាស្ត្រស្រុកចំការលើ ជាពិសេសការដាំដុះដំណាំកៅស៊ូ ក្នុងមូលដ្ឋានជូនដល់អង្គពិធីឲ្យបានជ្រាបនិងស្នើសូមឲ្យបងប្អូនកសិករទាំងអស់យកចិត្តទុកដាក់ស្តាប់ពីការធ្វើបទបង្ហាញរបស់ក្រុមការងារដើម្បីជាប្រយោជន៍ក្នុងការងារប្រចាំថ្ងៃ។

បន្ទាប់មក លោក **ស៊ឹម ថាវិទ:** បានធ្វើរបាយការណ៍សង្ខេបអំពីស្ថានភាពនៃវិស័យកសិកម្ម ពិសេសស្ថានភាពផលិតកម្មដំណាំកៅស៊ូ នៅក្នុងខេត្តនិងក្នុងស្រុកចំការលើជូនអង្គពិធីបានជ្រាប។

ជាកិច្ចបន្ត លោក **សេក ឥទ្ធី** បានមានមតិសំណេះសំណាលនិងប្រកាសបើកវគ្គផ្សព្វផ្សាយ ដោយបានគូសបញ្ជាក់ថា ការផ្សព្វផ្សាយនេះពិតជា

មានសារៈសំខាន់សម្រាប់បងប្អូន ពិសេសបានផ្តល់នូវព័ត៌មានថ្មីៗមួយចំនួនទាក់ទងទៅនឹងវិស័យកៅស៊ូដល់បងប្អូនកសិករដល់មូលដ្ឋាន។

បន្ទាប់ពីបានសម្រាកពិសារអាហារសម្រន់ វគ្គផ្សព្វផ្សាយបានចាប់ផ្តើមដំណើរការកម្មវិធីតាមការគ្រោងទុកដែលរួមមានចំនួន៣ប្រធានបទ៖

- ប្រធានបទទី១៖អនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីអំពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋានការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអរដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បកស្រាយដោយ លោក **សន សុធី** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម

- ប្រធានបទទី២៖ "សារាចរណែនាំលេខ១០ សរណន ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីអំពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសរបស់រាជរដ្ឋាភិបាលកម្ពុជា" បកស្រាយដោយលោក **ឃួន ផល្លា** ប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម

- ប្រធានបទទី៣៖ "ប្រកាសលេខ១៨០ប្រក.កសក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ស្តីអំពីនីតិវិធីនៃការគ្រប់គ្រងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" បកស្រាយដោយលោក **ឃួន ផល្លា** ប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម។

បន្ថែមពីនេះ ក្រុមការងារក៏បានជម្រាបជូនព័ត៌មានមួយចំនួនទាក់ទងនឹងវិស័យកៅស៊ូនាពេលបច្ចុប្បន្នជូនដល់អង្គពិធីបានជ្រាប ជាពិសេសសូមឲ្យបងប្អូនតាមដាននូវព័ត៌មានទាក់ទងនឹងវិស័យកៅស៊ូតាមរយៈបណ្តាញសង្គមហ្វេសប៊ុករបស់អគ្គនាយកដ្ឋានកៅស៊ូដែលមានទំព័រផ្លូវការឈ្មោះ "**អគ្គនាយកដ្ឋានកៅស៊ូ General Directorate of Rubber**" ឬស្តាប់វិទ្យុ **FM102 MHz** នៅរៀងរាល់ថ្ងៃច័ន្ទ វេលាម៉ោង១០:១០នាទី។

ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធវិស័យកៅស៊ូនៅស្រុកចំការលើ ខេត្តកំពង់ចាមបានទទួលលទ្ធផលល្អ ដោយមានការចូលរួមនិងសហការយ៉ាងជិតស្និទ្ធពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត អាជ្ញាធរមូលដ្ឋាន ការិយាល័យកសិកម្មស្រុក និងកសិករយ៉ាងផុសផុល៕



*រូបថតអនុស្សាវរីយ៍*

# ការចុះពង្រឹងសហគមន៍កសិកម្ម កៅស៊ូគ្រួសារ ស្រុកស្នួល ខេត្តក្រចេះ

ចាប់ពីថ្ងៃទី ៦-៩ ខែមិថុនា ឆ្នាំ២០១៨ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ បានចុះបំពេញបេសកកម្មនៅស្រុកស្នួល ខេត្តក្រចេះ ដើម្បីបើកវគ្គស្តីអំពី "ការចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ" ក្រោមអធិបតីភាពលោក **ផេង មុន្នាទី** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ ដល់កសិករកៅស៊ូគ្រួសារក្នុងគោលបំណង៖

- ផ្តល់ការយល់ដឹងពីវិធីសាស្ត្រគ្រប់គ្រងចំណូល-ចំណាយ
- ការចុះបញ្ជីគណនេយ្យ ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ មូលដ្ឋានគ្រឹះក្នុងការដឹកនាំសហគមន៍របស់ខ្លួនតាមបែបប្រជាធិបតេយ្យ
- ការប្រើប្រាស់ទុនរកស៊ីប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។

វគ្គបណ្តុះបណ្តាល ពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារនេះ ត្រូវបានរៀបចំនៅសាលប្រជុំក្នុងសណ្ឋាគារចម្ប៉ា-ពេជ្រ ដោយមានការចូលរួមពីថ្នាក់ដឹកនាំសហគមន៍ (ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ) និងសមាជិកសហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកស្នួល ចូលរួមសរុបមានចំនួន៣០នាក់ (ស្រី៥នាក់) បានចូលរួម។

វគ្គបណ្តុះបណ្តាលបានធ្វើបទបង្ហាញផ្តោតលើប្រធានបទសំខាន់មួយចំនួនពាក់ព័ន្ធនឹងការចុះ និងគ្រប់គ្រងបញ្ជីគណនេយ្យសម្រាប់ផែនការអភិវឌ្ឍន៍សហគមន៍កសិកម្មរួមមាន៖

១.អ្វីជាបញ្ជីគណនេយ្យសហគមន៍កសិកម្ម?
២.តើការចុះបញ្ជីគណនេយ្យផ្តល់សារៈប្រយោជន៍អ្វីខ្លះដល់សហគមន៍កសិកម្ម?
៣.វិធីសាស្ត្រកត់ត្រាបញ្ជីគណនេយ្យដែលត្រូវចងចាំ
៤.ក្បួនវិភាគប្រតិបត្តិការ
៥.ការចុះទិន្នានុប្បវត្តិ
៦.ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ
៧.ការរៀបចំតារាងតុល្យការ និង
៨.ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ



*សកម្មភាពនៃវគ្គពង្រឹងសហគមន៍កសិករកៅស៊ូ គ្រួសារស្រុកស្នួល ខេត្តក្រចេះ*

បន្ទាប់ពីការធ្វើបទបង្ហាញនីមួយៗបានបញ្ចប់ វាគ្មិនយើង បានធ្វើការបកស្រាយរាល់សំណួររបស់អ្នកចូលរួមដែលបានចោទសួរ ព្រមទាំងបានធ្វើការពិភាក្សាពីដំណើរការសហគមន៍ បន្ទាប់ពីទទួលបានវិញ្ញាបនបត្រទទួលស្គាល់ពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ ដើម្បីធ្វើឲ្យសហគមន៍ប្រកបមុខរបរដោយភាពរលូន និង គ្រប់គ្រងសហគមន៍

របស់ខ្លួនប្រកបដោយប្រសិទ្ធភាពតាមបែបប្រជាធិបតេយ្យ។

តាមរយៈលទ្ធផល វគ្គចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកស្នួល ខេត្តក្រចេះ បានបង្ហាញឲ្យឃើញថា៖

១/ ថ្នាក់ដឹកនាំនិងសមាជិកសហគមន៍កសិកម្មកៅស៊ូគ្រួសារទាំងអស់មានការចាប់អារម្មណ៍ក្នុងការគ្រប់គ្រងបញ្ជីគណនេយ្យ សម្រាប់ផែនការអភិវឌ្ឍន៍សហគមន៍កសិកម្ម

២/ សមាជិកសហគមន៍ទាំងអស់បានចូលរួមពិភាក្សាយ៉ាងផុសផុលជាមួយមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានកៅស៊ូនិងមន្ត្រីជំនាញមកពីការិយាល័យអភិវឌ្ឍន៍សហគមន៍នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ ដើម្បីឲ្យសហគមន៍កាន់តែរឹងមាំនិងបានសំណូមពរឲ្យមានការរៀបចំវគ្គផ្សេងៗទៀត៕

**ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានកៅស៊ូ ចូលរួមសិក្ខាសាលាស្តីពី "ឆ្ពោះទៅរកប្រសិទ្ធិភាពខ្សែច្រវ៉ាក់នៃការផ្គត់ផ្គង់" នៅទីក្រុងហាត់យ៉ៃ ប្រទេសថៃ**

ចាប់ពីថ្ងៃទី១៩ - ២១ ខែមិថុនា ឆ្នាំ២០១៨ ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានកៅស៊ូចំនួន០៣រូបគឺ៖ លោក **យុន ភក្តដា** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ លោក **ហ៊ិន សាផន** ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ និងលោក **គុយ ភក្តី** អនុប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិបានចូលរួមសិក្ខាសាលាស្តីអំពី "ឆ្ពោះទៅរកប្រសិទ្ធិភាពខ្សែច្រវ៉ាក់នៃការផ្គត់ផ្គង់" នៅទីក្រុងហាត់យ៉ៃ ប្រទេសថៃ។ គោលបំណងនៃអង្គសិក្ខាសាលានេះគឺ (១)ការចែករំលែកបទពិសោធន៍អំពីប្រព័ន្ធខ្សែច្រវ៉ាក់តម្លៃដែលកំពុងអនុវត្តនៅតាមបណ្តាប្រទេសជាសមាជិក ANRPC (២) ការរិះរកលទ្ធិភាពដើម្បីធ្វើឲ្យប្រសើរឡើងនូវតម្លៃមាត់ចម្ការជាអតិបរមា (៣) ការធ្វើទស្សនកិច្ចសិក្សាស្វែងយល់បន្ថែមអំពីប្រតិបត្តិការនៃមជ្ឈមណ្ឌលទីផ្សារកៅស៊ូរួមនិងរោងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកដែលទទួលបានឈ្មោះថា **ការអនុវត្តការកែច្នៃស្អាត** (GMP- Good Manufacturing Practice)។

## ១.ពិធីបើកសិក្ខាសាលានិងវត្តមានចូលរួម

សិក្ខាសាលានេះបានអញ្ជើញចូលរួមប្រកាសបើកដោយលោក **Yium Tavarolit** អគ្គនាយកស្តីទីនៃអាជ្ញាធរកៅស៊ូថៃ និងមានសមាជិកមកពី៖ កម្ពុជា៣នាក់ បង់ក្លាដែសចំនួន១នាក់ ឥណ្ឌាចំនួន១នាក់ ឥណ្ឌូនេស៊ីចំនួន២នាក់ ម៉ាឡេស៊ីចំនួន២នាក់ ហ្វីលីពីនចំនួន១នាក់ ស្រីលង្កាចំនួន២នាក់ ថៃចំនួន១៦នាក់ វៀតណាមចំនួន២នាក់ និងលេខាធិការដ្ឋាន ANRPC ២នាក់ សរុបចំនួន៣៤នាក់ បានចូលរួម។ លោក **Yium Tavarolit** បានគូសបញ្ជាក់អំពីតួនាទីនៃប្រសិទ្ធិភាពខ្សែច្រវ៉ាក់នៃការផ្គត់ផ្គង់ដែលនឹងជួយឲ្យប្រសើរឡើងតម្លៃនៅមាត់ចម្ការ។

## ២. ខ្លឹមសារនៃអង្គសិក្ខាសាលា

អង្គសិក្ខាសាលាបានសម្រេចជ្រើសរើស (១) លោក **Yium Tavarolit** អគ្គនាយកស្តីទីនៃអាជ្ញាធរកៅស៊ូថៃ ជាប្រធានដឹកនាំអង្គសិក្ខាសាលាទៅតាមសំណើរបស់តំណាងប្រតិភូពីប្រទេសហ្វីលីពីន និងម៉ាឡេស៊ី និង (២) លោក **Janaka Dharmakeerthi** ប្រធានប្រតិភូប្រទេសស្រីលង្កា ជាអនុប្រធានតាមសំណើរបស់តំណាងប្រតិភូពីប្រទេសកម្ពុជា និងឥណ្ឌូណេស៊ី បានប្រព្រឹត្តិទៅតាមកម្មវិធីជាបន្តបន្ទាប់ចំនួន០២ថ្ងៃ។

## ២.១.ការពិនិត្យឡើងវិញអំពីរចនាសម្ព័ន្ធនៃឧស្សាហកម្មកៅស៊ូនៅតាមបណ្តាប្រទេសសមាជិក

អគ្គលេខាធិការដ្ឋាន ANRPC បានធ្វើបទបង្ហាញសង្ខេបអំពីឧស្សាហកម្មកៅស៊ូទៅតាមបណ្តាប្រទេសជាសមាជិកនីមួយៗរួមមាន៖ ទំហំ រចនាសម្ព័ន្ធ និងទិន្នន័យអំពីតំបន់ដែលដាំដុះកៅស៊ូ ផ្ទៃដីចៀរ អត្រាភាគរយនៃកៅស៊ូគ្រួសារ ភាពខុសគ្នាទម្រង់នៃការកែច្នៃកៅស៊ូ និងការនាំចេញនិងនាំចូល។ ក្នុងឱកាសសិក្ខាសាលានេះផងដែរ អគ្គលេខាធិការដ្ឋានបានបង្ហាញពីការពង្រីកផ្ទៃដីចៀរតាមបណ្តាប្រទេសនីមួយៗចាប់ពីឆ្នាំ២០១៥-២០២៥។

**តារាងផ្ទៃដីចៀរចាប់ពីឆ្នាំ២០១៥-២០១៨ (ពាន់ហិកតា)**

| ប្រទេស | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|
| កម្ពុជា | 111,2 | 127 | 170,2 | 204 2 |
| ចិន | 711 | 720 | 744 | 770 |
| ឥណ្ឌា | 558,9 | 585,6 | 614,5 | 639,5 |
| ឥណ្ឌូណេស៊ី | 3 036 | 3 042 | 3 054 | 3 127,4 |
| ម៉ាឡេស៊ី | 512 | 481,1 | 521 | 483 |
| ហ្វីលីពីន | 116,9 | 142,7 | 153 | 162 |
| ស្រីលង្កា | 83,4 | 87,1 | 102,7 | 105,7 |
| ថៃ | 2 994,7 | 3 117,6 | 3 075,5 | 3 111,2 |
| វៀតណាម | 604,3 | 621,4 | 652,7 | 660 |
| **សរុប** | **8 728,4** | **8 924,5** | **9 088** | **9 263** |

**តារាងប៉ាន់ស្មានកំណើនផ្ទៃដីចៀរចាប់ពី ឆ្នាំ២០១៩-២០២៥ (ពាន់ហិកតា)**

| ប្រទេស | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|
| ចិន | 70,6 | 50,3 | 29,1 | 30,7 |
| ឥណ្ឌា | 85 | 26,7 | 25,4 | 26 |
| ឥណ្ឌូណេស៊ី | 34,5 | 36 | 32 | 31 |
| ម៉ាឡេស៊ី | 110 | 95 | 95 | 60 |
| ហ្វីលីពីន | 54,3 | 60,6 | 54,3 | 46 |
| ស្រីលង្កា | 18,3 | 12,6 | 36,7 | 25,1 |
| ថៃ | 6,6 | 8,4 | 45 | 2.7 |
| វៀតណាម | 165,5 | 80,1 | 71,8 | 53,3 |
| កម្ពុជា | 131,6 | 55,9 | 40,1 | 32,7 |
| **សរុប** | **676,4** | **425,6** | **388,9** | **307,5** |

## ២.២. ប្រព័ន្ធខ្សែច្រវ៉ាក់ផ្គត់ផ្គង់នៅតាមបណ្តាប្រទេសសមាជិក

អង្គសិក្ខាសាលា បានស្តាប់និងពិភាក្សាបទបង្ហាញអំពីប្រព័ន្ធខ្សែច្រវ៉ាក់ផ្គត់ផ្គង់នៃបណ្តាប្រទេសជាសមាជិកដោយផ្តោតលើ៖ (១) ស្ថិតិតាមផ្នែកនីមួយៗនៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់ (២)ស្ថាប័នគន្លឹះពាក់ពន្ធ័នឹងសកម្មភាពសម្របសម្រួលនិងអភិវឌ្ឍ (៣) លំហូរនៃផលិតផលកៅស៊ូពីចម្ការទៅកំពង់ផែ ឬអ្នកប្រើប្រាស់ចុងក្រោយ (៤) កំណើនតម្លៃតាមផ្នែកនីមួយៗនៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់ (៥) សមិទ្ធិផលសម្រេចបានក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់រយៈពេលខ្លីនិងទិសដៅបន្ត (៦) ប្រភេទនិងប្រភពនៃវត្ថុធាតុដើម (៧) ការលក់ដូរ ការកែច្នៃនិងការផលិតផលិតផលសម្រេចពីកៅស៊ូរបស់ក្រុមកសិករនិងសហការណ៍ និង (៨) ទិដ្ឋភាពបរិស្ថាននៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់។

វិធានការគោលនយោបាយ ឬសកម្មភាពដែលប្រទេសជាសមាជិក បានអនុវត្តកន្លងមកមានដូចខាងក្រោម ៖

## i- ប្រទេសកម្ពុជា

- ការគ្រប់គ្រងផ្ទៃដីកៅស៊ូបែងចែកជា៣គឺ៖ អតីតចម្ការកៅស៊ូរដ្ឋមានចំនួន១០ក្រុមហ៊ុន ចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ចចំនួន ១២៤ក្រុមហ៊ុន និងចម្ការកៅស៊ូគ្រួសារបានដាំដុះលើផ្ទៃដី២១ខេត្ត
- គិតត្រឹមឆ្នាំ២០១៧ អតីតចម្ការកៅស៊ូរដ្ឋ និងសម្បទានដីសេដ្ឋកិច្ចមានផ្ទៃដីសរុបចំនួន ២៨០ ២២៨ហិកតា (៦៤%) និងកៅស៊ូគ្រួសារមានចំនួន១៥៦ ១១២ហិកតា (៣៦%)។ ផ្ទៃដីចៃទាំសរុបមានចំនួន ២៦៦ ១១០ហិកតា (៦១%) នៃផ្ទៃដីដាំដុះសរុបទូទាំងប្រទេសចំនួន ៤៣៦ ៣៤០ហិកតា
- កសិករកៅស៊ូគ្រួសារមានចំនួន ៣២ ១០០ គ្រួសារ
- នៅឆ្នាំ២០១៧នេះ ប្រទេសកម្ពុជាបាននាំចេញកៅស៊ូសរុបចំនួន ១៨៨ ៨៣២ តោន
- រោងចក្រកែច្នៃកៅស៊ូដុំចំនួន៣៧ រោងចក្រជ័រកៅស៊ូខាប់ចំនួន១ សិប្បកម្មកែច្នៃកៅស៊ូសន្លឹក RSS ចំនួន៩២ និងរោងចក្រកែច្នៃឈើចំនួន៩ កសិករលក់ផលិតផលកៅស៊ូតាមរយៈ (ឈ្មួញកណ្ដាល/ភាក់ងារទិញ) ភ្នាក់ងារប្រមូលទិញឯកជននិងដឹកមករោងចក្រដើម្បីកែច្នៃជាផលិតផលអាចនាំចេញបាននិងលក់ផលិតផលតាមតម្លៃFOB។ អតីតចម្ការកៅស៊ូរដ្ឋ បានកែច្នៃផលិតផល និងនាំចេញដោយខ្លួនឯងឬតាមរយៈឈ្មួញកណ្ដាល
- តម្លៃមាត់ចម្ការបានត្រឹមតែ ៦៨% នៃតម្លៃ FOB ប៉ុណ្ណោះ។ ភាពលំអៀងដ៏ធំរវាងតម្លៃមាត់តម្ការនិងតម្លៃFOB កើតចេញពីថ្លៃសេវាមួយចំនួនរួមមាន៖ ថ្លៃដើមកែច្នៃ ពន្ធថ្លៃដឹកជញ្ជូន សេវាវិញ្ញាបនបត្រ SPS, CO និងការធ្វើធូបនកម្ម។ តម្លៃនៅមាត់ចម្ការទាបអា-ស្រ័យដោយ៖ វត្តមានឈ្មួញកណ្ដាលច្រើនដំណាក់ ភាពខ្សោយនៃសហគមនកៅស៊ូគ្រួសារ កង្វះខាតផ្នែកលំហូរខាងក្រោមក្នុងប្រទេស និងគុណភាពទាបនៃការផ្គត់ផ្គង់វត្ថុធាតុដើមកៅស៊ូរបស់កសិករកៅស៊ូគ្រួសារ
- វិធីសាស្ត្រដោះស្រាយបញ្ហាតម្លៃមាត់ចម្ការចុះទាប៖ រដ្ឋាភិបាលកម្ពុជាបានជំរុញការកែច្នៃជាក្រុមតាមរយៈការបង្កើត និងពង្រឹងសហគមន៍កសិករកៅស៊ូគ្រួសារ និងខិតខំប្រឹងប្រែងពង្រឹងខ្សែច្រវ៉ាក់ផ្គត់ផ្គង់។ រដ្ឋា-ភិបាលគ្រោងនឹងបង្កើតសហគមន៍កសិករកៅស៊ូគ្រួសារឲ្យបានច្រើនដើម្បីធ្វើឲ្យប្រសើរឡើងនូវទម្រង់ប្រព័ន្ធទីផ្សារទូលំទូលាយ និងផ្ដល់វគ្គបណ្ដុះបណ្ដាលប្រកបដោយប្រសិទ្ធិភាព។ វិធីសាស្ត្រទាំងនេះត្រូវបានរំពឹងទុកថានឹងកាត់បន្ថយអន្តរាគមរបស់ឈ្មួញកណ្ដាល ជួយបង្កើនអំណាចចរចាថ្លៃរបស់កសិករ និងធ្វើឲ្យថ្លៃដើមផលិតកម្មមានកម្រិតទាបជាអប្បបរមា

- ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដែលមានតួនាទីភារកិច្ចក្នុងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូកម្ពុជារួមមាន៖ (១)អគ្គនាយកដ្ឋានកៅស៊ូជាសេនាធិការឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបង្កើតគោលនយោបាយសម្រាប់ទីផ្សារកៅស៊ូ សហគមន៍និងក្រុមកសិករអ្នកដាំកៅស៊ូ។អគ្គនាយកដ្ឋានកៅស៊ូមានតួនាទីត្រួតពិនិត្យគុណភាពកៅស៊ូធម្មជាតិ និងការផ្តល់កម្មសិទ្ធិបញ្ញាសម្រាប់ពាណិជ្ជកម្មកៅស៊ូកម្ពុជា។ (២) ក្រសួងពាណិជ្ជកម្មទទួលខុសត្រូវចុះបញ្ជីក្រុមហ៊ុន និងគ្រប់គ្រងបញ្ហាទីផ្សារ (៣) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការប្រមូលពន្ធនាំចេញផលិតផលកៅស៊ូ
- គោលនយោបាយនិងយុទ្ធសាស្ត្រនានាដែលមានសក្តានុពល ពង្រឹងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ឧស្សាហកម្មកៅស៊ូកម្ពុជារួមមាន៖ (១)ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ (២) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសិកម្មឆ្នាំ២០១៤-២០១៨ (៣)គោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ (៤) ច្បាប់ស្តីពីសហគមន៍កសិកម្ម (៥) យុទ្ធសាស្ត្រអភិវឌ្ឍកៅស៊ូធម្មជាតិកម្ពុជាឆ្នាំ២០១១-២០២០ និង (៦) យុទ្ធសាស្ត្រអភិវឌ្ឍកៅស៊ូធម្មជាតិកម្ពុជាឆ្នាំ២០១៦-២០២៣។

**តារាងទិន្នន័យនៃដំណាំកៅស៊ូគ្រួសារនៅកម្ពុជា**

| ខេត្ត | ចំនួនគ្រួសារដែលបានដាំដំណាំកៅស៊ូ | ផ្ទៃដីចៀរ (ហិកតា) |
|---|---|---|
| ត្បូងឃ្មុំ | 17 949 | 46 379 |
| កំពង់ចាម | 2 931 | 21 010 |
| ក្រចេះ | 2 638 | 7 671 |
| រតនគិរី | 2 260 | 36 349 |
| កំពង់ធំ | 2 260 | 36 349 |
| មណ្ឌលគិរី | 1 606 | 11 305 |
| ខេត្តផ្សេងៗ | 2 456 | 11 167 |
| **សរុប** | **32 100** | **170 230** |

## ii- ប្រទេសវៀតណាម

- បានពង្រីកផ្ទៃដីដាំដុះកៅស៊ូយ៉ាងរហ័សក្នុងអំឡុងឆ្នាំ២០១១-២០១៥ ស្របពេលដែលតម្លៃកៅស៊ូកើនឡើងប៉ុន្តែវិស័យនេះសឹងតែជាប់គាំងវិញនៅចន្លោះឆ្នាំ២០១២-២០១៦ ដោយសារតម្លៃកៅស៊ូធ្លាក់ចុះ។ ផ្ទៃដីកៅស៊ូសរុបក្នុងឆ្នាំ២០១៧ ចំនួន ៩៧១ ៦០០ ហិកតា
- ទិន្នផលមធ្យម១ ៦៦៥គោន/ហ.ត/ឆ្នាំ ខ្ពស់ជាងគេក្នុងចំណោមប្រទេសផលិតកៅស៊ូធម្មជាតិ
- ផលិតផលនាំចេញសរុប១,៣៨លានតោន (+១០,២%) ស្មើនឹងទឹកប្រាក់ចំនួន២,២៥ ពាន់លានដុល្លារសហរដ្ឋអាម៉េរិក (+៣៤,៧%) ធៀបនឹងឆ្នាំមុន។តម្លៃជាមធ្យមគឺ១ ៦២៩ ដុល្លារសហរដ្ឋអាម៉េរិក/តោន បានកើនឡើង ២៣% បើធៀបទៅនឹងឆ្នាំមុន
- បាននាំចេញទៅចិន ៦៥,៣% ម៉ាឡេស៊ី

៥,៧% កូរ៉េខាងត្បូង៣,២% ឥណ្ឌា៤,១% អាល្លឺម៉ង់២,៩% សហរដ្ឋអាម៉េរិក២,៦% តៃវ៉ាន់២,១% ទួកគី១,៨% ជប៉ុន០,៩% និងអេស្ប៉ាញ០,៩%

- បាននាំចេញកៅស៊ូចម្រុះ (Rubber-Mixture) ៥៧,២% មាន៖ SVR-3L ១២% SVR-10 ៩% ជ័រទឹក៦,៩% SVR-CV60 ៥,៨% RSS-3 ៤,៥% និង SVR-CV50 ១,៥%
- ចំណូលពីការនាំចេញឈើកៅស៊ូមានចំនួន ១,៩៨ពាន់លានដុល្លារ និងពីផលិតផលសម្រេចពីកៅស៊ូបានចំនួន២,១៥ពាន់លានដុល្លារ។ ចំណូលសរុបដែលទទួលបានពីការនាំចេញផលិតផលទាំងពីរមុខខាងលើបានចំនួន៦,៣៨ពាន់លានដុល្លារកើនឡើង ៣១,៥%។
- ក្នុងអំឡុងឆ្នាំ២០០១-២០១៦ ផ្ទៃដីកៅស៊ូគ្រួសារ បានកើនឡើងលឿនជាងផ្នែករដ្ឋ និងឯកជន។ ត្រឹមឆ្នាំ២០១៦ ផ្ទៃដីកៅស៊ូគ្រួសារកើនដល់៤៨,៨% រដ្ឋ៤៣% និងឯកជន៨,២% នៃផ្ទៃដីកៅស៊ូសរុប
- ទិន្នផលមធ្យមបានកើនឡើងជាបន្តបន្ទាប់ដោយសារការដាំក្លូនផ្តល់ទិន្នផលខ្ពស់ដែលណែនាំដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូវៀតណាម និងការផ្តល់ជំនាញបច្ចេកទេសពីក្រុមប្រឹក្សាកៅស៊ូវៀតណាម។ ទិន្នផលមធ្យមរបស់កៅស៊ូគ្រួសារ បានកើនឡើងប្រហាក់ប្រហែលនឹងកៅស៊ូរដ្ឋដែរ
- ជ័រកៅស៊ូគ្រួសារមិនកែច្នៃដោយផ្ទាល់ទេ ប៉ុន្តែត្រូវបានកែច្នៃដោយផ្នែករដ្ឋនិងឯកជនដោយផ្តោតការយកចិត្តទុកដាក់ខ្លាំងចំពោះតំបន់ភាគខាងកើតឈៀងខាងត្បូងនៃប្រទេស
- វត្ថុធាតុដើមពីកៅស៊ូគ្រួសារបានលក់ទៅឲ្យឈ្មួលកណ្តាលក្នុងភូមិមុននឹងទៅដល់រោងចក្រកែច្នៃ និងបាននាំចេញឬលក់ទៅឲ្យរោងចក្រកែច្នៃបន្តក្នុងស្រុកគិតតាមតម្លៃ FOB។ ចំពោះប្រភេទ SVR-3L កសិករកៅស៊ូគ្រួសារទទួលបាន៨៥,១% នៃតម្លៃ FOB ឯឈ្មួលកណ្តាលបាន០,៦% អ្នកកែច្នៃបាន ៩,៧% និងអ្នកនាំចេញបាន៤,៦% នៃចំណែកដែលនៅសល់
- កត្តាដែលរារាំងដល់កសិករកៅស៊ូគ្រួសារមិនឲ្យទទួលបានតម្លៃមាត់ចម្ការខ្ពស់រួមមាន៖
  - ទីតាំងកំពង់ផែស្ថិតនៅតំបន់ដាច់ស្រយាល
  - វត្តមាននៃឈ្មួញកណ្តាលច្រើនដែលធ្វើឲ្យមានការបែងចែកប្រាក់ចំណេញច្រើន
  - សេវាណែនាំបច្ចេកទេសសម្រាប់ការចេញលិខិតបញ្ជាក់ពីគុណភាពកៅស៊ូនៅមានកម្រិត
  - បរិមាណផលកៅស៊ូរបស់កសិករម្នាក់នៅតិចតួចនៅឡើយ
- ការនាំចេញកៅស៊ូធម្មជាតិវៀតណាមគឺមិនជាប់ពន្ធនាំចេញឡើយ។

**ផ្ទៃតារាងដីនិងផលិតកម្មកៅស៊ូវៀតណាមតាមតំបន់ក្នុងឆ្នាំ២០១៧**

| តំបន់ | ផ្ទៃដីដាំដុះ (ហិកតា) | ផលិតកម្ម (តោន) | ទិន្នផលមធ្យម (គ.ក្រ/ហិកតា) |
|---|---|---|---|
| ខាងជើង | 30 572 | 40 | 600 |
| កណ្ដាល | 147 053 | 93 600 | 1 218 |
| ខ្ពង់រាប | 252 895 | 193 700 | 1 382 |
| ខាងត្បូង | 543 029 | 748 000 | 1 850 |
| **សរុប** | **973 504** | **1 035 000** | **1 666** |

**តារាងផ្ទៃដីតាមប្រភេទកម្មសិទ្ធិ**

| តំបន់ | សហគ្រាសរបស់រដ្ឋ (ហិកតា) | សហគ្រាសឯកជន (ហិកតា) | កសិករកៅស៊ូគ្រួសារ (ហិកតា) | សរុប (ហិកតា) |
|---|---|---|---|---|
| ខាងជើង | 29 190 | 337 | 1 000 | 30 527 |
| កណ្ដាល | 51 318 | 12 967 | 82 768 | 147 053 |
| ខ្ពង់រាប | 135 752 | 37 677 | 79 466 | 252 895 |
| ខាងត្បូង | 202 552 | 29 085 | 311 392 | 543 029 |
| **សរុប** | **418 812** | **80 066** | **474 626** | **973 504** |

**តារាងលិតផលនិងសមត្ថភាពកែច្នៃតាមប្រភេទក្នុងឆ្នាំ២០១៤**

| ប្រភេទ | ផលិតផល (តោន) | % សរុប | សមត្ថភាពកែច្នៃ (តោន) |
|---|---|---|---|
| សហគ្រាសរដ្ឋ | 407 000 | 42,7 | 80 000 |
| សហគ្រាសឯកជន | 22 400 | 2,3 | 444 300 |
| កសិករកៅស៊ូគ្រួសារ | 524 300 | 55 | 0 |
| **សរុប** | **953 700** | **100** | **524 300** |

**តារាងរោងចក្រ សមត្ថភាពកែច្នៃ និងផលិតផលប្រចាំឆ្នាំ២០១៤**

| តំបន់ | រោងចក្រកែច្នៃ | សមត្ថភាពកែច្នៃប្រចាំឆ្នាំ (តោន) | ផលិតផល (តោន) |
|---|---|---|---|
| តំបន់ឆ្នេរខាងជើងនិងកណ្ដាល | 36 | 98 700 | 82 400 |
| តំបន់ខ្ពង់រាប | 19 | 157 300 | 168 183 |
| តំបន់ឥសាន | 106 | 962 100 | 703 064 |
| **សរុប** | **161** | **1 218 100** | **953 700** |

## iii- ប្រទេសថៃ

- កសិករកៅស៊ូគ្រួសារផលិតកៅស៊ូជាទម្រង់ជ័រទឹក ជ័រកក និងកៅស៊ូសន្លឹកសំដិលដោយខ្យល់បន្ទាប់មកបានលក់ផលិតផលទាំងនោះទៅឈ្មួញកណ្ដាល សហករណ៍កសិករកៅស៊ូគ្រួសារ និងមជ្ឈមណ្ឌលទីផ្សារកៅស៊ូរួមដើម្បីកែច្នៃជាកៅស៊ូដុំកៅស៊ូសន្លឹកសម្លូតដោយផ្សែងនិងជ័រខាប់សម្រាប់នាំចេញ ឬលក់បន្តទៅឲ្យរោងចក្រកែច្នៃផលិតផលសម្រេចនៅក្នុងស្រុក
- ជ័រទឹក៤៩%លក់ទៅឲ្យសហករណ៍កៅស៊ូគ្រួសារ ៤៨%ទៅឲ្យឈ្មួញកណ្ដាល និងនៅសល់៣%ទៅរោងចក្រកែច្នៃដោយផ្ទាល់។ ជ័រចាន៥៤% លក់ទៅឲ្យឈ្មួញកណ្ដាល ២២%ទៅឲ្យសហករណ៍កៅស៊ូគ្រួសារ ២០% ទៅឲ្យទីផ្សារដេញថ្លៃឯកជន ២%ទៅឲ្យរោងចក្រកែច្នៃ និងនៅសល់២% ទៀតសម្រាប់លក់ទៅឲ្យរោងចក្រកែច្នៃ
- កៅស៊ូសន្លឹកសដិលដោយខ្យល់ ៤៥% កណ្ដាលលក់ទៅឲ្យឈ្មួញ ២៩% លក់ទៅឲ្យសហករណ៍កៅស៊ូគ្រួសារ២៤% លក់ទៅឲ្យមជ្ឈមណ្ឌលទីផ្សាររួម ១%លក់ទៅឲ្យរោងចក្រកែច្នៃ និងនៅសល់១% ទៀតលក់ទៅឲ្យទីផ្សារដេញថ្លៃឯកជន
- មជ្ឈមណ្ឌលទីផ្សាររួមត្រូវបានគ្រប់គ្រងដោយអាជ្ញាធរកៅស៊ូថៃក្នុងគោលបំណងធានាឲ្យកសិករកៅស៊ូគ្រួសារទទួលបាន

តម្លៃខ្ពស់បើធៀបទៅនឹងតម្លៃទីផ្សារក្នុងស្រុក។ ឧទាហរណ៍៖ កសិករកៅស៊ូគ្រួសារលក់ជ័រចានឲ្យមជ្ឈមណ្ឌលទីផ្សាររួមក្នុងតម្លៃ៤៦,៣១បាត/គ.ក្រ មានន័យថា៖ កសិករកៅស៊ូគ្រួសារទទួលបានតម្លៃខ្ពស់ជាងតម្លៃទីផ្សារក្នុងស្រុក ២,៧៩បាត/គ.ក្រ ដូចគ្នាដែរតម្លៃលក់កៅស៊ូសំដិលដោយខ្យល់ និងកៅស៊ូសន្លឹកសម្ងួតដោយផ្សែងនៅមជ្ឈមណ្ឌលទីផ្សាររួមបានថ្លៃខ្ពស់ជាងតម្លៃទីផ្សារក្នុងស្រុកចំនួន១,៩៨បាត/គ.ក្រ និង ៥,៧៩បាត/គ.ក្ររៀងគ្នា

- រដ្ឋាភិបាលថៃបានចាត់វិធានការបញ្ឈប់ការយកផលពីចម្ការកៅស៊ូរដ្ឋទំហំ ១៦ ០០០ហិកតា ក្នុងអំឡុងខែមករាដល់ខែមីនា ឆ្នាំ២០១៨ ដើម្បីស្រូបយកការផ្គត់ផ្គង់លើសកន្លងមក។

## iv- ប្រទេសម៉ាឡេស៊ី

- ស្ថិតិឧស្សាហកម្មកៅស៊ូប្រទេសម៉ាឡេស៊ីក្នុងឆ្នាំ២០១៧ រួមមាន៖
  - ✓ កសិករកៅស៊ូគ្រួសារចំនួន៤២៣ ៤៩០ គ្រួសារ
  - ✓ កម្មករចៀរជ័រចំនួន១០ ៤៥០នាក់
  - ✓ ផលិតផលកៅស៊ូប្រចាំឆ្នាំចំនួន ៧៤ ២៧៨តោន កសិករកៅស៊ូគ្រួសារមាន ៩៣%
  - ✓ អ្នកធុរកិច្ចកៅស៊ូ២ ៩៦១នាក់រួមមាន៖ ពាណិជ្ជករក្នុងស្រុក អ្នកនាំចូល និង អ្នកនាំចេញ
  - ✓ ក្រុមហ៊ុនកែច្នៃកៅស៊ូដុំ (SMR) ចំនួន៤៣
  - ✓ ក្រុមហ៊ុនកែច្នៃជ័រខាប់ចំនួន១២ ស្មើនឹង ៦% នៃផលិតផលសរុប
  - ✓ កម្មករក្នុងវិស័យរោងចក្រកែច្នៃកៅស៊ូចំនួន៨ ៣១៦នាក់
  - ✓ ក្រុមហ៊ុនកែច្នៃផលិតផលសម្រេចពីកៅស៊ូចំនួន៣០៥(ក្នុងនោះក្រុមហ៊ុនផលិតសំបកកង់យានយន្តចំនួន៨ និងផលិតគ្រឿងបន្លាស់យានយន្តចំនួន១៣)
  - ✓ កម្មករក្នុងរោងចក្រកែច្នៃផលិតផលសម្រេចចំនួន៧៧ ៣២៧នាក់
  - ✓ ការប្រើប្រាស់កៅស៊ូធម្មជាតិប្រចាំឆ្នាំចំនួន៤៨៨ ៧១៩តោន/ឆ្នាំ
  - ✓ ការនាំចេញកៅស៊ូធម្មជាតិប្រចាំឆ្នាំចំនួន១,១៩៤លានតោន
  - ✓ ការនាំចូលកៅស៊ូធម្មជាតិប្រចាំឆ្នាំចំនួន ១,០៩៦លានតោន
- វត្ថុធាតុដើមជាជ័រចាននិងជ័រទឹកពីកសិករកៅស៊ូគ្រួសារបានលក់ទៅឲ្យឈ្មួញក្នុងភូមិដែលឈ្មួញភាគច្រើនយកទៅលក់បន្តឲ្យរោងចក្រដើម្បីកែច្នៃជាទឹកជ័រនិងកៅស៊ូដុំទើបលក់បន្តទៅឲ្យក្រុមហ៊ុនកែច្នៃផលិតផលសម្រេចក្នុងស្រុកឬនាំចេញតែម្តង
- ក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ីយកចិត្តទុកដាក់ចំពោះការស្រាវជ្រាវនិងបំពេញមុខងារទៅតាមច្បាប់នៃឧស្សាហកម្មកៅស៊ូម៉ាឡេស៊ីដែលរួមមាន៖ការផ្តល់អាជ្ញាបណ្ណដល់ការធ្វើពាណិជ្ជកម្ម និងការកែច្នៃ។ អាជ្ញាធរ

អភិវឌ្ឍន៍ឧស្សាហកម្មកសិករកៅស៊ូគ្រួសារ RISDA- Rubber Industry Smallholders Development Authority) យកចិត្តទុកដាក់ទៅលើសេវាបច្ចេកទេស ការប្រឹក្សាយោបល់ និងផ្តល់វគ្គបណ្តុះបណ្តាលដល់កសិករអ្នកដាំកៅស៊ូ

- សមាគមឧស្សាហកម្មផ្សេងៗក៏មានវត្តមានយ៉ាងសកម្មក្នុងឧស្សាហកម្មកៅស៊ូម៉ាឡេស៊ីផងដែរដូចជា៖ សមាគមជាតិកសិករកៅស៊ូគ្រួសារ (NASH- National Association of Smallholders) សហព័ន្ធសមាគមពាណិជ្ជកម្មកៅស៊ូម៉ាឡេស៊ី (FRTAM- Federation of Rubber Trade Association of Malaysia) សមាគមរោងចក្រផលិតផលិតផលកៅស៊ូម៉ាឡេស៊ី (MRPMA- Malaysian Rubber Products Manufacturers' Association) សមាគមរោងចក្រផលិតស្រោមដៃកៅស៊ូម៉ាឡេស៊ី (MARGMA-Malaysia Rubber Gloves Manufacturers' Association) និងក្រុមប្រឹក្សាជំរុញការនាំចេញកៅស៊ូម៉ាឡេស៊ី (MREPC- Malaysia Rubber Exports promotion Council)
- តម្លៃកៅស៊ូម៉ាឡេស៊ីបង្ហាញថា៖ បើតម្លៃ FOB នៃកៅស៊ូ SMR 20 ស្មើនឹង ៥៥០សេនរីងហ្គីត/គ.ក្រ នោះអ្នកកែច្នៃទទួលបាន ៤៣០សេនរីងហ្គីត/គ.ក្រ ឈ្មួញទទួលបាន ៣៩០សេនរីងហ្គីត/គ.ក្រ រីឯកសិករកៅស៊ូគ្រួសារទទួលបាន ១៩៥សេនរីង-ហ្គីត/គ.ក្រ នៃទម្ងន់ជ័រកកសើម (គឺ៥០% នៃ៣៩០សេនរីងហ្គីត/គ.ក្រ
- ក្នុងកិច្ចខិតខំប្រឹងប្រែងពង្រឹងខ្សែច្រវ៉ាក់ផ្គត់ផ្គង់រដ្ឋាភិបាលម៉ាឡេស៊ីបានបំពាក់ប្រព័ន្ធពាណិជ្ជកម្ម Online ក្រោមកម្មវិធីឈ្មោះ MYROL ដើម្បីឲ្យកសិករកៅស៊ូគ្រួសារទទួលបាននូវអំណាចចរចារថ្លៃនៅពេលសហករណ៍កៅស៊ូគ្រួសារទទួលបានព័ត៌-មានផ្សព្វផ្សាយ Online
- គម្លាតរវាងតម្លៃ FOB និងតម្លៃមាត់ចម្ការនឹងមានទំហំតូច ក្នុងករណីដែលកសិករកៅស៊ូគ្រួសារបានបង្កើតជាសហករណ៍។ ខណៈពេលដែរតម្លៃលក់ធម្មតាមានគំលាតចាប់ពី១,២-១,៨រីងហ្គីត/គ.ក្រ នោះតម្លៃលក់នៅសហករណ៍កៅស៊ូគ្រួសារមានគម្លាតតែ១,១រីងហ្គីត/គ.ក្រ ចំពោះការលក់ដូរតាមប្រព័ន្ធពាណិជ្ជកម្ម MYROL កសិករកៅស៊ូគ្រួសារនឹងកំណត់តម្លៃគោលទាបបំផុតហើយអ្នកទិញណាដែលផ្តល់តម្លៃខ្ពស់ជាងគេនឹងទទួលបានជោគជ័យ
- ការលក់ដូរតាមរយៈសហករណ៍កសិករកៅស៊ូគ្រួសារនឹងទទួលផលវិជ្ជមាន៤ដូចខាងក្រោម៖
  - ✓ តម្លៃមាត់ចម្ការខ្ពស់ជាងពី ១០-២០រីងហ្គីត/គ.ក្រ បើធៀបនឹងការលក់ដូរធម្មតា
  - ✓ ប្រាក់ចំណូលទទួលបានខ្ពស់ជាងពី ៣០-៧៥រីងហ្គីត/ហិកតា បើធៀបនឹងការលក់ដូរធម្មតា
  - ✓ បរិមាណពាណិជ្ជកម្មកើនឡើងច្រើន

តាមរយៈការចងក្រងជាសហករណ៍
- ✓ ឈ្មួញដែលនៅជិតនឹងបង្ខំចិត្តផ្តល់តម្លៃស្មើនឹងតម្លៃដែលសហករណ៍កសិកកៅស៊ូគ្រួសារផ្តល់។

## V- ប្រទេសឥណ្ឌូនេស៊ី

- ស្ថិតិឧស្សាហកម្មប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ២០១៧ រួមមានៈ
  - ✓ កសិករកៅស៊ូគ្រួសារចំនួន២,៥លានគ្រួសារ
  - ✓ ផ្ទៃដីកៅស៊ូសរុបចំនួន៣,៦៥៩លានហិកតា
  - ✓ ផលិតកម្មកៅស៊ូធម្មជាតិចំនួន៣,៦២៩លានតោន
  - ✓ ទិន្នផលជាមធ្យមចំនួន១ ១៨៨គ.ក្រ/ហិកតា
  - ✓ ពាណិជ្ជករអ្នកនាំចេញចំនួន២០ និងអ្នកកែច្នៃចំនួន១៥១
  - ✓ រោងចក្រកែច្នៃសំបកកង់យានយន្តចំនួន១៤
- វត្ថុធាតុដើមកៅស៊ូពីកៅស៊ូគ្រួសារបានឆ្លងកាត់តាមរយៈពាណិជ្ជករថ្នាក់ភូមិ និងថ្នាក់ស្រុកមុននឹងទៅដល់រោងចក្រកែច្នៃ។ កសិករកៅស៊ូគ្រួសារទទួលបានតម្លៃតែ ៦០ %នៃតម្លៃ FOB តែប៉ុណ្ណោះដោយសារការលក់ពាក់ព័ន្ធជាមួយឈ្មួញកណ្តាលដ៏ច្រើននិងមានខ្សែច្រវ៉ាក់ផ្គង់ផ្គង់វែងពេក
- ស្ថាប័នសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍនិងការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនៅក្នុងឧស្សាហកម្មកៅស៊ូគឺស្ថិតក្នុងដែនសមត្ថកិច្ចនៃក្រសួងកសិកម្ម ក្រសួងពាណិជ្ជកម្មនិងក្រសួងឧស្សាហកម្ម
- ឥណ្ឌូនេស៊ីអនុញ្ញាតឲ្យមានអ្នកវិនិយោគបរទេសទៅលើការកែច្នៃកៅស៊ូតាមលក្ខខណ្ឌៈ
  - ✓ កម្មសិទ្ធិភាពនៃវិនិយោគិនបរទេសអតិបរមាត្រឹម៩៥%
  - ✓ យ៉ាងតិច២០% នៃវត្ថុធាតុដើមសម្រាប់ការកែច្នៃត្រូវមានប្រភពពីចម្ការផ្ទាល់ខ្លួន
- វិនិយោគិនបរទេសក្នុងវិស័យសិប្បកម្មកែច្នៃកៅស៊ូសរុបចំនួន៥៩ ចាប់ពីឆ្នាំ ២០១២-២០១៦
- រដ្ឋាភិបាលឥណ្ឌូនេស៊ីកំពុងពិចារណាយ៉ាងយកចិត្តទុកដាក់អំពីទស្សនៈវិស័យផ្តល់កម្ចីទន់សម្រាប់កសិករកៅស៊ូគ្រួសារចំពោះការដាំឡើងវិញនិងការប្តូរមុខដំណាំ។ ប្រសិនបើប្រទេសឥណ្ឌូនេស៊ីមិនបានប្រមូលពន្ធនាំចេញខ្លះឬពន្ធការប្រើប្រាស់កៅស៊ូធម្មជាតិក្នុងស្រុក រដ្ឋាភិបាលនឹងខ្វះថវិកាបែងចែកដល់ការគាំទ្រកម្មវិធីអភិវឌ្ឍកៅស៊ូ
- ក្នុងឆ្នាំ២០១៦ ផ្ទៃដីចៀរមានចំនួន៣០០ ០០០ហិកតា និង៣៦០ ០០០ហិកតា នៅឆ្នាំ២០១៧ ហើយរដ្ឋាភិបាលកំពុងផ្តោតការយកចិត្តទុកដាក់លើការដាំឡើងវិញនៅឆ្នាំ២០១៨ ដូចនេះផ្ទៃដីចៀរនឹងមានចំនួនតែ២៩០ ០០០ហិកតាប៉ុណ្ណោះ។

### vi- ប្រទេសហ្វីលីពីន

- ស្ថិតិឧស្សាហកម្មប្រទេសហ្វីលីពីនក្នុងឆ្នាំ ២០១៧ រួមមាន៖
  - ✓ កសិករកៅស៊ូគ្រួសារចំនួន៥៩ ១៦១ គ្រួសារ និងមានច្បារពូជចំនួន៣២
  - ✓ ២៤សហករណ៍ផលិត ៦០សហករណ៍ជំនួញ និង ១១៣សមាគម
  - ✓ ពាណិជ្ជករអ្នកនាំចេញចំនួន៨៦ និងអ្នកកែច្នៃចំនួន៤១
- វត្ថុធាតុដើមពីកៅស៊ូគ្រួសារភាគច្រើនជាប្រភេទជ័រចានលក់ទៅឲ្យភ្នាក់ងារទិញរបស់មជ្ឈមណ្ឌលជំនួញទើបបន្តទៅដល់ឈ្មួញប្រមូលទិញ និងបន្តទៅរោងចក្រកែច្នៃរួចទើបនាំចេញឬលក់ឲ្យទីផ្សារក្នុងស្រុក
- តម្លៃលក់ជ័រចានប្រែប្រួលផ្សេងៗគ្នា បើលក់ឲ្យភ្នាក់ងារទិញមានតម្លៃចាប់ពី២៧-៣០ប៉េសូ/គ.ក្រ បើលក់ឲ្យមជ្ឈមណ្ឌលជំនួញមានតម្លៃចាប់ពី២៨-៣១ប៉េសូ/គ.ក្រ បើលក់ឲ្យផ្ទាល់ដល់រោងចក្រកែច្នៃមានតម្លៃចាប់ពី២៩-៣១ ប៉េសូ/គ.ក្រ
- សកម្មភាពសំខាន់ៗ ដែលរដ្ឋាភិបាលបានអនុវត្តដើម្បីបង្រួមខ្សែច្រវ៉ាក់ផ្គត់ផ្គង់មាន៖
  - ✓ បង្កើតមជ្ឈមណ្ឌលជំនួញនិងដេញថ្លៃកៅស៊ូចំនួន៥៨កន្លែង នៅតាមតំបន់ដាំដុះសំខាន់ៗ
  - ✓ សម្របសម្រួលឲ្យមានជំនួបប្រជុំជាទៀងទាត់រវាងកសិករ អ្នកកែច្នៃ និងពាណិជ្ជករសំខាន់ៗដើម្បីកាត់បន្ថយឈ្មួញកណ្តាល
  - ✓ ផ្សព្វផ្សាយព័ត៌មានទីផ្សារទាន់ហេតុការណ៍តាមរយៈមជ្ឈមណ្ឌលព័ត៌មាន
  - ✓ រៀបចំជាទៀងទាត់សិក្ខាសាលាស្តីអំពីប្រព័ន្ធបញ្ជៀតចូលក្នុងទីផ្សារ
  - ✓ រៀបចំឲ្យមានទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលជំនួញកៅស៊ូដែលជោគជ័យដើម្បីពង្រីកបន្ថែមនៅតំបន់ដទៃ
  - ✓ ដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងតម្លៃកៅស៊ូ (Rubber Price Management System: RPMS) នៅគ្រប់មជ្ឈមណ្ឌល ដើម្បីទប់ស្កាត់ការកេងតម្លៃដល់កសិករ
- កត្តាសំខាន់ៗដែលរារាំងដល់កសិករមាន៖
  - ✓ ពុំមានប្រភពចំណូលផ្សេងមកជំនួសក្រៅពីកៅស៊ូ
  - ✓ កង្វះទុនវិនិយោគហេដ្ឋារចនាសម្ព័ន្ធកែច្នៃ និងឃ្លាំងស្តុកនៅថ្នាក់ភូមិ
  - ✓ តម្រូវការបំពេញជាកាតព្វកិច្ចរបស់កសិករដោយសារតែទទួលប្រាក់ជាមុនពីឈ្មួញកណ្តាល
- ក្រុមហ៊ុនកែច្នៃគ្រប់ប្រភេទត្រូវតែមានវិញ្ញាបនបត្របរិស្ថាន ECC (Environmental Compliance Certificate) ដែលត្រួតពិនិត្យលើការបំពុលទឹក និងសំណល់ពីរោងចក្រ
- រដ្ឋាភិបាលហ្វីលីពីនត្រូវការវិនិយោគិនបរទេសលើវិស័យកៅស៊ូ។ យោងតាមច្បាប់វិនិយោគិនបរទេសអាចជួលដីទំហំ១០០០ហិកតាសម្រាប់រយៈពេល៥០ឆ្នាំ និងអាចបន្ត២៥ឆ្នាំបន្ថែមទៀត

- រហូតមកដល់បច្ចុប្បន្ន មានអ្នកវិនិយោគិនបរទេសចំនួន២៤ ក្នុងនោះ ២០មកពីជប៉ុន ៣មកពីកូរ៉េ និង១មកពីម៉ាឡេស៊ីកំពុងតែវិនិយោគលើការកែច្នៃនិងការផលិតផលិតផលសម្រេចពីកៅស៊ូ។

## vii- ប្រទេសបង់ក្លាដែស

- ស្ថិតិឧស្សាហកម្មកៅស៊ូធម្មជាតិរបស់ប្រទេសបង់ក្លាដែសក្នុងឆ្នាំ២០១៧ រួមមាន៖
  - ✓ កៅស៊ូគ្រួសារចំនួន៥ ២០៤គ្រួសារ ក្នុងនោះ៣ ៣៩២គ្រួសារ មានផ្ទៃដីតិចជាង ១០ហិកតា
  - ✓ ពាណិជ្ជករកៅស៊ូចំនួន១៣
  - ✓ រោងចក្រកែច្នៃកៅស៊ូដុំជ័រខាប់ និងកៅស៊ូសន្លឹកចំនួន៧០
  - ✓ ក្រុមកសិករកៅស៊ូគ្រួសារដែលមានលទ្ធភាពកែច្នៃនិងធ្វើពាណិជ្ជកម្មចំនួន២៧
  - ✓ រោងចក្រផលិតផលកៅស៊ូចំនួន១២០ (រោងចក្រផលិតសំបង់កង់យានយន្តមានចំនួន១៤)
- ការកែច្នៃគឺជាស្នូលក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់នៃវិស័យកៅស៊ូធម្មជាតិបង់ក្លាដែសរួមមាន៖
  - ✓ ការផ្គត់ផ្គង់ធាតុចូលទៅឲ្យកសិករកៅស៊ូគ្រួសារ ដូចជាពូជកៅស៊ូ ដី និងថ្នាំការពារសត្វល្អិតជាដើម
  - ✓ ការផ្តល់បច្ចេកទេសដាំដុះកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
  - ✓ ការចៀរជ័រនិងការកែច្នៃកៅស៊ូសន្លឹកតាមកម្រិតចម្ការ
  - ✓ ការប្រមូលផលិតផលរបស់កសិករកៅស៊ូគ្រួសារដោយពាណិជ្ជករកម្រិតបឋមនិងនាំចេញផ្ទាល់ទៅឲ្យរោងចក្រកែច្នៃ
  - ✓ ការកែច្នៃផលិតផលបឋមរបស់រោងចក្ររួមមាន៖ កៅស៊ូសន្លឹក ជ័រខាប់ និងកៅស៊ូដុំ
  - ✓ ការផ្តល់ម៉ាកសញ្ញា ស្លាកសញ្ញា និងយុទ្ធសាស្រ្តទីផ្សារនៃកៅស៊ូកែច្នៃ
- កសិករកៅស៊ូគ្រួសារបានទទួលតម្លៃប្រហែល៧៥% នៃតម្លៃទីផ្សារ
- ខ្សែច្រវ៉ាក់ផ្គត់ផ្គង់នៃឧស្សាហកម្មកៅស៊ូបង់ក្លាដែសមិនមានក្នុងសណ្ឋានដូចគ្នាទេ អាស្រ័យដោយភាពខុសគ្នានៃទំហំដី។ ក្នុងចំណោមកៅស៊ូគ្រួសារសរុបចំនួន៥ ២០៤ គ្រួសារ ចំនួន៣ ៣៩២គ្រួសារមានផ្ទៃដីតិចជាង១០ហិកតា/គ្រួសារ និងក៏មានកសិករកៅស៊ូគ្រួសារដែលមានផ្ទៃដីត្រឹមតែពី១-២ ហិកតាប៉ុណ្ណោះ ដូច្នេះពួកគាត់ត្រូវតែលក់ទឹកជ័រទៅឲ្យឈ្មួញកណ្តាលក្នុងស្រុក
- មានស្ត្រី២០% ជាម្ចាស់រោងចក្រកែច្នៃនិង ២%ប៉ុណ្ណោះជាឈ្មួញកៅស៊ូ
- រោងចក្រកែច្នៃដែលគ្រប់គ្រងដោយរដ្ឋនិងវិស័យឯកជនមិនមានបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មសំណល់ទេ (Effluent Treatment System) ប៉ុន្តែរោងចក្រកែច្នៃទាំងនោះបានផ្តល់សេវានេះទៅឲ្យក្រុមហ៊ុនឯកជនមួយទៀតគ្រប់គ្រងលើសំណប់រោងចក្ររបស់ពួកគេដូច-ជាក្រុមហ៊ុន Duncan Brothers និងក្រុម

ហ៊ុន James Finley ដែលមានរោងចក្រប្រព្រឹត្តិកម្មសំណល់

- ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសបង់ក្លាដែសកំពុងជំរុញវិនិយោគិនបរទេសក្នុងការដាំដុះកៅស៊ូ ការកែច្នៃ ការធ្វើពាណិជ្ជកម្ម និងបើករោងចក្រកែច្នៃផលិតផលសម្រេច ដែលបច្ចុប្បន្នវិនិយោគិនបរទេសបានអវត្តមានក្នុងការធ្វើពាណិជ្ជកម្មនិងការកែច្នៃ។ រោងចក្រកែច្នៃផលិតផលសម្រេចដែលគ្រប់គ្រង់ដោយវិនិយោគិនបរទេសក្នុងប្រទេសបង់ក្លាដែសមានប្រហែល៤%ប៉ុណ្ណោះ។

### viii- ប្រទេសឥណ្ឌា

- បានដាំដុះនៅតំបន់ប្រពៃណីប្រមាណ ៧៦% នៃផ្ទៃដីដាំដុះសរុប
- ក្រុមប្រឹក្សាកៅស៊ូគឺជាសេនាធិការរបស់រដ្ឋាភិបាលតែមួយគត់ដែលអនុវត្តច្បាប់លិខិតបទដ្ឋានគតិយុត្តនិងការអភិវឌ្ឍន៍សម្រាប់វិស័យកៅស៊ូឥណ្ឌា ដែលគ្រប់ដណ្តប់លើខ្សែច្រវ៉ាក់ផ្គត់ផ្គង់គិតចាប់ពីចម្ការរហូតដល់រោងចក្រឧស្សាហកម្ម
- ក្នុងឆ្នាំ២០១៧ ផ្ទៃដីកៅស៊ូសរុបចំនួន ៨២២ ០០០ហិកតា។ កៅស៊ូគ្រួសារមានចំនួន១,២៩លានគ្រួសារ និងក្រុមហ៊ុនចំនួន៥៣៧។ ចម្ការកៅស៊ូគ្រួសារមាន ៩១% នៃផ្ទៃដីសរុប និង ៩២%នៃផលិតកម្មសរុប។ ចាត់ទុកជាចម្ការកៅស៊ូគ្រួសារគឺមានផ្ទៃដីកៅស៊ូតិចជាង១០ហិកតា ក្នុងនោះកសិករកៅស៊ូគ្រួសារ៩៨%មានផ្ទៃដីតិចជាង២ហិកតា
- ស្ថិតិសង្ខេបអំពីចំណាត់ថ្នាក់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់នៃឧស្សាហកម្មកៅស៊ូឥណ្ឌានៅក្នុងឆ្នាំ ២០១៧មានដូចខាងក្រោម៖
  - ✓ ពាណិជ្ជករចំនួន៨ ២៥២
  - ✓ អ្នកកែច្នៃចំនួន១១៦
  - ✓ រោងចក្រកែច្នៃផលិតផលសម្រេចចំនួន ៤ ៣០៧
  - ✓ សហគមន៍កែច្នៃនិងពាណិជ្ជកម្មចំនួន ២៦៥
  - ✓ ក្រុមដែលមានដំណើរការដោយខ្លួនឯងស្ថិតក្នុងក្រុមគោលការណ៍ RPS ចំនួន ១ ៩៧៧
  - ✓ ក្រុមហ៊ុនសហទុនកែច្នៃនិងពាណិជ្ជកម្មគ្រប់គ្រងដោយគោលការណ៍ RPS និងក្រុមប្រឹក្សាកៅស៊ូចំនួន១៨
- ចំពោះតំបន់ប្រពៃណីកសិករកៅស៊ូគ្រួសារអាចទទួលបានតម្លៃមាត់ចម្ការប្រហែល ៩០% នៃតម្លៃទីផ្សារអន្តរកាល។ ចំណែកតំបន់មិនប្រពៃណីទទួលបានតម្លៃមាត់ចម្ការត្រឹមតែ៨០% នៃតម្លៃទីផ្សារអន្តរកាល។ នៅពេលដែលផលិតផលកម្មកៅស៊ូធម្មជាតិឥណ្ឌាលក់បានទៅឲ្យអ្នកប្រើប្រាស់ក្នុងស្រុកតម្លៃកៅស៊ូធម្មជាតិ ដែលទទួលបានគឺជាតម្លៃអន្តរកាល ដូចទៅនឹរោងចក្រកែច្នៃផលិតផលសម្រេចបានទិញកៅស៊ូធម្មជាតិចេញពីទីផ្សារក្នុងស្រុក
- កត្តាវិជ្ជមានមួយចំនួនបានជំរុញឲ្យតំបន់

ប្រព៌ណីទទួលបានតម្លៃមាត់ចម្ការខ្ពស់ រួមមាន៖

- ✓ កសិករកៅស៊ូគ្រួសារប្រមាណជា ៧០% តផលទៅជាកៅស៊ូសន្លឹកបានកែច្នៃផលិសម្ងួតដោយផ្សែង (RSS- Ribbed Smoked Sheet)។ កៅស៊ូសន្លឹកអាចទុកនៅក្នុងស្តុកបានរយៈពេលយូរអង្វែងជាជាងការលក់ដោយសោកស្តាយ ដូច្នេះកសិករអាចបង្កើតឱកាសចរចារដើម្បីទទួលបាន
- ✓ ការទទួលបានព័ត៌មានទីផ្សារពិតប្រាកដសូម្បីតែថ្នាក់កម្រិតភូមិ
- ✓ កម្រិតខ្ពស់នៃចំណេះដឹងកសិករកៅស៊ូគ្រួសារដែលផ្តល់ដោយបណ្តាញទំនាក់ទំនងតំបន់ល្អ
- ✓ ពាណិជ្ជករជាង៨ ០០០នាក់ ចូលរួមត្រេកអរប្រកួតប្រជែងទីផ្សាតាមឋានានុក្រម
- ✓ ការចូលរួមពីក្រុមកសិករកៅស៊ូគ្រួសារ និងសហគមន៍កៅស៊ូគ្រួសារក្នុងពាណិជ្ជកម្មកៅស៊ូនៅតាមថ្នាក់កម្រិតភូមិ

- កត្តាដែលជំរុញឲ្យកសិករកៅស៊ូគ្រួសារលក់ដោយមិនស្តុកទុករួមមាន៖
  - ✓ ការធ្លាក់ចុះនៃសេដ្ឋកិច្ចអាចធ្វើឲ្យកសិករកៅស៊ូគ្រួសារស្តុកទុករយៈពេលយូរខ្លាំង
  - ✓ កង្វះខាតកន្លែងស្តុក
  - ✓ ហានិភ័យនៃគុណភាពដែលកាន់តែថយទៅៗប្រសិនបើស្តុករយៈពេលយូរ ជាពិសេសអំឡុងពេលដែលមានអាកាសធាតុមិនអំណោយផល
  - ✓ ហានិភ័យដែលកើតឡើងដែលធ្វើឲ្យតម្លៃចុះទាប
- ការវិនិយោគបរទេស បានអនុញ្ញាតឲ្យវិនិយោគជាចម្ការកៅស៊ូ និងជារោងចក្រផលិតផលិតផល
- ប្រទេសឥណ្ឌាតម្រូវឲ្យមានប្រព័ន្ធប្រព្រឹត្តិកម្មកាកសំណល់សម្រាប់សិប្បកម្មកែច្នៃខ្នាតធំនិងរោងចក្រ។ មជ្ឈមណ្ឌលក្រុមសិប្បកម្មកែច្នៃដែលចងក្រងដោយសមាគមអ្នកកែច្នៃកៅស៊ូបានរួមគ្នាបង្កើតជាប្រព័ន្ធប្រព្រឹត្តិកម្មសំណល់
- កសិកកៅស៊ូគ្រួសារប្រមាណ៤៥០លានគ្រួសារដែលជាប្រជាពលរដ្ឋក្នុងរដ្ឋបាលខេត្ត Kerala បានចុះឈ្មោះចូលរួមក្រោមការអនុវត្តន៍គម្រោងកម្មវិធីស្តីអំពីការជំរុញផលិតកម្មកៅស៊ូ។ គម្រោងនេះនឹងគ្រោងធានាតម្លៃកៅស៊ូ RSS-4 ដែលផលិតដោយកសិករកៅស៊ូគ្រួសារក្នុងតម្លៃ១៥០រូពី/គ.ក្រ រដ្ឋាភិបាលឥណ្ឌា នឹងចាប់ផ្តើមដំណើរការគម្រោងនេះក្នុងទិដ្ឋភាពមួយធានាលើប្រាក់ចំណូលកសិករដែលប្រកបអាជីវកម្មកៅស៊ូ។

## ix- ប្រទេសស្រីលង្កា

- ស្ថិតិឧស្សាហកម្មកៅស៊ូស្រីលង្កានៅក្នុងឆ្នាំ២០១៧ រួមមាន៖
  - ✓ ផ្ទៃដីកៅស៊ូសរុប ១៣៦ ០០០ហិកតា
  - ✓ កសិករកៅស៊ូគ្រួសារចំនួន១៣៩ ០០០ គ្រួសារ

- ✓ ក្រុមកសិករកៅស៊ូគ្រួសារចំនួន៨៣១
- ✓ ទិន្នផលកៅស៊ូធម្មជាតិប្រចាំឆ្នាំ៨៣ ០០០ តោន/ឆ្នាំ(៦៥% នៃទិន្នផលកសិករកៅស៊ូគ្រួសារ)
- ✓ ពាណិជ្ជករចំនួន៧៩០
- ✓ រោងចក្រ-សិប្បកម្មកែច្នៃ៖ ជ័រខាប់១៨ ជ័រដុំ៥ និងកៅស៊ូសន្លឹក១៩
- ✓ សហគមន៍កែច្នៃពាណិជ្ជកម្ម២០ និងកែច្នៃ១ពាណិជ្ជកម្ម
- ✓ រោងចក្រកែច្នៃផលិតផល៨៨ ក្នុងនោះ ១៩រោងចក្រផលិតសំបកកង់យានយន្ត
- ✓ ទិន្នផលនាំចូល ៦១ ៨០០តោន
- ✓ ទិន្នផលនាំចេញ ១៧ ២០០តោន

- ទិន្នផលកសិករកៅស៊ូគ្រួសារមាន៦៥% នៃទិន្នផលកៅស៊ូសរុបត្រូវបានលក់ឲ្យទីផ្សារក្នុងស្រុកសម្រាប់ការប្រើប្រាស់របស់រោងចក្រកែច្នៃផលិតផលសម្រេច
- វត្ថុធាតុដើមកៅស៊ូផលិតដោយកសិករកៅស៊ូគ្រួសារបានលក់ទៅឲ្យឈ្មួលនៅក្នុងភូមិ អ្នកប្រមូលទិញចល័ត ឈ្មួលទីក្រុងឈ្មួញកណ្ដាល និងមជ្ឈមណ្ឌលដេញថ្លៃមុននឹងទៅដល់រោងចក្រកែច្នៃផលិតផលសម្រេចឬអ្នកនាំចេញ
- ចំពោះក្រុមហ៊ុនចម្ការកៅស៊ូឯកជនមាន ៣៥% នៃកៅស៊ូសរុប។ លក្ខណៈនៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុនចម្ការកៅស៊ូឯកជនគឺមានទម្រង់ខ្លីដោយសារតែពួកគេអាចកែច្នៃផលិតផលទៅជាផលិតផលពាណិជ្ជកម្មនាំចេញ ឬលក់ទៅឲ្យរោងចក្រផលិតផលសម្រេចតាមរយៈមជ្ឈមណ្ឌលដេញថ្លៃ។ ទិន្នផលក្រុមហ៊ុនចម្ការកៅស៊ូឯកជន៨០% ត្រូវបាននាំចេញ និងលក់ទៅឲ្យទីផ្សារក្នុងស្រុកដើម្បីសមតុល្យភាព
- ស្ថាប័នសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍនិងរៀបចំលិខិតបទដ្ឋានគតិយុត្តឧស្សាហកម្មកៅស៊ូស្រីលង្ការួមមាន៖ នាយកដ្ឋានអភិវឌ្ឍកៅស៊ូ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូស្រីលង្កា និងមូលនិធិ Thurasaviya ដែលស្ថិតនៅក្រោមក្រសួងដំណាំឧស្សាហកម្ម។ នាយកដ្ឋានអភិវឌ្ឍកៅស៊ូយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យកៅស៊ូដោយវិធីសាស្ត្រកំណត់អត្តសញ្ញាណនិងជំរុញប្រកបដោយចីរភាពចំពោះការធ្វើឲ្យប្រសើរឡើងលើដំណាំកៅស៊ូ។ ជាមួយគ្នានេះនាយកដ្ឋានអភិវឌ្ឍកៅស៊ូក៏ទទួលខុសត្រូវការផ្ដល់កម្មសិទ្ធិបញ្ញាដល់ពាណិជ្ជករកៅស៊ូ។ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូស្រីលង្កាផ្ដល់សេវាស្រាវជ្រាវនិងអភិវឌ្ឍ។ មូលនិធិ Thurasaviya ទទួលខុសត្រូវផ្នែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមលើកសិករកៅស៊ូគ្រួសារបំពាក់រោងចក្រកែច្នៃផលិតផលខ្នាតតូចនិងដាក់ចេញយុទ្ធសាស្ត្រទីផ្សារផលិតផល
- សមាគមកសិករកៅស៊ូដែលស្ថិតនៅក្រោមមូនិធិ Thurasaviya បានប្រមូលផលិតផលកៅស៊ូ RSS ដែលផ្គត់ផ្គង់ពីសមាជិករួចលក់ទៅឲ្យរោងចក្រ។ ប្រព័ន្ធនេះកាត់

បន្ថយឈ្មួញកណ្តាលនិងជំរុញឲ្យកសិករកៅស៊ូគ្រួសារទទួលបានតម្លៃមាត់ចម្ការបន្ថែម៧% បើធៀបទៅនឹងការលក់បែបប្រពៃណី

- នៅពេលតម្លៃកៅស៊ូមិនច្បាស់លាស់ កសិករកៅស៊ូគ្រួសារកប្រែនឹងស្តុកកៅស៊ូ។ យ៉ាងណាក៏ដោយ កសិករកៅស៊ូគ្រួសារដែលស្តុកកៅស៊ូមានចំនួនមធ្យមដែលជាទូទៅអាចស្តុកទុកទិន្នផលកៅស៊ូបាន ២៩%។ ចំណែកហ៊ុនណាដែលមានផ្ទៃដីកៅស៊ូធំជាង២ហិកតា បង្ហាញក្នុងតារាងខាងក្រោម៖

**តារាងបែងចែកចំណែកហ៊ុនទៅតាមលក្ខខណ្ឌផ្ទៃដី**

| ទំហំផ្ទៃដី | ចំនួនចំណែកហ៊ុន | ផ្ទៃដីសរុប (ហិកតា) | % នៃហ៊ុនទទួលបាន (ហិកតា) |
|---|---|---|---|
| តិចជាង២ហិកតា | 122 474 | 56 446 | 71 |
| ធំឬស្មើ២ហិកតា | 4 618 | 22 949 | 29 |
| **សរុប** | **127 092** | **79 395** | **100** |

- ចំនួនក្រុមកសិករកៅស៊ូគ្រួសារចំនួន២១ ក្រុមបានដំណើរប្រតិបត្តិការក្នុងស្រុក ក្នុងនោះ២០ក្រុម ផ្តោតលើការកែច្នៃកៅស៊ូ និង១ក្រុមទៀតផ្តោតលើតែពាណិជ្ជកម្ម
- គ្រប់សិប្បកម្មកែច្នៃកៅស៊ូនិងរោងចក្រកែ-ច្នៃកៅស៊ូត្រូវមានប្រព័ន្ធកែច្នៃកាកសំណល់ដែលអនុញ្ញាតពីអាជ្ញាធរបរិស្ថានកណ្តាល ដើម្បីត្រួតពិនិត្យសារធាតុពុល និងការប្រើប្រាស់ទឹកនិងថាមពល
- ការចូលរួមរបស់ស្ត្រីក្នុងវិស័យឧស្សាហ-កម្មកៅស៊ូដែលមានក្នុងតារាងបែងចែកកៅស៊ូជាភាគរយ បើយោងតាមសមភាពយេនឌ័រ៖

| ភេទ | ចំនួនកសិករ | % |
|---|---|---|
| ប្រុស | 94 402 | 74 |
| ស្រី | 30 837 | 24 |
| មិនច្បាស់លាស់ | 1 853 | 2 |
| **សរុប** | **127 092** | **100** |

- ការវិនិយោគបរទេស ត្រូវបានអនុញ្ញាតឲ្យវិនិយោគក្នុងវិស័យកៅស៊ូ ដូចជា៖ បង្កើតចម្ការ ការកែច្នៃ និងរោងចក្រ។ បច្ចុប្បន្ននេះ ក្រុមហ៊ុនបរទេសបាននិងកំពុងដំណើរការរោងចក្រផលិតផលិតផលពីកៅស៊ូនៅក្នុងក្នុងប្រទេស។ រដ្ឋាភិបាលស្រីលង្កា ធ្លាប់បានអនុវត្តនកម្មវិធីធានាតម្លៃ(ឧបត្ថម្ភធន) ដើម្បីគាំទ្រកសិករកៅស៊ូគ្រួសារក្នុងស្រុក ចាប់ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២១០៥ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។

## ៣. ទស្សនកិច្ចសិក្សា

សិក្ខាកាមទាំងអស់បានចូលរួមធ្វើទស្សនកិច្ចសិក្សាស្វែងយល់បន្ថែមនិងផ្លាស់ប្តូរបទពិសោធអំពីទីផ្សារកៅស៊ូរួម (Central Rubber Market) នៅខេត្តសុងក្លាទីផ្សារទិញទឹកជ័រកៅស៊ូរបស់សហការ Ban Na Prang ក្នុងស្រុក Natawee និងរោងចក្រផលិតកៅស៊ូសន្លឹក RSS តាមប្រព័ន្ធ GMP (Good manufacturing Practices)។

### ៣.១ ទស្សនកិច្ចសិក្សានៅទីផ្សារកៅស៊ូរួមខេត្តសុងក្លា (SongklaCentral Rubber Market)

- ទីផ្សារកៅស៊ូរួមសុងក្លា ជាទីផ្សារទី១ បង្កើត

ឡើងនៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៩១ ស្ថិតក្នុងស្រុក Hatyai ខេត្ត Songkhla ប្រទេសថៃ។

- មកទល់នឹងបច្ចុប្បន្ន មានទីផ្សារកៅស៊ូរួម CRM (Central Rubber Market) ចំនួន៦កន្លែង ស្ថិតក្នុងខេត្ត Nongkhai Burirum Suratthani Nakon Sri Thammarat Songkhla និងខេត្ត Yala។

- ភារកិច្ចនិងទំនួលខុសត្រូវនៅទីផ្សារកៅស៊ូរួមសុងក្លារួមមាន៖(១)ការធ្វើសេវាកម្មទីផ្សារកៅស៊ូ (២)ការស្រាវជ្រាវសេដ្ឋកិច្ចកៅស៊ូ (៣)ការវិភាគស្ថានភាពកៅស៊ូ (៤)ការផ្តល់ព័ត៌មានកៅស៊ូ និង (៥)សេវាកម្មឃ្លាំងស្តុក។

**ការធ្វើសេវាកម្មទីផ្សារកៅស៊ូ៖** ចែកចេញជា៤ផ្នែក គឺទីផ្សារទិញ-លក់ភ្លាមៗ ទីផ្សារបណ្តាញទី-ផ្សារបញ្ជូនបន្តនិងទីផ្សារទឹកជ័រ។

➢ <u>ទីផ្សារទិញ-លក់ភ្លាមៗ</u>

\+ គោលការណ៍៖ ពេលវេលាធ្វើការចាប់ពីម៉ោង៧:៣០-៤:៣០ ទទួលតែជ័រកៅស៊ូប្រភេទ USS និង RSS មានបរិមាណចាប់ពី២០០-៣០០តោន/ថ្ងៃ តម្លៃតាមរយៈការដេញថ្លៃនៅក្នុងទីផ្សារកៅស៊ូរួម

\+ នីតិវិធី៖ ម្ចាស់ផលិតផលទាំងអស់ត្រូវមានឈ្មោះក្នុងបញ្ជីផលិតផលត្រូវបានចាត់ថ្នាក់តាមគុណភាព ថ្លឹងទម្ងន់ ធ្វើការដេញថ្លៃ អ្នកទិញបង់ប្រាក់ចូលបេឡា ទីផ្សារកៅស៊ូរួមបង្វែរប្រាក់ចូលគណនីនៅធនាគារជូនអ្នកលក់ដឹកជញ្ជូនផលិតផលអោយអ្នកទិញ

➢ <u>**ទីផ្សារបណ្តាញ**</u>

\+ លក្ខណៈសម្បត្តិ៖ ក្រុមកសិករ ឬសហគមន៍បញ្ជាក់ដោយអាជ្ញាធរកៅស៊ូថៃ ការធ្វើអធិការកិច្ច (ត្រួតពិនិត្យ) សម្រេចយល់ព្រមពីដោយអាជ្ញាធរកៅស៊ូថៃ

\+ នីតិវិធី៖ គ្រប់គ្រងដោយក្រុមកសិករឬសហ-គមន៍ផ្តល់ព័ត៌មានអំពីបរិមាណទៅអោយទីផ្សារកៅស៊ូរួមទិញ-លក់តាមរយៈតម្លៃដេញថ្លៃដូចជាទីផ្សារទិញ-លក់ភ្លាមៗ ការទូទាត់តាមគណនីនៅធនាគារដឹកជញ្ជូនអោយអ្នកទិញ/រោងចក្រ។

➢ <u>**ទីផ្សារបញ្ជូនបន្ត**</u>

\+ គោលការណ៍៖ កំណត់ប្រភេទជ័រ RSS 3 ពេលវេលាដេញថ្លៃ(១៣:០០-១៤:៣០)ពេលវេលាផ្តល់បរិមាណផលិតផល(១៤:៣០-១៦:០០) រយៈពេលផុតកំណត់ត្រឹម៧ថ្ងៃ

\+ លក្ខណៈសម្បត្តិអ្នកលក់៖ ជាសមាជិករបស់ទីផ្សារកៅស៊ូរួម មានឡចំហុយផ្ទាល់ខ្លួនមានការត្រួតពិនិត្យបានយល់ព្រមពីទីផ្សារកៅស៊ូរួម បរិមាណកំណត់ដោយទីផ្សារកៅស៊ូរួម

\+ នីតិវិធីដេញថ្លៃ៖ អ្នកទិញដាក់តម្លៃនៅ CRM បន្ទាប់មក CRM ប្រកាសតម្លៃទៅអ្នកលក់។ អ្នកលក់ផ្តល់បរិមាណជ័រទៅCRMរួចបញ្ជាក់បរិមាណជ័រទៅអ្នកទិញទើបឈានដល់ចុះកិច្ចសន្យារវាងអ្នកលក់និងអ្នកទិញ

\+ នីតិវិធីប្រគល់-ទទួល៖ អ្នកលក់ដឹកជញ្ជូនទៅកាន់ CRM អ្នកទិញទូទាត់ប្រាក់មក CRM ទើប CRMទូទាត់ប្រាក់ជូនអ្នកលក់ រួចដឹកជញ្ជូនទៅឲ្យអ្នកទិញ។

➢ <u>**ទីផ្សារទឹកជ័រ**</u>

\+ គោលការណ៍៖ ធានាតម្លៃផលិតតាម

ស្តង់ដារគុណភាពរបស់អាជ្ញាធរថៃ តម្លៃ និងបរិមាណចរចារគ្នា ការទូទាត់តាមគណនីនៅធនាគារ បើកប្រតិបត្តិការរាល់ថ្ងៃ

+នីតិវិធីៈនៅថ្ងៃដំបូង អ្នកលក់ផ្តល់បរិមាណជ័រដែលមានមកកាន់ CRM។ អ្នកទិញផ្តល់តម្លៃនិងបរិមាណជ័រត្រូវការមកកាន់ CRM ដោយធ្វើការចរ-ចារថ្លៃនិងបរិមាណជ័រនៅ CRM។ បន្ទាប់មក CRM បញ្ជាក់អំពីតម្លៃ និងបរិមាណជ័រទៅភាគីទាំង២ បន្ទាប់មកទៀតអ្នកលក់ដឹកជញ្ជូនទៅអោយអ្នកទិញ (រោងចក្រ)។ នៅថ្ងៃបន្ទាប់ អ្នកទិញផ្តល់ព័ត៌មានលម្អិតអំពី DRC ទម្ងន់ គុណភាពទៅ CRM អ្នកលក់ក៏ផ្តល់ព័ត៌មានលម្អិតមកCRM ដែរ បើព្រមព្រៀងគ្នា អ្នកទិញទូទាត់មកអោយ CRM រួចបង្វែរទូទាត់ជូនអ្នកលក់តាមគណនីនៅធនាគារ។

## ៣.២ ទស្សនកិច្ចសិក្សានៅទីផ្សារទឹកជ័រកៅស៊ូនៅសហករណ៍ Ban NaPrang ក្នុងស្រុក Natawee

កសិករម្នាក់ៗដឹកទឹកជ័រមកស្នាក់ការប្រមូលទិញដោយខ្លួនឯងផ្ទាល់។ បន្ទាប់មកភ្នាក់ងារសហ-ករណ៍ថ្លឹងទម្ងន់និងរក DRC ដោយដុតនឹង Microwave oven និងថ្លឹងដោយជញ្ជីង Electronic។ បន្ទាប់ពីដឹងទម្ងន់កៅស៊ូស្ងួតភ្នាក់ងារសហករណ៍គិតបរិមាណទឹកប្រាក់ដែលកសិករត្រូវទទួលបានទៅតាមតម្លៃដែលបានកំណត់រួចហើយ និង បង់ទូទាត់ដល់ដៃកសិករភ្លាមៗតែម្តង។

## ៣.៣ ទស្សនកិច្ចសិក្សារោងចក្រកែច្នៃកៅស៊ូសន្លឹក RSS ដោយអនុវត្ត GMP

- សហករណ៍មូលកៅស៊ូ Romjaikunaysung បានបង្កើតឡើងនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ស្ថិតក្នុងស្រុក Hatyai ខេត្ត Songkhla ប្រទេសថៃ។ រោងចក្រកែច្នៃ RSS អនុវត្តការផលិតល្អ RSS GMP) ដែលជាប្រព័ន្ធមួយមិនទាក់ទងផ្ទាល់ទៅនឹងការប្រើប្រាស់ទេ ប៉ុន្តែធានាថាផលិតផលនេះត្រូវបានផលិតនិងត្រួតពិនិត្យស្របតាមស្តង់ដារគុណភាពសុវត្ថិ-ភាពនិងបន្ថយហានីភ័យផលិកម្មកអោយតិចបំផុត។

- រោងចក្រ RSS GMP មានគោលការណ៍គន្លឹះ ៦ចំណុចៈ

+ ជ្រើសរើសទីតាំងបង្កើតរោងចក្រដែលមិនទទួលរងការខូចខាតនិងតំបន់គ្មានទឹកជំនន់

+ សម្ភារនិងបរិក្ខារត្រូវមានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ដើម្បីត្រៀមប្រតិបត្តិការ

+ ការកែច្នៃត្រូវអនុវត្តយ៉ាងម៉ត់ចត់តាមប្រព័ន្ធគុណភាព

+ បុគ្គលិកទាំងអស់ត្រូវយល់ដឹងនិងទទួលខុសត្រូវការងាររៀងៗខ្លួន

+ រៀបចំឃ្លាំងស្តុកប្រកបដោយសុវត្ថិភាព និងមានមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់

+ ត្រូវរក្សាអនាម័យស្អាតល្អនិងសុវត្ថិភាព

- រោងចក្រ RSS GMP ផលិតកៅស៊ូ RSS ២ ប្រភេទ គឺRSS ជាសន្លឹកនិង RSS ជាដុំ

- លក្ខណៈសម្បត្តិនៃប្រព័ន្ធអនុវត្តការផលិតល្អគឺៈ(១)ត្រួតពិនិត្យនិងបង្កើនគុណភាពផលិតផលទាំង២ប្រភេទ (២)ពង្រឹងនិងកសាងទំនុកចិត្តដល់អ្នកទិញនិងអ្នកប្រើប្រាស់លើទីផ្សារពិភពលោក និង (៣)កាត់បន្ថយថ្លៃដើមផលិតកម្មក្នុងការកែច្នៃ

- មកទល់នឹងបច្ចុប្បន្ននេះ អាជ្ញាធរកៅស៊ូថៃបានចេញវិញ្ញាបនប័ត្រអោយសហគមន៍មូលនិធិនិងឡចំហុយកៅស៊ូ RSS ចំនួន១២កន្លែង និងរោងចក្រកៅស៊ូដុំចំនួន២០កន្លែង ដោយការផលិតកៅស៊ូ RSS តាមស្តង់ដារអនុវត្តការផលិតល្អ (RSS GMP system) ដែលរំពឹងថានឹងបង្កើនកម្រិតគុណភាពល្អបំផុតដោយផ្ទាល់ខ្លួន។

- រោងចក្រ RSS GMP ក៏ដាក់គោលការណ៍៤ចំនុចដល់កសិករត្រូវអនុវត្តរួមមាន៖

+ ត្រូវចាប់ចៀរជ័រពីយប់

+ ត្រូវផ្គាប់ចានអោយបានត្រឹមត្រូវ

+ ត្រូវត្រងច្រោះទឹកជ័រនៅចម្ការ

+ ត្រូវដឹកជញ្ជូនទឹកជ័រមកដល់រោងចក្រមិនអោយហួសម៉ោង១១ព្រឹក។

ទន្ទឹមនឹងនោះ វត្ថុធាតុគីមីត្រូវរក្សាទុកនិងប្រើប្រាស់អោយបានត្រឹមត្រូវតាមការចាំបាច់។

## ៤. សន្និដ្ឋាន និងលទ្ធផលរួម

ជាសេចក្តីសន្និដ្ឋាន សិក្ខាសាលាស្តីអំពី "ឆ្ពោះទៅរកប្រសិទ្ធិភាពខ្សែច្រវ៉ាក់នៃការផ្គត់ផ្គង់" បានស្វែងយល់ ពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមកអំពីវិធានការនានាដែលបណ្តាប្រទេសជាសមាជិក ANRPC បានប្រកាន់យកដើម្បីសម្រាលឥទ្ធិពលអវិជ្ជមាននានា ដែលបង្ករផលប៉ះពាល់ជាពិសេសដល់កសិករកៅស៊ូគ្រួសារក្នុងពេលដែលតម្លៃកៅស៊ូធ្លាក់ថ្លៃ។ អង្គសិក្ខាសាលានេះបានចែករំលែកចំណេះដឹង គំនិតយោបល់ បទពិសោធន៍ និងទស្សនាទានដែលជាធាតុចូលសំខាន់ៗក្នុងការរៀបចំផែនការអភិវឌ្ឍន៍កៅស៊ូធម្មជាតិឲ្យកាន់តែរីកចម្រើនប្រកបដោយចីរភាព ជាពិសេសការរៀបចំបង្កើតមជ្ឈមណ្ឌលទីផ្សារកៅស៊ូរួមនៅតាមតំបន់ដាំដុះកៅស៊ូសំខាន់ៗនាពេលខាងមុខ។

ជាលទ្ធផលសំខាន់ៗពីកិច្ចប្រជុំនេះ រួមមាន៖

❖ ក្នុងឆ្នាំ២០១៨ផ្ទៃដីចៀរជ័រនៅក្នុងសមាគម ANRPC នឹងមានចំនួន៩,២៦៣លានហិកតា។ ក្នុងឆ្នាំ២០១៩ ផ្ទៃដីបើកចៀរបន្ថែមមានចំនួន ៦៧៦ ៤០០ហិកតា ឆ្នាំ២០២០ នឹងបើកចំនួន៤២៥ ៦០០ ហិកតា និងឆ្នាំ២០២៥ បន្ថែមចំនួន២១៥ ៩០០ ហិកតា។

❖ ប្រទេសនីមួយៗបានចាត់វិធានការផ្សេងៗគ្នាស្របតាមបរិបទនិងគោលនយោបាយរបស់សាមីប្រទេសរៀងៗខ្លួន តែជារួមមាន៣ជាគោលសំខាន់គឺ៖ (i) វិធានការគ្រប់គ្រងការផ្គត់ផ្គង់ផលិតផល (ii) វិធានការជំរុញការប្រើប្រាស់ក្នុងស្រុក និង (iii) វិធានការជួយឧបត្ថម្ភគាំទ្រកសិករនៅពេលតម្លៃកៅស៊ូធ្លាក់ថ្លៃ

❖ ប្រទេសភាគច្រើនបានធ្វើឲ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់ផ្គត់ផ្គង់តាមរយៈយន្តការកាត់បន្ថយឲ្យបានជាអប្បបរមាឈ្មួញកណ្តាល ការពង្រឹង និងចងក្រងសហករណ៍ ការកែលម្អគុណភាពជ័រកៅស៊ូគ្រួសារ ការរៀបចំប្រព័ន្ធទីផ្សារសម្រាប់កសិករ និងការកំណត់តម្លៃទិញសមស្របដោយរដ្ឋាភិបាលដែលផ្តល់តម្លៃនៅមាត់ចម្ការខ្ពស់ (៨៥ - ៩០%) ដល់កសិករ។

❖ បទពិសោធន៍ជោគជ័យនៃការរៀបចំ និងដំណើរការប្រព្រឹត្តិទៅនៃមជ្ឈមណ្ឌលទីផ្សារកៅស៊ូរួម CRM និងការកែលម្អគុណភាពកៅស៊ូសន្លឹក RSS

ដោយប្រើប្រព័ន្ធ GMP នៅក្នុងប្រទេសថៃ គឺជាគំរូដ៏ល្អបំផុតមួយដែលប្រទេសដទៃទៀតយកទៅអនុវត្ត ដែលក្នុងនោះប្រតិភូប្រទេសហ្វីលីពីនបានស្នើដល់ភាគីថៃមកធ្វើទស្សនកិច្ចសិក្សាម្តងទៀតដើម្បីរៀបចំនៅហ្វីលីពីន។

## ៥. សំណូមពរ

១. គួរត្រៀមរៀបចំវិធានការឬយន្តការសម្រាប់ពង្រឹងតម្លៃកៅស៊ូធម្មជាតិនៅកម្ពុជា។ វិធានការមួយចំនួនដែលគួរអនុវត្តមានដូចខាងក្រោម៖

- ជំរុញចងក្រងឬពង្រឹងសមាគមកសិករកៅស៊ូគ្រួសារ សិក្សា និងបង្កើតមណ្ឌលកែច្នៃកៅស៊ូ ទីផ្សារកៅស៊ូរួម និងទីផ្សារកៅស៊ូដេញថ្លៃសម្រាប់កសិករកៅស៊ូគ្រួសារ ដូចនៅបណ្តាប្រទេសផលិតកៅស៊ូដទៃទៀតដើម្បីផ្តល់កាលានុវត្តន៍ដល់កសិករកៅស៊ូគ្រួសារឲ្យដើរដល់ទីផ្សារចុងក្រោយក្នុងស្រុក និងឲ្យមានអំណាចចរចាថ្លៃជាមួយអ្នកទិញកៅស៊ូក្នុងស្រុក ឬក្រៅប្រទេស
- គួរជំរុញលើកទឹកចិត្តដល់វិនិយោគិនទាំងក្នុង និងក្រៅស្រុក ជាពិសេសវិនិយោគិនបរទេសដែលមានបទពិសោធន៍ឲ្យវិនិយោគទាំងផ្នែកលំហូរខាងលើ និងលំហូរខាងក្រោម (បង្កើតរោងចក្រផលិតផលិតផលសម្រេចពីកៅស៊ូ) ស្របតាមគោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥ - ២០២៥

២. គួរចាត់ប្រតិភូកម្ពុជាធ្វើទស្សនកិច្ចសិក្សាឲ្យបានស៊ីជម្រៅអំពីការរៀបចំនិងដំណើរការប្រព្រឹត្តិទៅនៃមជ្ឈមណ្ឌលទីផ្សារកៅស៊ូរួម CRM និងការកែលម្អគុណភាពកៅស៊ូសន្លឹក RSS ដោយប្រើប្រព័ន្ធ GMP នៅក្នុងប្រទេសថៃ ដើម្បីបានជាធាតុចូលសម្រាប់ការរៀបចំមជ្ឈមណ្ឌលទីផ្សារកៅស៊ូរួម CRM និងការកែលម្អគុណភាពកៅស៊ូសន្លឹក RSS ដោយប្រើប្រព័ន្ធ GMP នៅក្នុងប្រទេសកម្ពុជានាពេលអនាគត

៣. សូមអនុញ្ញាតបន្តចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាសំខាន់ៗផ្សេងៗទៀតដែលជាផលប្រយោជន៍ដល់កម្ពុជា និងជាកាតព្វកិច្ចនៃប្រទេសជាសមាជិក ANRPC ៕




*សិក្ខាកាមជួបជុំថតរូបអនុស្សាវរីយ៍*



*រូបថតអនុស្សាវរីយ៍*

## សិក្ខាសាលាស្តីអំពី ផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុ តាមរយៈការជំរុញការអនុវត្តកសិកម្មល្អ

ចាប់ពីថ្ងៃទី១៩ - ២៣ ខែមិថុនា ឆ្នាំ២០១៨

អគ្គនាយកដ្ឋានកៅស៊ូ បានរៀបចំសិក្ខាសាលាស្ដីអំពី"ផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការជំរុញការអនុវត្តកសិកម្មល្អ" Climate Smart Rubber Production through promoting Good Agriculture Practices (GAP) ។ សិក្ខាសាលានេះមានគោលបំណង៖

(១) បង្កើននិងពង្រឹងចំណេះដឹងដល់មន្ត្រីរាជការអំពីផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុ

(២)រៀបចំសេចក្ដីព្រៀងឯកសារទាក់ទងការអនុវត្តកសិកម្មល្អសម្រាប់វិស័យកៅស៊ូ។

សិក្ខាសាលានេះ ត្រូវបានរៀបចំនៅសាលប្រជុំ នៃអគ្គនាយកដ្ឋានកៅស៊ូ ក្រោមអធិបតីភាពឯកឧត្ដម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ និងលោក **FARLOTTI Pierre,** តំណាងទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) ។ សិក្ខាសាលានេះមានអ្នកចូលរួមមកពីមន្ត្រីអគ្គនាយកដ្ឋានកៅស៊ូគ្រប់នាយកដ្ឋាន មន្ត្រីវិទ្យាស្ថានស្រាវកៅស៊ូកម្ពុជា និងមានការចូលរួមពីជំនាញការរបស់មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិ នៃការស្រាវជ្រាវផ្នែកកសិកម្មសម្រាប់ការអភិវឌ្ឍ (CIRAD) មានចំនួនសរុបប្រមាណ៥០នាក់។

ជាកិច្ចចាប់ផ្ដើមលោកបណ្ឌិត **Eric Gohet** ជំនាញការរបស់មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិនៃការស្រាវជ្រាវផ្នែកកសិកម្មសម្រាប់ការអភិវឌ្ឍ (CIRAD) បានថ្លែងសុន្ទរកថាស្វាគមន៍ដល់គណៈអធិបតីនិងអង្គសិក្ខាសាលា ព្រមទាំងបានលើកឡើងថា វាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់បណ្ដាប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ដើម្បីអនុវត្តន៍កសិកម្មល្អសម្រាប់វិស័យកៅស៊ូ ដោយត្រូវធ្វើការបណ្ដុះបណ្ដាលដល់មន្ត្រីបង្គោលខាងផ្នែកកៅស៊ូ ដើម្បីបង្កើនចំណេះដឹងទាំងផ្នែកទ្រឹស្ដី និងផ្នែកបច្ចេកទេសលើការបង្កើនគុណភាព និងបរិមាណកៅស៊ូសម្រាប់ធ្វើការផ្សព្វផ្សាយនូវចំណេះដឹងទាំងអស់នោះឲ្យដល់កសិករកៅស៊ូគ្រួសារ ប្រតិបត្តិករ និងអ្នកពាក់ព័ន្ធដ៏ទៃទៀតក្នុងវិស័យកៅស៊ូ។

បន្ទាប់មក អង្គសិក្ខាសាលាក៏បានស្ដាប់នូវចំណាប់អារម្មណ៍របស់លោក **FARLOTTI Pierre** តំណាងទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) បានលើកឡើងថារយៈពេលយូរយារមកហើយកៅស៊ូជាដំណាំយ៉ាងសំខាន់សម្រាប់ប្រទេសកម្ពុជាហើយចាប់តាំងពីមានវត្តមានរបស់ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) នៅក្នុងប្រទេសកម្ពុជា, AFD បានចូលរួមក្នុងការអភិវឌ្ឍរបស់ខ្លួនជាច្រើន តាមរយៈភាពជាដៃគូរជាមួយអគ្គនាយកដ្ឋានកៅស៊ូ។ នាពេលបច្ចុប្បន្ននេះ AFD បានសហការណ៍ជាមួយអគ្គនាយកដ្ឋានកៅស៊ូ បានកំពុងអនុវត្តន៍គម្រោងធម្មនិយាមកម្មច្បារពូជ ដែលបានជួយដល់កសិករកៅស៊ូគ្រួសារដើម្បីវាយតម្លៃ និងធ្វើឲ្យប្រសើរឡើងនូវគុណភាពពូជដែលកសិករបានប្រើប្រាស់ និងធ្វើឲ្យប្រសើរឡើងនូវការអនុវត្តបច្ចេកទេសរបស់កសិករកៅស៊ូគ្រួសារផងដែរ។

លោក **FARLOTTI Pierre** បានជឿជាក់លើជំនាញនិងបទពិសោធន៍របស់ជំនាញការ CIRAD ដើម្បីរៀនសូត្របន្ថែមនិងសង្ឃឹមថាទៅអនាគតខ្សែ

ច្រវ៉ាក់កៅស៊ូនៅក្នុងប្រទេសកម្ពុជានឹងទទួលលទ្ធផលប្រសើរជាងនេះ។ នៅពេលគម្រោងបញ្ចប់អ្វីដែលសំខាន់ AFD គឺចូលរួមផ្តល់នូវទិន្នន័យ និងទូរលេខដល់អគ្គនាយកដ្ឋានកៅស៊ូដើម្បីរៀបចំនិងពិនិត្យឡើងវិញសម្រាប់ធ្វើគោលនយោបាយរបស់ខ្លួន។ AFD មានការរីករាយណាស់ដែលបានឃើញនូវចំណាប់អារម្មណ៍សកម្មភាពចុងក្រោយនេះចំពោះប្រព័ន្ធកសិអេកូឡូជី តាមរយៈកសិកម្មឆ្លាតខាងអាកាសធាតុនេះ ជាប្រធានបទមួយដែលជារបៀបវារៈសម្រាប់ថ្នាក់អន្តរជាតិ និងជាការចាប់អារម្មណ៍ដ៏ធំសំបើមចំពោះ AFD នៅក្នុងប្រទេសកម្ពុជាខណៈដែលបានកំពុងធ្វើការសហការណ៍ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ជាកិច្ចបន្តអង្គសិក្ខាសាលាបានស្តាប់សុន្ទរកថាបើកដោយ ឯកឧត្តម **ម៉ុល សុផា** បានលើកឡើងថាកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសនានាដែលងាយរងគ្រោះខ្លាំងទៅនឹងការប្រែប្រួលអាកាសធាតុជាសកល។ ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមពីខាងក្រៅដ៏សំខាន់មួយដែលជះឥទ្ធិពលចំពោះការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការប្រែប្រួលអាកាសធាតុបានបណ្តាលឲ្យមានការកកើតនូវភាពញឹកញាប់នៃទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការកើនឡើងនៃកំដៅ (សីតុណ្ហភាពក្តៅជាងមុន) ដែលជះឥទ្ធិពលអាក្រក់ដល់ផលិតផលកសិកម្មប្រែប្រួលជាអវិជ្ជមាន។ សព្វថ្ងៃនេះដំណាំកៅស៊ូ ចាប់ផ្តើមទទួលរងនូវបញ្ហាប្រឈមជាច្រើនដោយសារការប្រែប្រួលអាកាសធាតុដូចជាភាពរាំងស្ងួតអូសបន្លាយរយៈពេលយូរ របបទឹកភ្លៀងមានការប្រែប្រួល ខ្យល់ព្យុះ និង ខ្យល់កន្ត្រាក់ជាដើមដែលជះឥទ្ធិពលដល់ចម្ការកៅស៊ូ សុខភាពដើមកៅស៊ូថយចុះនិងទិន្នផលធ្លាក់ចុះជាដើម។ ដូចនេះការងារចំពោះមុខនិងចាំបាច់គឺ ការបង្កើនសមត្ថភាពបន្សាំរបស់កសិករឲ្យមានភាពវៃឆ្លាតស្របតាមទំហំលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

ជាទីបញ្ចប់ **ឯកឧត្តម** ក៏បានថ្លែងអំណរគុណចំពោះ AFD ដែលតែងតែជួយគាំទ្រដល់វិស័យកៅស៊ូកន្លងមកនិងមានសង្ឃឹមយ៉ាងមុតមាំថា AFD និងបន្តគាំទ្រ និងជំរុញលើរាល់សកម្មភាពពាក់ព័ន្ធនឹងវិស័យកៅស៊ូក៏ដូចជាសកម្មភាព “Climate Smart Rubber Production through promoting Good Agriculture Practice (GAP)” នេះឲ្យមាននិរន្តរភាពជាបន្តទៀត ដើម្បីឲ្យសកម្មភាពទាំងនេះប្រព្រឹត្តទៅដល់គោលដៅដែលយើងទាំងអស់គ្នាចង់បានគឺចម្ការមានគុណភាពខ្ពស់និងចំណាយតិច (រយៈពេលថែទាំដាំដុះខ្លី, ធន់នឹងជំងឺ និងការប្រែប្រួលអាកាសធាតុ ចម្ការកៅស៊ូផ្តល់ជ័រនិងឈើខ្ពស់) កសិករទទួលបានចំណូលជាអតិបរមា រួមចំណែកកាត់បន្ថយភាពក្រីក្រនៅជនបទ។




*សុន្ទរកថាបើកដោយ ឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ*



*រូបថតអនុស្សាវរីយរបស់សិក្ខាកាម*

សិក្ខាសាលានេះ មានសកម្មភាពដូចខាងក្រោម៖ (១)ការធ្វើបទបង្ហាញរយៈពេល៣ថ្ងៃ (២)កិច្ចប្រជុំពិភាក្សាដើម្បីរៀបចំការអនុវត្តកសិកម្មល្អ (GAP) រយៈពេល១ថ្ងៃ និង (៣)ទស្សនៈកិច្ចសិក្សារយៈពេល ១ថ្ងៃ។

## ១.ការប្រព្រឹត្តទៅនៃវគ្គសិក្ខាសាលា

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨

**បទបង្ហាញទី១៖** "ការយល់ដឹងនូវយុទ្ធសាស្ត្រ និងការអនុវត្តរបស់កសិករជំហានសំខាន់សម្រាប់ការទទួលយកនូវគំនិតថ្មីៗ" (Understanding Famers' Practices and Strategies: an essential step for innovation) ដោយលោកស្រីបណ្ឌិត **Bénédicte Chambon** ជំនាញការ CIRAD ដោយផ្តោតទៅលើការសិក្សាសេដ្ឋកិច្ចសង្គមកសិកម្មដើម្បីកសិកម្មមានលក្ខណៈនិរន្តភាព ចំពោះកសិករកៅស៊ូគ្រួសារក្នុងការទទួលយកការបន្សាំនិងការផ្សព្វផ្សាយដោយមានបញ្ហាប្រឈមមួយចំនួនដូចជាការអនុវត្ត និងទម្លាប់សម្រាប់ការទទួលយកនូវបច្ចេកវិទ្យាថ្មីៗរបស់កសិករកៅស៊ូគ្រួសារ។ ការសិក្សាចរិកលក្ខណៈនៃការអនុវត្តរបស់កសិករ និងការធ្វើអត្តសញ្ញាណនូវបញ្ហាដែលកសិករបានជួបប្រទះត្រូវតែធ្វើការអនុវត្តដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករកៅស៊ូគ្រួសារ។ ការអនុវត្តប្រព័ន្ធកសិកម្មផលិតកម្មចិញ្ចឹមសត្វ ប្រព័ន្ធដាំដុះ ថ្លៃនៃផលិតកម្ម កម្លាំងពលកម្ម និងដើមទុនរបស់កសិករកៅស៊ូគ្រួសារត្រូវបានសិក្សា។



*ការធ្វើបទបង្ហាញដោយ លោកស្រីបណ្ឌិត Bénédicte Chambon ជំនាញការ CIRAD*



*ទិដ្ឋភាពនៃវគ្គសិក្ខាសាលា*

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨

**បទបង្ហាញទី២៖** "សុខភាពដីកសិកម្ម អភិរក្ស និងពិពិធកម្មកសិកម្ម" (Soil Health, Conservation Agriculture and Diversification) របស់លោកបណ្ឌិត **Florent Tivet** ជំនាញការ CIRAD។ ដីកើតចេញពីសិលាមេពុកផុយយឺតៗ ដោយសារពន្លឺព្រះអាទិត្យ ភ្លៀង ខ្យល់ ដោយសត្វ និងរុក្ខជាតិជាដើម។ តាមដំណើរការនេះដីមានជីជាតិ ១០ស.ម ត្រូវការពេល២០០០ឆ្នាំ ហើយដីដែលយើងបំផ្លាញមានរយៈពេលតែ៣-៤ឆ្នាំប៉ុណ្ណោះត្រូវបាត់បង់ជារៀង

រហូត ប៉ុន្តែព្រៃឈើនិងរុក្ខជាតិអាចការពារដីបាន។ សព្វថ្ងៃនេះ យើងពុំមានដីដាំដុះគ្រប់គ្រាន់ និងថែមទាំងដាំដុះដំណាំឯកវប្បកម្មនៅក្នុងតំបន់ជំរាលហើយក្រោយពេលប្រមូលផលរួចដីត្រូវបានភ្ជួរឬក៏ទុកចោលគ្មានអ្វីការពារដែលការអនុវត្តបែបនេះជម្រុញឲ្យដីកាន់តែហូរច្រោះខ្លាំងហើយដីស្រទាប់លើក៏បាត់បង់តាមរយៈខ្យល់និងទឹកជាដើម។ យើងត្រូវការដីមានជីជាតិល្អនិងសុខភាពល្អ ហើយត្រូវចេះបែងចែកដីឲ្យមានតម្លាភាព និងត្រូវបង្កើនទិន្នផលដំណាំឲ្យខ្ពស់ខ្លាំង។ ដីមិនមែនជាធនធានមិនចេះរីងស្ងួតនោះទេ យើងត្រូវដឹងពីរបៀបថែរក្សាដីសម្រាប់កូនចៅរបស់យើង ហើយយើងត្រូវចងចាំថាដីជាភាវៈរស់មានជីវិតសាំញ៉ាំដែលត្រូវការពារ។ ដីគឺជាការបង្កើតនូវសង្គមកសិកម្មដែលជាមូលដ្ឋានសម្រាប់ផ្តល់ស្បៀងចំណីអាហារ ប្រេងឥន្ធនៈ រុក្ខជាតិផ្តល់ជាឱសថ និងផ្តល់ប្រព័ន្ធអេកូឡូស៊ីផងដែរ។ យើងមានវិធីសាស្រ្តដើម្បីអនុវត្តន៍ក្នុងការផ្តល់នូវសារធាតុឲ្យទៅកាន់ដីតាមរយៈការដាំដំណាំគ្របដីជាមួយដំណាំចំបងៗ ដើម្បីបង្កើនសារធាតុសរីរាង្គ និងអាចរក្សាសារធាតុកាបូននៅក្នុងដីផងដែរ។



*ការធ្វើបទបង្ហាញដោយលោកបណ្ឌិត Florent Tivet ជំនាញការ CIRAD*

**បទបង្ហាញទី៣៖** ″ប្រព័ន្ធអេកូសរីរវិទ្យានៃចម្ការកៅស៊ូ″ (Ecophysiology of Rubber Tree Plantations) របស់លោកបណ្ឌិត **Yann Nouvellon** ជំនាញការ CIRAD។ រៀបរាប់អំពីការប្រែប្រួលអាកាសធាតុ លក្ខខណ្ឌសមស្របរបស់ដំណាំកៅស៊ូ ការបំភាយចំហាយទឹករបស់ដំណាំកៅស៊ូ ទៅក្នុងបរិយាកាស លទ្ធផលនៃការស្រាវជ្រាវទៅលើការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ពីរគឺៈតំបន់ដែលមានការដាំកៅស៊ូ និងតំបន់ដែលជាតំបន់ព្រៃធម្មជាតិ បច្ចេកទេសមួយចំនួនក្នុងការសិក្សាពិសោធន៍ទៅលើកំដៅក្នុងដីរបបទឹកភ្លៀង ការបំភាយចំហាយទឹករបស់រុក្ខជាតិ ល្បឿនខ្យល់ កំដៅនៃពន្លឺព្រះអាទិត្យ និងលក្ខណៈសរីរៈរបស់រុក្ខជាតិក្នុងការលូតលាស់ជាពិសេសការស្រូបយកសារធាតុចិញ្ចឹមតាមរយៈប្រព័ន្ធឬសរបស់រុក្ខជាតិ។

នៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៧

**បទបង្ហាញទី៤៖** ″បច្ចេកទេសប្រមូលទឹកជ័រ″ (Latex Harvesting Technology , LHG) របស់លោកបណ្ឌិត **Eric Gohet** អ្នកជំនាញការ CIRAD។ បច្ចេកទេសក្នុងការប្រមូលទឹកជ័រឲ្យ បានសមស្របដោយធ្វើការថែរក្សាការពារសុខភាពដើមកៅស៊ូជាពិសេសគឺការទាញយកផលពីដំណាំកៅស៊ូទៅតាមបច្ចេកទេសដូចជាការប្រើប្រាស់ជី ការបើកមុខចៀរជ័រ ការថែរក្សាផ្ទាំងចៀរ ការផ្លាស់ប្តូរមុខចៀរ ចង្វាក់ចៀរ សរីរៈរបស់ដើមកៅស៊ូក្នុងការធ្វើមេតាប៉ូលីសការរិភាគទឹកជ័រ ការការពារទឹកជ័រតាមរយៈការប្រើប្រាស់ក្បាំងទឹកភ្លៀង ពេលវេលាក្នុងការទាញយកផល ការប្រើប្រាស់ថ្នាំរំញោច និងការអនុវត្តកសិកម្មល្អក្នុងការទាញយកផលឲ្យបានសមស្របពីដំណាំកៅស៊ូផងដែរ។



*ការធ្វើបទបង្ហាញដោយលោកបណ្ឌិត Eric Gohet ជំនាញការ CIRAD*

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨

មានកិច្ចប្រជុំពិភាក្សាថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូក្រោមអធិបតីភាព ឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ និងលោកបណ្ឌិត **Eric Gohet** ជំនាញការរបស់មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិនៃការស្រាវជ្រាវផ្នែកកសិកម្មសម្រាប់ការអភិវឌ្ឍ (CIRAD) ព្រមទាំងសហការី។ អង្គប្រជុំបានពិភាក្សាលើចំនុចសំខាន់ៗដូចខាងក្រោម៖ (១)រៀបចំសេចក្តីព្រៀងឯកសារស្តីអំពីការអនុវត្តកសិកម្មល្អ (GAP) ក្នុងវិស័យកៅស៊ូ (២)ការសិក្សាលើទិន្នន័យរបបទឹកភ្លៀងតាមបណ្តាខេត្តក្នុងតំបន់ទាំងបួននៃប្រទេសកម្ពុជា ខ្ពង់រាប ទំនាបកណ្តាល មាត់សមុទ្រ និងតំបន់ភ្នំ (៣)ការប្រែប្រួលអាកាសធាតុរយៈពេល១០ឆ្នាំចុងក្រោយ (៤)ការរៀបចំធ្វើពិសោធន៍ទាក់ទងទៅនឹងការអនុវត្តកសិកម្មល្អនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង (៥) ការពិភាក្សាពីគោលបំណងរបស់អគ្គនាយកដ្ឋានកៅស៊ូលើការអនុវត្តកសិកម្មល្អ ដើម្បីបង្កើនគុណភាព និងផលិតភាពកៅស៊ូឲ្យបានសមស្របនិងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុដើម្បីធ្វើយ៉ាងណាឲ្យកសិករកៅស៊ូគ្រួសារ ប្រតិបត្តិករ និងអ្នកពាក់ព័ន្ធ ទទួលបានប្រាក់ចំណូលជាអតិប្បរមាក្នុងវិស័យនេះ។





*ការប្រជុំស្តីពីការរៀបចំឯកសារពង្រាងស្តីពីការអនុវត្តកសិកម្មល្អ (GAP) ក្នុងវិស័យកៅស៊ូ និងការងារផ្សេងៗ រវាងថ្នាក់ដឹកនាំ GDR, CRRI និង CIRAD*







*ពិធីចុះហត្ថលេខាស្តីពីដំណើរការនៃការអនុវត្តកសិកម្មល្អ រវាងអគ្គនាយកដ្ឋានកៅស៊ូ និងជំនាញការ CIRAD*

## ២. ទស្សនកិច្ចសិក្សា

ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨

ការធ្វើទស្សនកិច្ចសិក្សារបស់សិក្ខាកាមទៅកាន់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (វសកក) ដើម្បីធ្វើការសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់នូវការអនុវត្តជាក់ស្តែងនិងអាចណែនាំដល់កសិករកៅស៊ូគ្រួសារបន្តទៀតដែលក្នុងសិក្ខាកាមបានសិក្សាអំពី៖ (១)ច្បារពូជ ការជម្រើសក្លូន ការសម្គាល់ក្លូនកៅស៊ូ និងក្លូនកៅស៊ូថ្មីដែលទើបតែនាំយកមកដាំសាកល្បងនៅក្នុងឡូត៍ពិសោធន៍ (២)ថ្នាលបណ្តុះកូនកៅស៊ូនិងឡូត៍ពិសោធន៍ពី Trip Irrigation on Rubber Trees (៣)ពិនិត្យមើលទីតាំងសម្រាប់ពិសោធន៍ស្តីពី Effect of Cover crops and Fertilizer on Rubber Growth, Production ដោយផ្តោតលើការអនុវត្តកសិកម្មល្អ (GAP) និង (៤)បន្តទស្សនកិច្ចសិក្សាមន្ទីរពិសោធន៍ជីវគីមីនិងសរីរវិទ្យា។



*ដំណើរទស្សនកិច្ចសិក្សារបស់សិក្ខាកាមនៅស្ថានីយ៍ពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា*

តាមរយៈលទ្ធផល ដែលទទួលបានពីសិក្ខាសាលាបានបង្ហាញឲ្យឃើញថា៖

- ❖ សិក្ខាសាលាប្រព្រឹត្តទៅដោយជោគជ័យតាមការគ្រោងទុកនិងមានការចូលរួមផ្លាស់ប្តូរបទ-ពិសោធន៍ចំណេះដឹងគ្នាយ៉ាងផុលផុស
- ❖ បង្កើនចំណេះដឹងដល់មន្ត្រីជំនាញឲ្យយល់កាន់តែច្បាស់អំពីផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការអនុវត្តកសិកម្មល្អ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ
- ❖ សិក្ខាកាមទទួលបានចំណេះដឹងទាំងផ្នែកទ្រឹស្តី និងការអនុវត្តដែលអាចទៅធ្វើការផ្សព្វផ្សាយដល់កសិករកៅស៊ូគ្រួសារ ប្រតិបត្តិករ និងអ្នកពាក់ព័ន្ធដទៃទៀតអំពីផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុ
- ❖ ពិសោធន៍ស្តីពី Effect of Cover crops and Fertilizer on Rubber Growth, Production ដោយផ្តោតលើការអនុវត្តកសិកម្មល្អ (GAP) ត្រូវបានបង្កើតឡើងនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- ❖ ឯកសារពង្រាងស្តីអំពីផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការជម្រុញការអនុវត្តកសិ-កម្មល្អសម្រាប់វិស័យកៅស៊ូនឹងត្រូវបានបង្កើតឡើងតាមរយៈអគ្គនាយកដ្ឋានកៅស៊ូសហការណ៍ជាមួយជំនាញការរបស់មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិនៃការស្រាវជ្រាវផ្នែកកសិកម្មសម្រាប់ការអភិវឌ្ឍ (CIRAD)៕

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកៅស៊ូ**

លេខ: ៦៦៩ អក.ល

ថ្ងៃ [illegible] ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៨

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំឆមាសទី១ ឆ្នាំ២០១៨និងទិសដៅអនុវត្តបន្ត។
**ជូនភ្ជាប់** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំឆមាសទី១ ឆ្នាំ២០១៨និងទិសដៅអនុវត្តបន្ត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំឆមាសទី១ ឆ្នាំ២០១៨និងទិសដៅអនុវត្តបន្តដោយសង្ខេបដូចខាងក្រោម៖

១-ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤៣៦ ២៩៩ ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ១៧៣ ០១៧ ហិកតា ស្មើនឹង ៣៩% និងផ្ទៃដីថែទាំមានចំនួន ២៦៣ ២៨១ ហិកតា ស្មើនឹង៦១%។

២-បរិមាណផលិតផលសម្រេចបានក្នុងឆមាសទី១មានចំនួន ៨៣ ៧១៨ តោន បានកើនឡើងចំនួន ១០ ៨៤៧ តោនស្មើនឹង១៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៣-បរិមាណបញ្ចេញលក់ក្នុងឆមាសទី១មានចំនួន ៨៤ ៤១៩ តោន បានកើនឡើងចំនួន ១៤ ៣៧៦ តោន ស្មើនឹង២១% ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

៤-តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងឆមាសទី១មានចំនួន ១ ៤៣៤ដុល្លារ/តោន បានថយចុះចំនួន ៣៣៦ ដុល្លារ/តោន ស្មើនឹង(-១៨,៩៨%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៥-ទិសដៅបន្ត៖

- ប្រជុំពិនិត្យនិងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងកែសម្រួលធ្វើបច្ចុប្បន្នភាពសារាចរលេខ ១០សរណន ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- បន្តចុះអនុវត្តសកម្មភាពគម្រោងតាមកម្មវិធីឲ្យបានសម្រេចតាមផែនការដែលបានគ្រោងទុក
- ចុះត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងជំរុញការប្រមូលចំណូលចូលថវិការដ្ឋតាមការគ្រោងទុក
- ផ្សព្វផ្សាយតម្លៃកៅស៊ូតាមវិទ្យុ លើទំព័រហ្វេសប៊ុក និងព្រឹត្តិបត្ររបស់អគ្គនាយកដ្ឋានកៅស៊ូ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ប៉ុល សុផា**

**ចម្លងជូន៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក
  "ដើម្បីជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃ អនក.
- គ្រប់ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម
  "ដើម្បីជ្រាប"
- ឯកសារ

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email: gdr.maff@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

## របាយការណ៍
## ស្តីពី
## ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំឆមាសទី១ ឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្ត

### ១.សេចក្តីផ្តើម

នៅក្នុងឆមាសទី១ ឆ្នាំ២០១៨ នេះអគ្គនាយកដ្ឋានកៅស៊ូ បាននឹងកំពុងអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ទាំងការងារចរន្ត ការងារអនុវត្តគម្រោងតាមកម្មវិធី ការងារដាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ច ទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិ-ឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗ ដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០១៨ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

### ២.លទ្ធផលការងារសម្រេចបាន

#### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

##### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤៣៦ ២៩៩ ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ១៧៣ ០១៧ ហិកតា ស្មើនឹង ៣៩% និងផ្ទៃដីថែទាំមានចំនួន ២៦៣ ២៨១ ហិកតា ស្មើនឹង ៦១% ធៀបនឹងខែមុន ។

##### ២.១.២ ផលិតកម្ម

ផលិតផលជ័រកៅស៊ូសម្រេចបានក្នុងខែមិថុនាមានចំនួន ១៨ ២៥៩ តោន បានកើនឡើងចំនួន ១ ៩៧៩ តោន ស្មើនឹង១២% ធៀបនឹងខែមុន និងបានកើនឡើងចំនួន ២ ៨១២ តោន ស្មើនឹង ១៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

ផលិតផលជ័រកៅស៊ូសរុបគិតមកដល់ត្រឹមខែមិថុនា (ឆមាសទី១) សម្រេចបានចំនួន ៨៣ ៧១៨ តោន បានកើនឡើងចំនួន ១០ ៨៤៧ តោន ស្មើនឹង ១៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

##### ២.១.៣ ធុរកិច្ចកៅស៊ូ

បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែមិថុនាមានចំនួន ១៦ ៧៤៣ តោន បានកើនឡើងចំនួន ៥៩០ តោន ស្មើនឹង៤% បើធៀបនឹងខែមុន និងបានកើនឡើងចំនួន ១ ២៩០ តោន ស្មើនឹង ៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។

បរិមាណបញ្ចេញលក់សរុបគិតមកដល់ត្រឹមខែមិថុនា (ឆមាសទី១) សម្រេចបានចំនួន ៨៤ ៤១៩ តោន បានកើនឡើងចំនួន ១៤ ៣៧៦ តោន ស្មើនឹង ២១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

តម្លៃលក់មធ្យមក្នុងខែមិថុនាគឺ ១ ៤១៣ដុល្លារ/តោន បានកើនឡើង ២០ដុល្លារ/តោន ស្មើនឹង ១,៤១%ធៀបនឹងខែមុន ប៉ុន្តែបានថយចុះ ២៣ដុល្លារ/តោន ស្មើនឹង១,៦០% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន

អាសយដ្ឋាន: ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
Address: National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email:gdr.maff@gmail.com

តម្លៃលក់កៅស៊ូជាមធ្យមគិតមកដល់ត្រឹមខែមិថុនា (ឆមាសទី១) គឺ ១ ៤៣៤ ដុល្លារ/តោន បានថយចុះចំនួន ៣៣៦ ដុល្លារ/តោន ស្មើនឹង (-១៨,៩៨%) ធៀបនឹងរយៈដូចគ្នាឆ្នាំមុន។

## ២.២. ការងារចរន្តនិងការអនុវត្តគម្រោងសមកម្មភាពថវិកាតាមកម្មវិធី

### ២.២.១. ការងារចរន្ត

- បានប្រជុំរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងលិខិតបទដ្ឋាននានាក្រោមច្បាប់បានចំនួន២លើក នៅអគ្គនាយកដ្ឋានកៅស៊ូ
- បានចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធវិស័យកៅស៊ូបានចំនួន០១លើកនៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
- បានចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានពីរខេត្តគោលដៅគឺ ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី
- បានចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ នៅខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី កំពង់ធំ ព្រះវិហារ កំពង់ចាម និងខេត្តត្បូងឃ្មុំ
- បន្តចុះពង្រឹងសហគមន៍កៅស៊ូគ្រួសារនៅខេត្តបាត់ដំបង និងប៉ៃលិន
- ចុះតាមដាននិងវាយតម្លៃការអនុវត្តវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើវិស័យកៅស៊ូបានចំនួនពីរលើក
- ចុះតាមដាន និងវាយតម្លៃការអនុវត្តន៍ចង្កោមសកម្មភាពរបស់នាយកដ្ឋានអភិវឌ្ឍកៅស៊ូចំនួន១ដង
- រៀបចំប្រជុំធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា (២០១៦-២០២៥)
- រៀបចំវគ្គសិក្ខាសាលាស្តីពី ស្ថានភាពឧស្សាហកម្មកៅស៊ូធម្មជាតិ (២៧-២៩/៦/១៨)
- បានសិក្សាស្រាវជ្រាវប្រមូលទិន្នន័យនិងព័ត៌មានកៅស៊ូ សម្រាប់រៀបចំព្រឹត្តិបត្រប្រចាំខែ និងផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិលើទំព័រហ្វេសប៊ុករបស់អគ្គនាយកដ្ឋានកៅស៊ូ
- បានប្រមូលទិន្នន័យ និងរៀបចំតម្លៃកៅស៊ូធម្មជាតិសម្រាប់ផ្សាយប្រចាំសប្តាហ៍តាមវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា(FM102)ចំនួន៤ដង។

### ២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី

ការចំណាយថវិកាគិតមកដល់ត្រឹមខែមិថុនា (ឆមាសទី១) ឆ្នាំ២០១៨ មានចំនួន ១ ០១៣ ៤៥២ ៧៩៥ រៀល ដោយឡែកការចំណាយថវិកាក្នុងខែមិថុនា ឆ្នាំ២០១៨មានចំនួន ៤០៧ ៧៨១ ៦៩៥ រៀល។

### ២.២.៣. ការប្រមូលចំណូលថវិកា

ការប្រមូលចំណូលថ្លៃឈ្នួលដីវិនិយោគចម្ការកៅស៊ូរដ្ឋទាំង៧ ក្រុមហ៊ុនចម្ការកៅស៊ូរដ្ឋឡាបានសៀក និងក្រុមហ៊ុននីហ័រណេ អាហ័រណេកៅស៊ូ គិតមកដល់ត្រឹមខែមិថុនា (ឆមាសទី១) ឆ្នាំ២០១៨ បានចំនួន ៦៩៣ ០៣១ ៩៧៩ រៀល។ ដោយឡែកក្នុងខែមិថុនា ឆ្នាំ២០១៨ ប្រមូលចិការបានចំនួន ២០៧ ៧៨៣ ៤៨៣រៀល ។

## ៣. ទិសដៅបន្ត

- បន្តប្រជុំពិនិត្យនិងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងកែសម្រួលធ្វើបច្ចុប្បន្នភាពសារាចរណែនាំលេខ១០សរណនចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា

២/៣

- បន្តរៀបចំធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា (២០១៦-២០២៥)
- បន្តចុះតាមដាន វាយតម្លៃការអនុវត្តចង្កោមសកម្មភាព និងកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចក្នុងវិស័យកៅស៊ូ និងអនុវត្តការងារផ្សេងៗតាមផែនការគ្រោងទុកសម្រាប់ឆ្នាំ២០១៨
- បន្តចុះបើកវគ្គបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ
- បន្តចុះពង្រឹងនិងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ
- បន្តចុះពិនិត្យនិងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តស្រាវជ្រាវនិងប្រមូលទិន្នន័យកៅស៊ូក្នុងស្រុក និងអន្តរជាតិ សម្រាប់រៀបចំព្រឹត្តិបត្រប្រចាំខែ និងផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិតាមវិទ្យុប្រចាំសប្តាហ៍និងលើគេហទំព័រហ្វេសប៊ុករបស់អគ្គនាយកដ្ឋានកៅស៊ូ។

ថ្ងៃ[illegible] ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៨
**ប្រធាននាយកដ្ឋានរដ្ឋបាលនិងនិតិកម្ម**

**បានឃើញនិងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

**សេក គង្គី**

៣/៣

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំឆមាសទី១ ឆ្នាំ២០១៨

តារាងទី១

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០១៧ | | | | សន្និធិដើមគ្រា | ឆ្នាំ២០១៨ | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | | | | | | | | | | | | | ផ្ទៃដីសរុប | | ផលិតផល | | បញ្ចេញលក់ | | ផលិតផល | | | | បញ្ចេញលក់ | | | | |
| | | ចៀរជ័រ | ថែទាំ | សរុប | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 658 | 131 | 789 | 48 | 237 | 50 | 200 | 25 | 54 | 227 | 50 | 200 | 0 | 0 | 5 | 11 | 0 | 0 | 6 | 13 | -10 | -4 | 0 | 0 | 0 | 0 | 52 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ិនវេសមេន គ្រុប | 11,668 | 3,132 | 14,800 | 1,714 | 8,431 | 2,077 | 7,468 | 2,477 | 1,594 | 6,871 | 1,021 | 7,957 | 0 | 0 | -41 | -2 | -974 | -49 | -120 | -7 | -1,560 | -19 | -1,056 | -51 | 488 | 7 | 1,391 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1,191 | 864 | 2,055 | 133 | 556 | 147 | 525 | 22 | 152 | 593 | 126 | 588 | 0 | 0 | 36 | 31 | -42 | -25 | 19 | 14 | 37 | 7 | -21 | -14 | 63 | 12 | 27 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 5,658 | 2,495 | 8,153 | 397 | 1,690 | 378 | 1,734 | 721 | 412 | 1,631 | 242 | 2,038 | -514 | -6 | 35 | 9 | -177 | -42 | 15 | 4 | -59 | -3 | -136 | -36 | 304 | 18 | 314 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ ឈើមីតធីត(រតនគិរី) | 79 | 2,588 | 2,666 | 31 | 65 | 25 | 60 | 253 | 7 | 51 | | 267 | 0 | 0 | -8 | -52 | 0 | 0 | -23 | -76 | -15 | -23 | -25 | 0 | 207 | 344 | 36 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស៍ លីមីធីត(ស្នួល) | 3,859 | 548 | 4,406 | 278 | 1,239 | 60 | 787 | 2,036 | 410 | 1,657 | 484 | 2,030 | 0 | 0 | 64 | 18 | 211 | 77 | 133 | 48 | 418 | 34 | 424 | 707 | 1,244 | 158 | 1,663 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ិនធើណេស៊ិនណល | 4,604 | 1,335 | 5,939 | 508 | 1,845 | 445 | 1,740 | 440 | 517 | 1,768 | 378 | 1,628 | 0 | 0 | 39 | 8 | 168 | 80 | 9 | 2 | -76 | -4 | -67 | -15 | -112 | -6 | 580 |
| 8 | ក្រុមហ៊ុនអានម៉ានី គ្រុប(ចម្ការអណ្តូង) | 3,327 | 2,597 | 5,924 | 286 | 879 | 290 | 998 | 198 | 289 | 1,009 | | 840 | 0 | 0 | 48 | 20 | -220 | 0 | 2 | 1 | 130 | 15 | -290 | 0 | -158 | -16 | 367 |
| 9 | ក្រុមហ៊ុនអានម៉ានី គ្រុប(ពាមជាំង+រមាសហែក) | 1,882 | 1,242 | 3,124 | 172 | 516 | 160 | 592 | 169 | 170 | 449 | | 360 | 0 | 0 | 58 | 52 | -80 | 0 | -3 | -2 | 68 | -13 | -160 | 0 | -232 | -39 | 258 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 4,359 | 439 | 4,798 | 580 | 2,112 | 820 | 2,038 | 461 | 502 | 2,110 | 462 | 2,169 | 0 | 0 | 61 | 14 | 42 | 10 | -77 | -13 | -2 | 0 | -358 | -44 | 131 | 6 | 402 |
| | សរុប ក | 37,284 | 15,370 | 52,655 | 4,147 | 17,571 | 4,452 | 16,143 | 6,925 | 4,107 | 16,366 | 2,763 | 18,078 | -514 | -1 | 297 | 8 | -1,071 | -28 | -40 | -1 | -1,205 | -7 | -1,690 | -38 | 1,935 | 12 | 5,213 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 35,229 | 192,303 | 227,532 | 3,000 | 14,800 | 2,900 | 14,200 | 653 | 3,952 | 18,652 | 3,780 | 17,841 | 0 | 0 | 482 | 14 | 461 | 14 | 952 | 32 | 3,852 | 26 | 880 | 30 | 3,641 | 26 | 1,464 |
| | សរុបI=ក+ខ | 72,513 | 207,673 | 280,187 | 7,147 | 32,371 | 7,352 | 30,343 | 7,578 | 8,059 | 35,018 | 6,543 | 35,919 | -514 | 0 | 779 | 11 | -610 | -9 | 912 | 13 | 2,647 | 8 | -810 | -11 | 5,576 | 18 | 6,677 |
| | II. កៅស៊ូគ្រួសារ | 100,504 | 55,608 | 156,112 | 8,300 | 40,500 | 8,100 | 39,700 | 4,676 | 10,200 | 48,700 | 10,200 | 48,500 | 0 | 0 | 1,200 | 13 | 1,200 | 13 | 1900 | 23 | 8,200 | 20 | 2,100 | 26 | 8,800 | 22 | 4,876 |
| | សរុបរួមI+II | 173,017 | 263,281 | 436,299 | 15,447 | 72,871 | 15,452 | 70,043 | 12,254 | 18,259 | 83,718 | 16,743 | 84,419 | -514 | -0.12 | 1,979 | 12 | 590 | 4 | 2812 | 18 | 10,847 | 15 | 1,290 | 8 | 14,376 | 21 | 11,553 |

បញ្ជាក់:

(១) ផ្ទៃដីសរុបមានចំនួន ៤៣៦ ២៩៩ហត ( ផ្ទៃដីចៀរជ័រ ១៧៣ ០១៧ហត ថែទាំ ២៦៣ ២៨១ហត) ថយចុះ ៥១៤ហត (០.១២%)ធៀបនឹងខែមុន។

(២) ផលិតផលសរុបចំនួន ១៨ ២៥៩ តោន បានកើនឡើងចំនួន ១ ៩៧៩តោន ( ១២%) ធៀបខែមុន និងបានកើនឡើងចំនួន ២ ៨១២ (១៨%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។

(៣) រហូតមកដល់ខែមិថុនា (ឆមាសទី១) ឆ្នាំ២០១៨ ផលិតផលសរុប ៨៣ ៧១៨តោន បានកើន ១០ ៨៤៧តោន ( ១៥%)ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។

(៤) ការបញ្ចេញលក់សរុប ១៦ ៧៤៣តោន បានកើន ៥៩០តោន (៤%) ធៀបខែមុន និងបានកើនឡើងចំនួន ១ ២៩០ត (៨%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។

(៥) រហូតមកដល់ខែមិថុនា(ឆមាសទី១) ឆ្នាំ២០១៨ ការបញ្ចេញលក់សរុប ៨៤ ៤១៩តោន បានកើនឡើងចំនួន១៤ ៣៧៦ (២១%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។

(៦)សន្និធិចុងគ្រាមានចំនួន១១ ៥៥៣ត។

បានឃើញ និងឯកភាព
ជ.រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធនធានទឹកកម្ពុជា ទទួលបន្ទុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

សេក តក្តី

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

ឃួន_ផល្លា

ថ្ងៃ សុក្រ ១៤កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៨
អ្នកធ្វើតារាង

ធី ប៊ិនធី

# ព័ត៌មានអន្តរជាតិ

## ពិព័រណ៍កៅស៊ូឥណ្ឌានឹងប្រារព្ធនៅខែមករាពេលខាងមុខនេះ

*ឯកសារយោង៖ http://www.tribuneindia.com*
*ប្រែសម្រួលដោយលោក **គុយ គន្ធី***

សមាគមឧស្សាហកម្មកៅស៊ូ ឥណ្ឌាទាំងអស់ បានរៀបចំសន្និសីទសារព័ត៌មាន និងបានប្រកាសអំពីការតាំងពិរព័ណ៌កៅស៊ូធំជាងគេនៅអាស៊ីដែលនឹងប្រារព្ធឡើងនៅទីក្រុង Mumbai ក្នុងខែមករា ឆ្នាំ ២០១៩ខាងមុខនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃឧស្សាហកម្មកៅស៊ូដែលជាវិស័យដ៏សំខាន់ជាងគេបំផុតក្នុងប្រទេស។

ការតាំងពិព័ណ៌កៅស៊ូឥណ្ឌា ឆ្នាំ២០១៩ (IRE-India Rubber Expo) កំពុងស្ថិតក្នុងការរៀបចំមួយដើម្បីឲ្យក្លាយទៅជាស្តង់ដារអន្តរជាតិ។

លោក **Vikram Makar** និងជានាយកប្រតិបត្តិនៃពិព័រណ៍កៅស៊ូឥណ្ឌា និង នាយកក្រុមហ៊ុន Oriental Rubber Industries Pvt Ltd មានប្រសាសន៍ថាការតាំងពិព័រណ៍កៅស៊ូឥណ្ឌានឹងបង្ហាញឲ្យឃើញអំពីសមាសភាពក្រុមហ៊ុនធំជាងគេដែលនឹងចូលរួមក្នុងពិព័រណ៍នេះ និងផ្តល់ឱកាសសម្រាប់ម្ចាស់អាជីវកម្មខ្នាតតូច និងធំដើម្បីធ្វើការផ្លាស់ប្តូរយោបល់គ្នា។

លោក **HS Chitkara** អាជីវករក្នុងស្រុកនិងជាអគ្គលេខាធិការនៃពិព័រណ៍កៅស៊ូឥណ្ឌានិយាយថា៖ មានស្តង់តាំងពិព័រណ៍រោងចក្រកៅស៊ូចំនួន៤០០ សម្រាប់ពិព័រណ៍ក្នុងតំបន់ Jalandhar នេះ ប៉ុន្តែត្រូវកាត់បន្ថយមកនៅត្រឹមចំនួន១៥០ស្តង់ប៉ុណ្ណោះ។ យើងចង់ឲ្យរដ្ឋាភិបាលជួយពួកយើង ដើម្បីឲ្យការរៀបចំប្រព្រឹត្តទៅជាព្រឹត្តិការណ៍ធំមួយ៕

## វៀតណាមនៅតែរក្សាជំហរជាអ្នកនាំចេញកៅស៊ូលំដាប់ទី៣

*ឯកសារយោង៖ http://english.vietnamnet.vn*
*ប្រែសម្រួលដោយកញ្ញា **ថូ ស្រីស***

តាមសារព័ត៌មាន VietNamNet Bridge: បានឲ្យដឹងថា៖ ប្រសិនបើ ប្រទេសវៀតណាមមិនផ្លាស់ប្តូរការអភិវឌ្ឍន៍កៅស៊ូឲ្យមាននិរន្តរភាពទេ នោះប្រទេសវៀតណាមនឹងធ្លាក់ចេញពីតំណែងជាអ្នកនាំចេញកៅស៊ូធំបំផុតទី៣លើពិភពលោក។

ប្រទេសវៀតណាមបានជាប់ចំណាត់ថ្នាក់ទី៣ បន្ទាប់ពីប្រទេសថៃ, ឥណ្ឌូនេស៊ី និងនៅពីក្រោយយ៉ាងកៀកដោយប្រទេសម៉ាឡេស៊ី។

មានក្រុមហ៊ុនកៅស៊ូរាប់រយជាមួយនឹងការច្នៃប្រឌិតនូវបច្ចេកទេសថ្មីៗជាច្រើនបានធ្វើឲ្យប្រទេសវៀតណាមឈានមុខគេលើទិន្នផលទឹកជ័រកៅស៊ូពី ១,៦ ទៅ១,៧តោន/ហិកតា។

ប្រទេសវៀតណាម បានធ្វើឲ្យតំណែងរបស់ខ្លួនឡើងដោយមានទិន្នផលកៅស៊ូ ១.១លានតោន

ពីផ្ទៃដីដាំដុះ១លានហិកតា បន្ទាប់ពីឡើងដល់ចំណាត់ថ្នាក់ទី៣ លើផ្នែកទិន្នផលកៅស៊ូពិភពលោកក្នុងឆ្នាំ២០១៣។

កៅស៊ូធម្មជាតិរបស់ប្រទេសវៀតណាម បាននាំចេញជាង៨០% នៅលើទីផ្សារស្មើរនឹង ១២% នៃការនាំចេញសរុបរបស់ពិភពលោក។

នាពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសវៀតណាម បានប្រឈមមុខនិងការរិៈគន់លើគម្រោងកៅស៊ូនៅប្រទេសឡាវនិងកម្ពុជា។សមាគមកៅស៊ូវៀតណាម ក៏បានចេញនូវឯកសារមួយស្តីអំពីរបៀបដែលអ្នកវិនិយោគអាចកាត់បន្ថយហានិភ័យជាមួយគម្រោងនេះ។ ទោះយ៉ាងណាក៏ដោយ នេះគ្រាន់តែជាវិធានការមួយបណ្តោះអាសន្នប៉ុណ្ណោះ។

កាលពីថ្ងៃទី៧ ខែឧសភា ក្នុងកិច្ចជំនួបកំពូលឧស្សាហកម្មកៅស៊ូពិភពលោក មានក្រុមហ៊ុនទិញកៅស៊ូធំបំផុតចំនួនបីគឺក្រុមហ៊ុន Bridgestone ក្រុមហ៊ុន Goodyear និងក្រុមហ៊ុន Michelin បាននិយាយថាពួកគេនឹងខិតខំផលិតកៅស៊ូឲ្យមាននិរន្តរភាពទៅថ្ងៃអនាគត។

យោងតាម ឯកឧត្តម **Vo Hoang An** អគ្គលេខាធិការសមាគមកៅស៊ូវៀតណាម បានឲ្យដឹងថា៖ក្រុមហ៊ុនសំបកកង់ឡានធំៗចំនួន១១ក្រុមហ៊ុន បានព្រមព្រៀងគ្នាតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូប្រកបដោយនិរន្តរភាពនេះ ដែលបានប្រើប្រាស់កៅស៊ូជាង៨៥% នៃកៅស៊ូធម្មជាតិពិភពលោក។

ស្របពេលជាមួយគ្នានោះ អ្នកស្រី **Tran Thi Thuy Hoa** ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កៅស៊ូបាននិយាយថាឈ្មួញទិញកៅស៊ូមួយចំនួនបានចាប់ផ្តើមស្នើសុំឲ្យក្រុមប្រឹក្សាភិបាលការពារព្រៃឈើ (FSC : Forest Stewardship Council)ចេញនូវវិញ្ញាបនបត្រ។ ដោយឡែកសហគ្រាសវៀតណាមមួយចំនួនដែលគ្មានវិញ្ញាបនបត្របានបាត់បង់អតិថិជនរបស់ពួកគេខ្លះៗហើយ។

ការអភិវឌ្ឍកៅស៊ូប្រកបដោយចីរភាពត្រូវបានលើកឡើងជាលើកដំបូងនៅក្នុងគោលនយោបាយរបស់ប្រទេសវៀតណាមកាលពីប៉ុន្មានឆ្នាំមុន។

ក្នុងឆ្នាំ២០១២ រដ្ឋាភិបាលវៀតណាមបានចេញសេចក្តីសម្រេចលេខ ៤៣២ ស្តីអំពីយុទ្ធសាស្ត្រអភិវឌ្ឍចីរភាពរបស់វៀតណាមនៅឆ្នាំ២០២០ និងមានសេចក្តីសម្រេចនិងសារាចរជាច្រើនទៀត។ ទាំងនេះរួមមាន៖ សេចក្តីសម្រេចលេខ៨៤៩ ស្តីអំពីការរៀបចំរចនាសម្ព័ន្ធក្នុងវិស័យកសិកម្មឆ្ពោះទៅរកការបង្កើនខ្សែច្រវ៉ាក់តម្លៃ និងការអភិវឌ្ឍនប្រកបដោយចីរភាព និងសារាចរលេខ៣៨ ស្តីអំពីផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាពរួមទាំងការដាំព្រៃឈើផងដែរ។

នៅខែមេសា ឆ្នាំ២០១៧ នាយករដ្ឋមន្ត្រីបានចេញសេចក្តីសម្រេចលេខ ៤១៩ ស្តីអំពីការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដើម្បីកាត់បន្ថយការបាត់បង់ព្រៃឈើ និងការរិចរិល។ កៅស៊ូគឺជាដំណាំមួយក្នុងចំណោមដំណាំចំនួនបួននៅក្នុងគំរូអភិវឌ្ឍន៍ប្រកបដោយចីរភាព៕

# ទំព័រស្រាវជ្រាវ

## ការដាំដុះនិងថែទាំកូនកៅស៊ូមិនទាន់ផ្តល់ផល

*រៀបចំដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ*

### ១. ការដាំដុះដំណាំកៅស៊ូ

កូនកៅស៊ូ ដែលយកទៅដាំដុះត្រូវមានស្លឹក ១ផ័ត្រពណ៌បៃតងក្រម៉ៅ។ ការដាំ (ស្លឹកចាស់ល្អ) ធ្វើនៅរដូវវស្សាចាប់ពីចុងខែឧសភា ដល់ ខែសីហា។ ការដាំត្រូវអនុវត្តជាបន្តបន្ទាប់ដូចខាងក្រោម៖

- កាយដីស្តារបាតរណ្តៅឲ្យបានជម្រៅយ៉ាងតិច៥០ស.ម.(ដីស្រទាប់លើទុកនៅម្ខាងនិងដីស្រទាប់ក្រោមទុកនៅម្ខាងទៀត)
- ច្របល់ដីស្រទាប់លើជាមួយជី NPK ចំនួន ១០០ក្រាម/រណ្តៅ (រូបភាពទី១)



*រូបភាពទី១៖ ការស្តារបាតរណ្តៅ*

- ប្រើកាំបិតមុតកាត់បាតថង់កម្ពស់២ស.ម ពីបាតថង់(ត្រូវជៀសវាងការប៉ះភ្នែកបំបៅ)
- ដាក់កូនកៅស៊ូឲ្យចំកណ្តាលរណ្តៅដោយប្រុងប្រយ័ត្ន និងបែរភ្នែកបំបៅទៅទិសនិរតី (រូបភាពទី២)



*រូបភាពទី២៖ ការកាត់បាតថង់និងដាក់ក្នុងរណ្តៅ*

- ទុកភ្នែកបំបៅកម្ពស់២ស.ម. (ប្រហែល២ធ្នាប់ដៃ) ពីមាត់រណ្តៅ
- ប្រើកាំបិតមុតវះ១/៣ពីបាតថង់ចាប់លាត់ថង់នេះពីក្រោមឡើងនឹងដោយប្រុងប្រយ័ត្នកុំឲ្យបែកដីចេញពីឫសបន្ទាប់មកលុបដីដែលលាយជីរួចដាក់ចូលក្នុងរណ្តៅនោះជាន់ឲ្យហាប់ណែនល្អ
- វះ២/៣ នៃថង់ដែលនៅសល់ចាប់លាត់ថង់ដោយថ្នមៗចេញទាំងស្រុងហើយប្រមូលថង់និងបាតថង់ទុកដើម្បីយកចោល



*រូបភាពទី៣៖ ការកាត់បាតថង់និងវះថង់*

- លុបដីបំពេញរណ្តៅ និងជាន់ឲ្យណែនល្អ កុំឲ្យប៉ះដីក្នុងថង់ និងធ្វើមាត់រណ្តៅជារាងបាតខ្ទះ(រូបភាពទី៤)



*រូបភាពទី៤៖ លុបដីបំពេញរណ្តៅ*

- ដោតតក្បាំងឫស្សីចំងាយប្រមាណ១៥ស.ម ទៅ២០ស.ម.ពីខាងមុខភ្នែកបំបៅ(រូបភាពទី៥)



*រូបភាពទី៥៖ ការដោតក្បាំងឫស្សី*

## ២. ការថែទាំកៅស៊ូមិនទាន់ផ្តល់ផល

### ២.១ ការដាក់ជី

ការដាក់ជីត្រូវចាប់ផ្តើមតាំងពីកូនកៅស៊ូ នៅតូចដើម្បីដុះលូតលាស់បានល្អ លប់ដីលើស្មៅនិងរុក្ខជាតិចង្រៃផ្សេងៗទៀត។ បីឆ្នាំដំបូងនៃការដាំដុះកៅស៊ូ ជាតំណាក់កាលសំខាន់បំផុតដែលត្រូវផ្តល់នូវសារធាតុចិញ្ចឹមឲ្យបានគ្រប់គ្រាន់សម្រាប់ការដុះលូតលាស់របស់ដើមកៅស៊ូ។ បន្ទាប់ពីតំណាក់កាលនេះការដាក់ជីត្រូវមើលតាមរោគសញ្ញានៃកង្វះសារធាតុចិញ្ចឹមរបស់ដើមកៅស៊ូ។

អនុសាសន៍នៃការដាក់ជីកំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានដូចខាងក្រោម៖

| ឆ្នាំដាំ | បរិមាណជី ១៥-១៥-១៥ (ឆ្នាំ/ដើម/ក្រាម) | ចម្ងាយពីគល់កៅស៊ូ (.ម) | បរិមាណជីដាក់ ២ដង/១ឆ្នាំ |
|---|---|---|---|
| ឆ្នាំទី១ (ដាំឆ្នាំ) | ២០០ | ០.៣ | ១០០ក្រ/ដើម ខែកញ្ញា-ខែតុលា |
| ឆ្នាំទី២ | ២០០ | ០.៥ | ១០០ក្រ/ដើម ខែឧសភា- ខែកញ្ញា |
| ឆ្នាំទី៣ | ៣០០ | ១ | ១៥០ក្រ/ដើម ខែឧសភា- ខែកញ្ញា |
| ឆ្នាំទី៤ | ៤០០ | ១.៥ | ២០០ក្រ/ដើម ខែឧសភា- ខែកញ្ញា |
| ឆ្នាំទី៥ | ៥០០ | ៣ | ២៥០ក្រ/ដើម ខែឧសភា- ខែកញ្ញា |

**វិធីសាស្ត្រនៃការដាក់ជី៖**

- កូនកៅស៊ូអាយុ១ឆ្នាំ-២ឆ្នាំ៖ ជីត្រូវដាក់នៅជុំវិញគល់កៅស៊ូចម្ងាយប្រមាណពី០,២ម ទៅ០,៥ម ពីដើមកៅស៊ូ (រូបភាពទី៦)




*រូបភាពទី៦៖ ការដាក់ជីកូនកៅស៊ូអាយុ១ឆ្នាំ- ២ឆ្នាំ*

- កូនកៅស៊ូអាយុ៣ឆ្នាំ៖ ការដាក់ជីត្រូវដាក់ចម្ងាយ១មពីជួរកៅស៊ូដោយឆូតជាចង្អូរតាមចន្លោះរងកៅស៊ូ (រូបភាពទី៧)




*រូបភាពទី៧៖ ការដាក់ជីកូនកៅស៊ូអាយុ៣ឆ្នាំ*

- កូនកៅស៊ូអាយុ៤ឆ្នាំ៖ ការដាក់ជីត្រូវដាក់ចម្ងាយ១,៥មពីជួរកៅស៊ូដោយឆូតជាចង្អូរតាមចន្លោះរងកៅស៊ូ (រូបភាពទី៨)




*រូបភាពទី៨៖ ការដាក់ជីកូនកៅស៊ូអាយុ៤ឆ្នាំ*

- កូនកៅស៊ូអាយុ៥ឆ្នាំ៖ការដាក់ជីត្រូវដាក់ចម្ងាយ៣មពីជួរកៅស៊ូ៩ដោយឆូតជាចង្អូរតាមចន្លោះរងកៅស៊ូ (រូបភាពទី៩)។




*រូបភាពទី៩៖ ការដាក់ជីកូនកៅស៊ូអាយុ៥ឆ្នាំ*

## ២.២ ការដាំជួស

កូនកៅស៊ូ ដែលងាប់ត្រូវដាំជួសឡើងវិញនៅឆ្នាំទី១ឬឆ្នាំទី២បន្ទាប់ពីការដាំដំបូង។ កូនកៅស៊ូដែលល្អសម្រាប់ការដាំជួស គឺកូនស្ទុមដែលមានកម្ពស់ខ្ពស់ ឬកូនក្នុងថង់ដែលមានទំហំ នឹងអាយុប្រហាក់ប្រហែលគ្នាជាមួយកូនកៅស៊ូបានដាំឆ្នាំដំបូង។ បច្ចុប្បន្ននេះ គេនិយមយកកូនកៅស៊ូ១ផ័ត្រ ឬ២ផ័ត្រសម្រាប់ការដាំជួស។

## ២.៣ ការកាត់ខ្នែង

លទ្ធផលនៃការកាត់ខ្នែង គឺទទួលបានដើមត្រង់ល្អមិនបែកមែកនិងស្នាមពកនៅលើសំបកដែលមិនបង្កការលំបាកនៅពេលដើមកៅស៊ូដល់ដំណាក់ការចៀរ។ ការកាត់ខ្នែងដុះតាមដើមត្រូវប្រើកំបិតមុតដើម្បីកាត់ខ្នែងលើដើមកៅស៊ូហើយការកាត់ខ្នែងនេះត្រូវកាត់រហូតដើមកៅស៊ូមានកម្ពស់ពី ២,៥.ម. ទៅ ៣ម (រូបភាពទី១០)។ ការកាត់ខ្នែងត្រូវអនុវត្តដូចខាងក្រោម៖

- រយៈពេល២ខែដំបូងនៃឆ្នាំទី១ ការកាត់ខ្នែងប្រព្រឹត្តពី៨ថ្ងៃ ទៅ ១៥ថ្ងៃម្តង
- រយៈពេលចាប់ពី៣ខែ រហូតដល់ ឆ្នាំទី២ ការកាត់ខ្នែងប្រព្រឹត្តទៅ ១ខែម្តង
- កូនកៅស៊ូមានអាយុ២ឆ្នាំទៅ៣ឆ្នាំការកាត់ខ្នែងប្រព្រឹត្តទៅ២ខែម្តង




*រូបភាពទី១០៖ ការកាត់ខ្នែងនិងមែក*

## ២.៤ ការគ្រប់គ្រងរុក្ខជាតិចង្រៃ

ការកម្ចាត់រុក្ខជាតិចង្រៃក្នុងចម្ការកៅស៊ូអាចគ្រប់គ្រងបានដោយការជម្រះតាមចន្លោះរងនីមួយៗឲ្យបាន១ម.ពីគល់កៅស៊ូទាំងសងខាងនិងការជម្រះជារង្វង់ជុំវិញគល់ឬការប្រើប្រាស់ថ្នាំសម្លាប់រុក្ខជាតិចង្រៃចាប់ពីឆ្នាំទី២ឡើងទៅ។ នៅពេលកៅស៊ូដាំបាន៦ខែដំបូងត្រូវជម្រះស្មៅនឹងត្រូវធ្វើឡើង១៥ថ្ងៃទៅ២០ថ្ងៃម្តង និងត្រូវសម្អាតឲ្យបាន៤ដង-៥ដងក្នុង១ឆ្នាំ។ ចំពោះស្មៅតាមចន្លោះរងកៅស៊ូវិញត្រូវសម្អាតឲ្យបាន២ដង-៣ដងក្នុងរយៈពេល១ឆ្នាំ។ ចំណែកការប្រើថ្នាំសម្លាប់រុក្ខជាតិចង្រៃទាំងអស់គួរប្រើប្រភេទគ្លីផូស្វាត (Gly phophate) លាយជាមួយ ២ដេ៤,2,4D)។ ដែលមានតារាងដូចខាងក្រោម៖

| រុក្ខជាតិចង្រៃ | ប្រភេទថ្នាំសម្លាប់(ក្រ/ហាត) | |
|---|---|---|
| | គ្លីផូស្វាត | ២ដេ៤, |
| ស្បូវ | ២៨០០ | ៧២០ |
| ស្មៅចង្រៃផ្សេងៗ | ១៤៤០ | ៧២០ |

***សំគាល់៖*** *ស្បូវត្រូវច្រូតឲ្យខ្លីត្រឹម៣០ស.ម-៤០ស.មក្នុងករណីស្បូវខ្ពស់ហើយទុកវាចោលពី៤ថ្ងៃ-៥ថ្ងៃទើបបាញ់ថ្នាំ។*

**ចំពោះធុងសម្រាប់បាញ់ដោយដៃចំណុះ១៨លីត្រ៖**

– ចំណុះធុង១៨លីត្រ
– សមត្ថភាពបាញ់ក្នុង១ធុងបាន០.៨ហិកតា
– ១២,៥ធុង បាញ់ក្នុងផ្ទៃដី ១ហិកតា

ជាទូទៅការសម្អាតស្មៅតាមរងកៅស៊ូគួរតប្រើចបនៅក្នុងឆ្នាំដាំនិងឆ្នាំទី១។ ក្នុងករណីចាំបាច់អាចប្រើប្រាស់ថ្នាំកម្ចាត់ស្មៅបានប៉ុន្តែត្រូវគ្របកូនកៅស៊ូឲ្យបានត្រឹមត្រូវ។ ចាប់ពីឆ្នាំទី២ ការប្រើថ្នាំកម្ចាត់ស្មៅតាមរងកៅស៊ូអាចអនុវត្តបានដោយបាញ់រៀងរាល់៤ខែម្តង នៅក្នុងឆ្នាំទី២ និង៦ខែម្តងចាប់ពីឆ្នាំទី៣ឡើងទៅ។

## ២.៥ ការដាំដំណាំចន្លោះរង( Intercrops )

ដំណាំចន្លោះរងបានផ្តល់នូវប្រភពធនធានដូចជាម្ហូបអាហា និងថវិកាសម្រាប់កសិករកៅស៊ូគ្រួសារក្នុងអំឡុងពេលកូនកៅស៊ូមិនទាន់ផ្តល់ផល។

គុណសម្បត្តិនៃដំណាំចន្លោះរងរួមមាន៖

- ការពារការដុះរុក្ខជាតិចង្រៃ
- ធ្វើឲ្យប្រសើរឡើងនូវសារធាតុរបស់ដីព្រោះដំណាំចន្លោះរងខ្លះផ្តល់សារធាតុចិញ្ចឹមឲ្យដីដូចជាពពួកសណ្តែកដែលជួយឲ្យដីមានជីជាតិពិសេសអាសូត
- កាត់បន្ថយការហូរច្រោះដី
- ផ្តល់ការងារនិងប្រាក់ចំណូលបន្ថែមដល់កសិករ។

### ក. ប្រភេទដំណាំចន្លោះរង

ប្រភេទដែលគេនិយមដាំនៅក្នុងចម្ការកៅស៊ូចាប់ពីកៅស៊ូអាយុ១ឆ្នាំ-៣ឆ្នាំ មានដូចជាសណ្តែកដី សណ្តែកបាយ សណ្តែកសៀង ខ្ញី និង ដំណាំប្រចាំរដូវផ្សេងៗទៀត។

ពីដំណាំរដូវទាំងនោះគេក្រៅអាចដាំដំណាំរយៈពេលវែងដូចជាម្នាស់ចេកកាហ្វេ។ ប៉ុន្តែដំណាំរយៈពេលវែងតាមចន្លោះរងកៅស៊ូ អាចអនុវត្តបានតែក្នុងករណីជួរភ្លោះតែប៉ុណ្ណោះ។

### ខ.ដំណាំគម្របដី (Cover crops)

ក្រៅពីដំណាំចន្លោះរងដូចបានរៀបរាប់ខាងលើគេក៏អាចដាំដំណាំគម្របដីនៅចន្លោះរងកៅស៊ូបានដែរ។ ប្រភេទដំណាំគម្របដី ដែលគេធ្លាប់បាន

ដាំកន្លងមកមានដូចជា៖

- ស្ទីលឡូសាំងតែស (*Stylosanthes*)
- មូគូណាប្រាស្តេតា(*Mucunabracteata*)
- ពូអេរារីយ៉ាហ្វាសេអូឡូអ៊ីត (*Pueraria phaseoloides*)
- សង់ត្រូសេម៉ាពូបេះសង់ (*Centrosema pubescens*)
- ប្រាការីយ៉ាប្រីហ្សង់ថា (Brachiaria Brizantha)
- កាឡូប៉ូហ្គូនីយ៉ូមមូស្គូណោយ (*Calopogonium mucunoides*)...។ល។

ដំណាំគម្របដីផ្តល់ផលប្រយោជន៍ជាច្រើន៖

–កាត់បន្ថយការហូរច្រោះដី

–រក្សាសំណើមដី

– ផ្តល់សារធាតុចិញ្ចឹម

– ទប់ស្កាត់ការលូតលាស់រុក្ខជាតិចង្រៃ។



*រូបភាពទី១១៖ ពូអេរារីយ៉ា* (Puerariaphaseoloides)



*រូបភាពទី១២៖ ប្រាស៊ីអារីយ៉ា* (*Brachiariabrizantha*)



*រូបភាពទី១៣៖ ស្ទីលឡូសាំងតែស* (Stylosanthes)



*រូបភាពទី១៤៖ មូគូណា* (Mucunabracteata)

## ២.៦ការធ្វើឲ្យបែកមែក

ក្លូនកៅស៊ូមួយចំនួនមានការបែកមែកយឺត និងដុះលូតទៅលើខ្ពស់គ្មានមែក ដែលជាលទ្ធផលធ្វើឲ្យដើមស្រឡូនឡើងទៅលើដោយសារការពង្រីកទំហំដើមយឺត។ ដើមកៅស៊ូទាំងនោះត្រូវបានជំរុញឲ្យបែកមែកដើម្បីទទួលបានគម្របស្លឹកល្អហើយដើមកៅស៊ូដុះលូតលាស់និងមានទម្រង់ល្អ។

ការជំរុញឲ្យបែកមែកត្រូវធ្វើនៅលើដើមកៅស៊ូដែលមានអាយុយ៉ាងតិច ១៨ខែ ប្រើឧបករណ៍កាត់សំបកជុំវិញដើម។ ឧបករណ៍ត្រូវដាក់នៅលើដើមដែលមានកម្ពស់ ២,៥ម៉ែត្រពីដី រួចបង្វិលមួយជុំដើមដើម្បីអាចកាត់សំបកដល់សាច់ឈើ (រូបភាពទី១៥)។ វិធីនេះអាចធ្វើឲ្យបែកមែកពី៤មែក ៥មែក ក្រៅពីវិធីសាស្រ្តខាងលើគេមានវិធីសាស្រ្តផ្សេងៗទៀតដើម្បីឲ្យដើមកៅស៊ូបែកមែកមានដូចជា៖ ការកាត់តួស្លឹកនៅផ្នែកខាងចុងចេញ និងការក្តោបកំពូលត្រួយស្លឹក។ កំពូលស្លឹកដែលក្តោបនឹងត្រូវស្រាយចេញក្រោយរយៈពេល៣អាទិត្យ- ៤អាទិត្យ បន្ទាប់មកជ្រើសរើសខ្នែងដែលដុះចេញល្អចំនួន៥ យ៉ាងច្រើន ៕



*រូបភាពទី១៥៖ ការធ្វើឲ្យបែកមែក*

## ឯកសារយោង

១.សៀវភៅបច្ចេកទេសកៅស៊ូសម្រាប់កសិករកៅស៊ូគ្រួសារនៅប្រទេសភីលីពីន
(E.A. ALCALA, 2000 manual for rubber smallholder, Philippine)

២.វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា២០០៨ មគ្គុទេសបច្ចេកទេសវិធីដាំកូនកៅស៊ូផ័ត្រ

# និន្នាការតម្លៃនិងស្ថិតិកៅស៊ូធម្មជាតិតាមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ

## តារាងទី១៖ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅតាមបណ្តាស្រុក ប្រចាំសប្តាហ៍ ខែមិថុនា ឆ្នាំ២០១៨

| ល.រ | ខេត្ត | សប្តាហ៍ទី ១ | | | | | | សប្តាហ៍ទី ២ | | | | | | សប្តាហ៍ទី ៣ | | | | | | សប្តាហ៍ទី ៤ | | | | | | តម្លៃមធ្យមខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | ជ័រកក |
| | | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | រ/គ.ក្រ |
| ១ | កំពង់ចាម | 4.600 | 1,13 | → 0 | 2.300 | 0,57 | → 0 | 4.300 | 1,06 | ↓ 300 | 2.100 | 0,52 | ↓ 200 | 4.300 | 1,06 | → 0 | 2.100 | 0,52 | → 0 | 4.200 | 1,03 | ↓ 100 | 2.000 | 0,49 | ↓ 100 | 4.350 | 2125 |
| ២ | ត្បូងឃ្មុំ | 4.600 | 1,13 | ↑ 100 | 2.200 | 0,54 | → 0 | 4.500 | 1,11 | ↓ 100 | 2.000 | 0,49 | ↓ 200 | 4.400 | 1,08 | ↓ 100 | 2.000 | 0,49 | → 0 | 4.200 | 1,03 | ↓ 200 | 1.900 | 0,47 | ↓ 100 | 4.425 | 2025 |
| ៣ | កំពង់ធំ | 4.600 | 1,13 | → 0 | 2.100 | 0,52 | → 0 | 4.600 | 1,13 | → 0 | 2.100 | 0,52 | → 0 | 4.600 | 1,13 | → 0 | 2.100 | 0,52 | → 0 | 4.300 | 1,06 | ↓ 300 | 1.900 | 0,47 | ↓ 200 | 4.525 | 2050 |
| ៤ | រតនគិរី | 4.600 | 1,13 | → 0 | 2.500 | 0,61 | ↑ 100 | 4.500 | 1,11 | ↓ 100 | 2.500 | 0,62 | → 0 | 4.500 | 1,11 | → 0 | 2.400 | 0,59 | ↓ 100 | 4.300 | 1,06 | ↓ 200 | 2.300 | 0,57 | ↓ 100 | 4.475 | 2425 |
| ៥ | ក្រចេះ | 4.500 | 1,11 | → 0 | 2.200 | 0,54 | → 0 | 4.400 | 1,08 | ↓ 100 | 2.000 | 0,49 | ↓ 200 | 4.300 | 1,06 | ↓ 100 | 2.000 | 0,49 | → 0 | 4.200 | 1,03 | ↓ 100 | 2.000 | 0,49 | → 0 | 4.350 | 2050 |
| ៦ | មណ្ឌលគិរី | | | | 2.400 | 0,59 | → 0 | | | | 2.300 | 0,57 | ↓ 100 | | | | 2.200 | 0,54 | ↓ 100 | | | | 2.200 | 0,54 | → 0 | | 2275 |
| តម្លៃមធ្យម | | **4.580** | 1,13 | ↑ 20 | **2.283** | **0,56** | ↑ 17 | **4.460** | **1,10** | ↓ 120 | **2.167** | **0,53** | ↓ 117 | **4.420** | **1,09** | ↓ 40 | **2.133** | **0,53** | ↓ 33 | **4.240** | **1,04** | ↓ 180 | **2.050** | **0,50** | ↓ **83** | 4.425 | 2.158 |
| អត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជា | | | **4.070** | | | | | | **4.062** | | | | | | 4.063 | | | | | | 4.063 | | | | | | |

ចំពោះស្ថានភាពទិញជ័រកៅស៊ូគ្រួសារតាមតំបន់នានា ប្រចាំខែមិថុនាជាមធ្យមមានតម្លៃ ៤ ៤២៥រ/គ.ក្រ (=១,០៩US$/គ.ក្រ) សម្រាប់ជ័រស្ងួត និង ២ ១៥៨រ/គ.ក្រ (=០,៥៣US$/គ.ក្រ) សម្រាប់ជ័រកក។

# តារាងទី២៖ ស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែមិថុនា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

## តារាងស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំឆមាសទី១ ឆ្នាំ២០១៨

តារាងទី២

| ល.រ | ចម្ការកៅស៊ូ | មិថុនា ២០១៧ | | | | | | មិថុនា ២០១៨ | | | | | | ធៀបខែមុន | | | | ធៀបរយៈពេលដូចគ្នានៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ ខែនេះ | | តម្លៃមធ្យម ខែនេះ | | បរិមាណ ខែនេះ | | បរិមាណ ដល់ខែនេះ | | តម្លៃមធ្យម ខែនេះ | | តម្លៃមធ្យម ដល់ខែនេះ | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| I. កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 50 | 200 | 66.000 | 324.500 | 1.320 | 1.623 | 50 | 200 | 62.000 | 254.500 | 1.240 | 1.273 | 0 | 0 | -80 | -6,06 | 0 | 0 | 0 | 0 | -80 | -6,06 | -350 | -21,57 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ិនវេសមេន គ្រុប | 2.077 | 7.468 | 3.063.584 | 13.075.224 | 1.475 | 1.751 | 1.021 | 7.957 | 1.492.685 | 11.679.230 | 1.462 | 1.468 | -974 | -48,82 | 45 | 3,17 | -1.056 | -50,85 | 488 | 6,54 | -13 | -0,86 | -283 | -16,16 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 147 | 525 | 205.170 | 881.790 | 1.396 | 1.680 | 126 | 588 | 176.610 | 829.710 | 1.402 | 1.411 | -42 | -25,00 | 40 | 2,97 | -21 | -14,29 | 63 | 12,00 | 6 | 0,43 | -269 | -15,99 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 378 | 1.734 | 593.712 | 3.135.887 | 1.569 | 1.808 | 242 | 2.038 | 325.195 | 2.992.735 | 1.344 | 1.468 | -177 | -42,25 | -95 | -6,60 | -136 | -36,07 | 304 | 17,55 | -225 | -14,33 | -340 | -18,81 |
| 5 | ក្រុមហ៊ុនស៊ីហ្ស រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 25 | 60 | 28.191 | 93.950 | 1.128 | 1.559 | 0 | 267 | 0 | 343.477 | 0 | 1.285 | 0 | 0 | 0 | 0 | 0 | 0 | 207 | 343,79 | 0 | 0 | -275 | -17,62 |
| 6 | ក្រុមហ៊ុនស៊ីហ្ស រីសសស៍ លីមីធីត(ស្នួល) | 60 | 787 | 84.000 | 1.520.496 | 1.400 | 1.933 | 484 | 2.030 | 646.400 | 2.783.148 | 1.336 | 1.371 | 211 | 77,29 | 16 | 1,24 | 424 | 706,67 | 1.244 | 158,06 | -64 | -4,60 | -562 | -29,07 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ិនធើណេស៊ិនណល | 445 | 1.740 | 621.660 | 3.040.666 | 1.397 | 1.747 | 378 | 1.628 | 539.700 | 2.362.100 | 1.428 | 1.451 | 168 | 80,00 | -7 | -0,50 | -67 | -15,06 | -112 | -6,45 | 31 | 2,20 | -296 | -16,96 |
| 8 | ក្រុមហ៊ុនអានម៉ានី គ្រុប(ចម្ការអណ្តូង) | 290 | 998 | 391.900 | 1.645.060 | 1.351 | 1.648 | 0 | 840 | 0 | 1.098.600 | 0 | 1.308 | 0 | 0 | 0 | 0 | 0 | 0 | -158 | -15,83 | 0 | 0 | -340 | -20,66 |
| 9 | ក្រុមហ៊ុនអានម៉ានី គ្រុប(ពាមជាំង) | 160 | 592 | 210.600 | 971.840 | 1.316 | 1.642 | 0 | 360 | 0 | 467.600 | 0 | 1.299 | 0 | 0 | 0 | 0 | 0 | 0 | -232 | -39,19 | 0 | 0 | -343 | -20,88 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 820 | 2.038 | 1.129.900 | 3.415.120 | 1.378 | 1.676 | 462 | 2.169 | 661.710 | 3.124.020 | 1.432 | 1.440 | 42 | 10,00 | 27 | 1,94 | -358 | -43,66 | 131 | 6,43 | 54 | 3,94 | -235 | -14,05 |
| **សរុប ក** | | **4.452** | **16.143** | **6.394.717** | **28.104.533** | **1.436** | **1.741** | **2.763** | **18.078** | **3.904.300** | **25.935.121** | **1.413** | **1.435** | **-1.071** | **-27,95** | **20** | **1,41** | **-1.690** | **-37,95** | **1.935** | **11,99** | **-23** | **-1,60** | **-306** | **-17,60** |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 2.900 | 14.200 | 4.165.172 | 25.271.148 | 1.436 | 1.780 | 3.780 | 17.841 | 5.342.084 | 25.583.691 | 1.413 | 1.434 | 461 | 13,89 | 20 | 1,41 | 880 | 30,34 | 3.641 | 25,64 | -23 | -1,60 | -346 | -19,42 |
| សរុបI=ក+ខ | | 7.352 | 30.343 | 10.559.888 | 53.375.681 | 1.436 | 1.759 | 6.543 | 35.919 | 9.246.384 | 51.518.811 | 1.413 | 1.434 | -610 | -8,53 | 20 | 1,41 | -810 | -11,01 | 5.576 | 18,38 | -23 | -1,60 | -325 | -18,46 |
| II. កៅស៊ូគ្រួសារ | | 8.100 | 39.700 | 11.633.756 | 70.629.508 | 1.436 | 1.779 | 10.200 | 48.500 | 14.415.146 | 69.565.282 | 1.413 | 1.434 | 1.200 | 13,33 | 20 | 1,41 | 2.100 | 25,93 | 8.800 | 22,17 | -23 | -1,60 | -345 | -19,38 |
| **សរុបI+II** | | **15.452** | **70.043** | **22.193.644** | **124.005.189** | **1.436** | **1.770** | **16.743** | **84.419** | **23.661.530** | **121.084.093** | **1.413** | **1.434** | **590** | **3,65** | **20** | **1,41** | **1.290** | **8,35** | **14.376** | **20,52** | **-23** | **-1,60** | **-336** | **-18,98** |

**បញ្ជាក់៖**

១. ក្នុងខែមិថុនា ឆ្នាំ២០១៨បរិមាណបញ្ចេញលក់សរុបមានចំនួន១៦ ៧៤៣តោន បានកើនឡើង៥៩០តោន (=៣,៦៥%)បើធៀបនឹងខែមុន និងបានកើនឡើង១ ២៩០តោន(=៨,៣៥%)បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។

២. ក្នុងខែមិថុនា ឆ្នាំ២០១៨ តម្លៃលក់មធ្យមគឺ១ ៤១៣ដុល្លារ/តោន បានកើនឡើង២០ដុល្លារ/តោន(=១,៤១%) ធៀបនឹងខែមុន ប៉ុន្តែបានថយចុះ២៣ដុល្លារ/តោន (=-១,៦០%)បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។

៣. ក្នុងឆមាសទី១ ឆ្នាំ២០១៨ បរិមាណបញ្ចេញលក់សរុបមានចំនួន៨៤ ៤១៩តោន បានកើនឡើង១៤ ៣៧៦តោន (=+២០,៥២%)ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៧។

៤. ក្នុងឆមាសទី១ ឆ្នាំ២០១៨ តម្លៃលក់មធ្យមគឺ១ ៤៣៤ដុល្លារ/តោន បានថយចុះ៣៣៦ដុល្លារ/តោន (=-១៨,៩៨%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៨
អ្នកធ្វើតារាង

បានពិនិត្យត្រឹមត្រូវ
ជ.ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

**សេក ឥក្តី**

## តារាងទី៣៖ តម្លៃកៅស៊ូនៅទីផ្សារប្រទេសថៃ ប្រចាំខែមិថុនា ឆ្នាំ២០១៨ (ដុល្លារសហរដ្ឋអាមេរិក/តោន)

| ថ្ងៃ | កៅស៊ូសន្លឹកសំដិលដោយខ្យល់ USS *1* | | | | | | | មធ្យម | សន្លឹកចំហុយ | ជ័រចាន | ទឹកជ័រនៅចម្ការ |
|---|---|---|---|---|---|---|---|---|---|---|---|
| | Hat Yai | Khlong Nga | Trang | Phuket | Surat thani | Rayong | Ubonrat chatani | | | | |
| 1 | 1 524,44 | 1 524,44 | 1 524,44 | 1 491,30 | 1 491,30 | 1 557,58 | 1 557,58 | 1 524,44 | 1 706,71 | 1 275,89 | 1 623,86 |
| 4 | 1 524,44 | 1 524,44 | 1 524,44 | 1 524,44 | 1 524,44 | 1 557,58 | 1 557,58 | 1 534,05 | 1 715,99 | 1 275,89 | 1 657,00 |
| 5 | 1 491,30 | 1 524,44 | 1 491,30 | 1 491,30 | 1 491,30 | 1 557,58 | 1 524,44 | 1 510,19 | 1 692,46 | 1 259,32 | 1 557,58 |
| 6 | 1 491,30 | 1 524,44 | 1 491,30 | 1 524,44 | 1 524,44 | 1 557,58 | 1 557,58 | 1 524,44 | 1 706,71 | 1 275,89 | 1 557,58 |
| 7 | 1 491,30 | 1 491,30 | 1 491,30 | 1 491,30 | 1 524,44 | 1 557,58 | 1 557,58 | 1 514,83 | 1 697,10 | 1 292,46 | 1 491,30 |
| 8 | 1 491,30 | 1 524,44 | 1 458,16 | 1 491,30 | 1 491,30 | 1 524,44 | 1 524,44 | 1 500,91 | 1 672,91 | 1 292,46 | 1 491,30 |
| 11 | 1 524,44 | 1 524,44 | 1 524,44 | 1 491,30 | 1 524,44 | 1 524,44 | 1 524,44 | 1 519,80 | 1 697,10 | 1 259,32 | 1 458,16 |
| 12 | 1 524,44 | 1 524,44 | 1 524,44 | 1 491,30 | 1 524,44 | 1 524,44 | 1 524,44 | 1 519,80 | 1 701,74 | 1 259,32 | 1 491,30 |
| 13 | 1 425,02 | 1 458,16 | 1 458,16 | 1 425,02 | 1 425,02 | 1 491,30 | 1 491,30 | 1 453,52 | 1 654,35 | 1 275,89 | 1 524,44 |
| 14 | 1 425,02 | 1 458,16 | 1 458,16 | 1 425,02 | 1 425,02 | 1 491,30 | 1 491,30 | 1 453,52 | 1 635,46 | 1 259,32 | 1 491,30 |
| 15 | 1 458,16 | 1 491,30 | 1 425,02 | 1 425,02 | 1 425,02 | 1 491,30 | 1 491,30 | 1 458,16 | 1 640,43 | 1 226,18 | 1 458,16 |
| 18 | 1 425,02 | 1 458,16 | 1 458,16 | 1 425,02 | 1 425,02 | 1 491,30 | 1 491,30 | 1 453,52 | 1 226,18 | 1 458,16 | 1 458,16 |
| 19 | 1 391,88 | 1 425,02 | 1 425,02 | 1 391,88 | 1 391,88 | 1 458,16 | 1 491,30 | 1 425,02 | 1 607,29 | 1 193,04 | 1 425,02 |
| 20 | 1 391,88 | 1 425,02 | 1 425,02 | 1 391,88 | 1 391,88 | 1 458,16 | 1 458,16 | 1 420,38 | 1 597,68 | 1 193,04 | 1 458,16 |
| 21 | 1 391,88 | 1 458,16 | 1 391,88 | 1 391,88 | 1 391,88 | 1 491,30 | 1 491,30 | 1 429,66 | 1 597,68 | 1 193,04 | 1 458,16 |
| 22 | 1 391,88 | 1 458,16 | 1 425,02 | 1 425,02 | 1 425,02 | 1 491,30 | 1 491,30 | 1 443,91 | 1 626,18 | 1 209,61 | 1 425,02 |
| 25 | 1 425,02 | 1 458,16 | 1 425,02 | 1 425,02 | 1 425,02 | 1 491,30 | 1 458,16 | 1 443,91 | 1 630,82 | 1 226,18 | 1 491,30 |
| 26 | 1 458,16 | 1 458,16 | 1 425,02 | 1 425,02 | 1 425,02 | 1 491,30 | 1 491,30 | 1 453,52 | 1 635,46 | 1 226,18 | 1 491,30 |
| 27 | 1 425,02 | 1 458,16 | 1 458,16 | 1 425,02 | 1 458,16 | 1 491,30 | 1 491,30 | 1 458,16 | 1 640,43 | 1 226,18 | 1 491,30 |
| 28 | 1 425,02 | 1 425,02 | 1 425,02 | 1 425,02 | 1 425,02 | 1 491,30 | 1 491,30 | 1 443,91 | 1 626,18 | 1 234,47 | 1 458,16 |
| 29 | 1 425,02 | 1 458,16 | 1 425,02 | 1 391,88 | 1 425,02 | 1 458,16 | 1 491,30 | 1 439,27 | 1 621,21 | 1 226,18 | 1 425,02 |
| មធ្យម | *1 453,43* | *1 478,68* | *1 459,74* | *1 447,11* | *1 455,00* | *1 507,08* | *1 507,08* | *1 472,62* | *1 634,76* | *1 254,19* | *1 494,46* |
| អតិបរមា | *1 524,44* | *1 524,44* | *1 524,44* | *1 524,44* | *1 524,44* | *1 557,58* | *1 557,58* | *1 534,05* | *1 715,99* | *1 458,16* | *1 657,00* |
| អប្បរមា | *1 391,88* | *1 425,02* | *1 391,88* | *1 391,88* | *1 391,88* | *1 458,16* | *1 458,16* | *1 420,38* | *1 226,18* | *1 193,04* | *1 425,02* |

កំណត់សំគាល់៖ នេះជាតម្លៃកៅស៊ូក្នុងស្រុកបានមកពីសមាគមន៍កៅស៊ូថៃ ដែលបានអង្កេតយ៉ាងតិច ២-៥សមាជិក/ថ្ងៃ

*1* USS = Un-Smoked Sheets (កៅស៊ូសន្លឹកសំដិលដោយខ្យល់)

## តារាងទី៤៖ តម្លៃកៅស៊ូស្តង់ដារម៉ាឡេស៊ី SMR/FOB ប្រចាំខែមិថុនា ឆ្នាំ២០១៨ (ដុល្លារអាមេរិក/តោន)

| មិថុនា | SMR CV | SMR L | SMR 5 | SMR GP | SMR 10 | SMR 20 |
|---|---|---|---|---|---|---|
| **1** | 1 826,50 | 1 660,50 | 1 455,50 | 1 447,50 | 1 430,00 | 1 424,50 |
| **4** | 1 829,50 | 1 666,00 | 1 479,50 | 1 471,50 | 1 454,00 | 1 448,50 |
| **5** | 1 834,50 | 1 671,00 | 1 457,50 | 1 450,00 | 1 432,00 | 1 426,50 |
| **6** | 1 835,00 | 1 674,00 | 1 458,00 | 1 450,00 | 1 432,00 | 1 427,00 |
| **7** | 1 835,00 | 1 674,00 | 1 459,00 | 1 451,50 | 1 433,50 | 1 428,50 |
| **8** | 1 834,00 | 1 678,00 | 1 449,50 | 1 442,00 | 1 424,00 | 1 419,00 |
| **11** | 1 832,50 | 1 679,50 | 1 445,00 | 1 437,00 | 1 419,50 | 1 414,00 |
| **12** | 1 829,00 | 1 679,00 | 1 445,00 | 1 437,00 | 1 419,50 | 1 414,00 |
| **13** | 1 818,50 | 1 672,00 | 1 411,50 | 1 404,00 | 1 386,00 | 1 381,00 |
| **14** | 1 814,00 | 1 670,50 | 1 402,00 | 1 394,50 | 1 377,00 | 1 371,50 |
| **18** | 1 809,00 | 1 668,00 | 1 398,50 | 1 391,00 | 1 373,00 | 1 368,00 |
| **19** | 1 808,00 | 1 669,50 | 1 362,00 | 1 354,50 | 1 336,50 | 1 331,50 |
| **20** | 1 808,00 | 1 672,00 | 1 377,50 | 1 370,00 | 1 352,00 | 1 347,00 |
| **21** | 1 810,50 | 1 674,50 | 1 369,00 | 1 361,50 | 1 344,00 | 1 338,50 |
| **22** | 1 814,50 | 1 681,50 | 1 381,00 | 1 373,50 | 1 356,00 | 1 350,50 |
| **25** | 1 818,00 | 1 687,50 | 1 388,50 | 1 381,00 | 1 363,00 | 1 358,00 |
| **26** | 1 808,00 | 1 682,00 | 1 382,50 | 1 375,00 | 1 357,50 | 1 352,50 |
| **27** | 1 808,50 | 1 686,00 | 1 383,00 | 1 375,50 | 1 358,00 | 1 353,00 |
| **28** | 1 808,00 | 1 689,50 | 1 419,50 | 1 412,00 | 1 354,50 | 1 389,00 |
| **29** | 1 800,50 | 1 692,00 | 1 390,50 | 1 383,00 | 1 365,50 | 1 360,50 |
| **មធ្យម** | ***1 819,30*** | ***1 167,64*** | ***1 415,70*** | ***1 408,10*** | ***1 390,40*** | ***1 385,20*** |
| **អតិបរមា** | ***1 835,00*** | ***1 692,00*** | ***1 479,50*** | ***1 471,50*** | ***1 454,00*** | ***1 448,50*** |
| **អប្បបរមា** | ***1 805,00*** | ***1 660,50*** | ***1 362,00*** | ***1 354,50*** | ***1 336,50*** | ***1 331,50*** |




- តម្លៃកៅស៊ូស្តង់ដារម៉ាឡេស៊ីលេខ១០ (SVR 10) បានធ្លាក់ចុះដល់ ១ ៣៩០,៤០ដុល្លារអាមេរិក/តោន ក្នុងខែមិថុនា ឆ្នាំ២០១៨ បើធៀបទៅនឹងខែឧសភា ឆ្នាំ២០១៨ ដែលមានតម្លៃ ១ ៤៤៣,២០ដុល្លារអាមេរិក/តោន ដូចនេះសន្ទស្សន៍តម្លៃថយចុះ ១,០៣៦ មានន័យថាតម្លៃកៅស៊ូខែមិថុនា ឆ្នាំ២០១៨ បានធ្លាក់ចុះ ៣,៦%។

SMR = Standard Malaysian Rubber (កៅស៊ូស្តង់ដារម៉ាឡេស៊ី ), FOB = Fee-on-Board (ថ្លៃទំនិញដឹកដល់កប៉ាល់)

## តារាងទី៥៖ តម្លៃកៅស៊ូស្តង់ដារវៀតណាម SVR/FOB ប្រចាំខែមិថុនា ឆ្នាំ២០១៨ (ដុល្លារ/តោន)

| មិថុនា | SVR CV | SVR L | SVR 5 | SVR GP | SVR 10 | SVR 20 |
|---|---|---|---|---|---|---|
| 4 | 1 774,60 | 1 616,00 | 1 435,10 | 1 427,40 | 1 410,40 | 1 405,00 |
| 5 | 1 779,50 | 1 620,90 | 1 413,80 | 1 406,50 | 1 389,00 | 1 383,70 |
| 6 | 1 780,00 | 1 623,80 | 1 414,30 | 1 406,50 | 1 389,00 | 1 384,20 |
| 8 | 1 779,00 | 1 627,70 | 1 406,00 | 1 398,70 | 1 381,30 | 1 376,40 |
| 11 | 1 777,50 | 1 629,10 | 1 401,70 | 1 393,90 | 1 376,90 | 1 371,60 |
| 12 | 1 774,10 | 1 628,60 | 1 401,70 | 1 393,90 | 1 376,90 | 1 371,60 |
| 13 | 1 763,90 | 1 621,80 | 1 369,20 | 1 361,90 | 1 344,40 | 1 339,60 |
| 14 | 1 759,60 | 1 620,40 | 1 359,90 | 1 352,70 | 1 335,70 | 1 330,40 |
| 18 | 1 754,70 | 1 618,00 | 1 356,50 | 1 349,30 | 1 331,80 | 1 327,00 |
| 19 | 1 753,80 | 1 619,40 | 1 321,10 | 1 313,90 | 1 296,40 | 1 291,60 |
| 20 | 1 753,80 | 1 621,80 | 1 336,20 | 1 328,90 | 1 311,40 | 1 306,60 |
| 21 | 1 756,20 | 1 624,30 | 1 327,90 | 1 320,70 | 1 303,70 | 1 298,30 |
| 22 | 1 760,10 | 1 631,10 | 1 339,60 | 1 332,30 | 1 315,30 | 1 310,00 |
| 25 | 1 763,50 | 1 636,90 | 1 346,80 | 1 339,60 | 1 322,10 | 1 317,30 |
| 26 | 1 753,80 | 1 631,50 | 1 341,00 | 1 333,80 | 1 316,80 | 1 311,90 |
| 28 | 1 753,80 | 1 638,80 | 1 376,90 | 1 369,60 | 1 352,70 | 1 347,30 |
| 29 | 1 750,90 | 1 641,20 | 1 348,80 | 1 341,50 | 1 324,50 | 1 319,70 |
| មធ្យម | *1 575,62* | *1 455,33* | *1224,95* | *1 363,00* | *1 198,71* | *1 126,72* |
| អតិបរមា | *1 779,50* | *1 641,20* | *1435,10* | *1 427,40* | *1 410,40* | *1 384,20* |
| អប្បបរមា | *1 779,00* | *1 616,00* | *1341,00* | *1 313,90* | *1 389,00* | *1 310,00* |




- តម្លៃកៅស៊ូស្តង់ដារវៀតណាមលេខ១០ (SVR 10) បានធ្លាក់ចុះដល់ ១ ១៩៨,៧១ ដុល្លារអាម៉េរិក/តោន ក្នុងខែមិថុនា ឆ្នាំ២០១៨ បើធៀបទៅនឹង ខែមេសា ឆ្នាំ២០១៨ ដែលមានតម្លៃ ១ ៣៩៦,៣៥ ដុល្លារអាម៉េរិក/តោន ដូចនេះសន្ទស្សន៍តម្លៃធ្លាក់ចុះ ១,១៤១ មានន័យថាតម្លៃកៅស៊ូ ខែមិថុនា ឆ្នាំ២០១៨ បានធ្លាក់ចុះ ១៤,១%។

SVR = Standard Vietnam Rubber (កៅស៊ូស្តង់ដារវៀតណាម)

FOB = Free-on-Board (ថ្លៃទំនិញដឹកដល់កប៉ាល់)

## តារាងទី៦៖ តម្លៃកៅស៊ូធម្មជាតិចេញដោយ Association of Natural Rubber Producing Countries ប្រចាំខែមិថុនា ឆ្នាំ២០១៨ (ដុល្លារ/តោន)

| មិថុនា | Latex 60% | RSS | | TSR | |
|---|---|---|---|---|---|
| | ម៉ាឡេស៊ី(៤) | បាងកក RSS 3(២) | កូតាយ៉ាម RSS 4(៣) | បាងកក TSR 20(២) | គូឡាឡាំពួរ SMR 20(១) |
| 5 | 1 166,90 | - | 1 886,50 | - | 1 426,50 |
| 6 | 1 138,10 | - | 1 879,50 | - | 1 427,00 |
| 7 | 1 120,50 | - | 1 880,10 | - | 1 428,50 |
| 8 | 1 125,60 | - | 1 866,00 | - | 1 419,00 |
| 11 | 1 131,10 | 1 677,70 | 1 878,70 | 1 443,60 | 1 414,00 |
| 12 | 1 120,20 | - | 1 875,30 | - | 1 414,00 |
| 13 | 1 097,40 | - | 1 870,60 | - | 1 381,00 |
| 14 | 1 371,50 | 1 617,20 | 1 868,90 | 1 415,00 | 1 089,20 |
| 15 | - | - | 1 868,90 | - | - |
| 18 | 1 091,20 | 1 575,50 | 1 852,30 | 1 376,60 | 1 368,00 |
| 19 | 1 106,60 | 1 556,80 | 1 848,80 | 1 365,70 | 1 331,50 |
| 20 | 1 080,50 | 1 555,60 | 1 850,70 | 1 358,50 | 1 347,00 |
| 21 | 1 093,80 | 1 543,10 | 1 847,60 | 1 351,50 | 1 338,50 |
| 22 | 1 086,10 | 1 546,30 | 1 859,20 | 1 357,90 | 1 350,50 |
| 25 | 1 093,20 | 1 544,10 | 1 849,00 | 1 362,10 | 1 358,00 |
| 26 | 1 092,40 | 1 541,70 | 1 855,70 | 1 362,70 | 1 352,50 |
| 27 | 1 099,20 | 1 535,70 | 1 846,10 | 1 363,10 | 1 353,00 |
| 28 | 1 103,70 | 1 543,10 | 1 842,20 | 1 376,70 | 1 389,00 |
| 29 | 1 111,80 | 1 543,70 | 1 859,30 | 1 371,80 | 1 360,50 |
| **មធ្យម** | ***1 123,87*** | ***1 565,04*** | ***1 862,38*** | ***1 3754,3*** | ***1 363,76*** |
| **អតិបរមា** | ***1 371,50*** | ***1 677,70*** | ***1 886,50*** | ***1 443,60*** | ***1 428,50*** |
| **អប្បរមា** | ***1 080,50*** | ***1 535,70*** | ***1 842,20*** | ***1 351,50*** | ***1 089,20*** |

**សំគាល់៖**

(១)ថ្លៃបវន្តផ្ទុកលើនាវាកំណត់ដោយអ្នកទិញនៅល្ងាចម៉ោង៥:០០

(២)ថ្លៃបវន្តផ្ទុកលើនាវាកំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូថៃ

(៣)ថ្លៃជាមធ្យមកំណត់ដោយទីផ្សារតណ្ឌា (ដែលទាក់ទងនឹងថ្លៃទីផ្សារក្នុងស្រុកនិងមិនគិតថ្លៃពន្ធ ឬថ្លៃផ្សេង)

(៤)ថ្លៃកំណត់ដោយអ្នកទិញដែលបានរាយការណ៍ជាផ្លូវការដោយក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី

**ពាក្យកាត់៖**

*1* TSR = Technical Specified Rubber (កៅស៊ូបញ្ជាក់គុណភាពតាមបច្ចេកទេស)

*2* RSS = Ribbed Smoked Sheets (កៅស៊ូសន្លឹកសម្ងួតដោយផ្សែង)

*3* Latex 60% (ទឹកជ័រខាប់៦០%)

*4* SMR = Standard Malaysia Rubber (កៅស៊ូស្តង់ដាប្រទេសម៉ាឡេស៊ី)

*5* STR = Standard Thai Rubber (កៅស៊ូស្តង់ដាប្រទេសថៃ)

## តារាងទី៧៖ តម្លៃកៅស៊ូសន្លឹកលេខ៣ ( RSS3) នៅលើទីផ្សារហ៊ីន TOCOM

(ដុល្លារ/គីឡូក្រាម)

| កាលបរិច្ឆេទនៃការធ្វើពាណិជ្ជកម្ម | កិច្ចសន្យាប្រចាំខែ | | | | | |
|---|---|---|---|---|---|---|
| | មិថុនា ១៨ | កក្កដា ១៨ | សីហា ១៨ | កញ្ញា ១៨ | តុលា ១៨ | វិច្ឆិកា ១៨ |
| ១-មិថុនា-១៨ | 1 588,86 | 1 639,82 | 1 663,48 | 1 692,60 | 1 710,80 | 1 723,54 |
| ៤-មិថុនា-១៨ | 1 575,21 | 1 648,01 | 1 674,40 | 1 694,42 | 1 717,17 | 1 732,64 |
| ៥-មិថុនា-១៨ | 1 547,91 | 1 636,18 | 1 660,75 | 1 675,31 | 1 695,33 | 1 703,52 |
| ៦-មិថុនា-១៨ | 1 558,83 | 1 631,63 | 1 665,30 | 1 685,32 | 1 701,70 | 1 711,71 |
| ៧-មិថុនា-១៨ | 1 573,39 | 1 636,18 | 1 666,21 | 1 692,60 | 1 715,35 | 1 726,27 |
| ៨-មិថុនា-១៨ | 1 561,56 | 1 617,07 | 1 638,00 | 1 663,48 | 1 681,68 | 1 693,51 |
| ១១-មិថុនា-១៨ | 1 557,92 | 1 612,52 | 1 619,80 | 1 653,47 | 1 669,85 | 1 682,59 |
| ១២-មិថុនា-១៨ | 1 568,84 | 1 617,98 | 1 629,81 | 1 658,02 | 1 682,59 | 1 697,15 |
| ១៣-មិថុនា-១៨ | 1 547,91 | 1 569,75 | 1 597,05 | 1 617,07 | 1 638,00 | 1 649,83 |
| ១៤-មិថុនា-១៨ | 1 536,99 | 1 555,19 | 1 573,39 | 1 599,78 | 1 620,71 | 1 633,45 |
| ១៥-មិថុនា-១៨ | 1 515,15 | 1 550,64 | 1 570,66 | 1 572,48 | 1 623,44 | 1 638,00 |
| ១៨-មិថុនា-១៨ | 1 461,46 | 1 523,34 | 1 542,45 | 1 538,81 | 1 597,05 | 1 608,88 |
| ១៩-មិថុនា-១៨ | 1 422,33 | 1 492,40 | 1 512,42 | 1 555,19 | 1 562,47 | 1 580,67 |
| ២០-មិថុនា-១៨ | 1 463,28 | 1 512,42 | 1 533,35 | 1 543,36 | 1 582,49 | 1 601,60 |
| ២១-មិថុនា-១៨ | 1 466,01 | 1 500,59 | 1 528,80 | 1 535,17 | 1 569,75 | 1 585,22 |
| ២២-មិថុនា-១៨ | 1 456,00 | 1 510,60 | 1 521,52 | 1 526,98 | 1 565,20 | 1 577,94 |
| ២៥-មិថុនា-១៨ | 1 486,94 | 1 490,58 | 1 506,96 | 1 554,28 | 1 547,91 | 1 560,65 |
| ២៦-មិថុនា-១៨ | 1 505,14 | 1 514,24 | 1 524,25 | 1 557,92 | 1 560,65 | 1 569,75 |
| ២៧-មិថុនា-១៨ | 1 515,15 | 1 517,88 | 1 531,53 | 1 577,03 | 1 573,39 | 1 581,58 |
| ២៨-មិថុនា-១៨ | 1 526,98 | 1 536,08 | 1 551,55 | 1 589,77 | 1 590,68 | 1 594,32 |
| ២៩-មិថុនា-១៨ | 1 533,35 | 1 546,09 | 1 561,56 | 1 713,53 | 1 600,69 | 1 604,33 |

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែមិថុនា ឆ្នាំ២០១៨*

*អត្រា៖ ១យ៉េន = 0,00៩១ដុល្លារ*

# តារាងទី៨៖ តម្លៃកៅស៊ូសន្លឹកលេខ៣ (RSS3) នៅលើទីផ្សារហ៊ុនសៀងហៃ

(ដុល្លារ/តោន)

| កាលបរិច្ឆេទនៃការធ្វើពាណិជ្ជកម្ម | កិច្ចសន្យាប្រចាំខែ | | | | | |
|---|---|---|---|---|---|---|
| | មិថុនា ១៨ | កក្កដា ១៨ | សីហា ១៨ | កញ្ញា ១៨ | តុលា ១៨ | វិច្ឆិកា ១៨ |
| ១-មិថុនា-១៨ | 1 662,57 | 1 694,18 | 1 698,59 | 1 716,96 | 1 732,40 | 1 741,95 |
| ៤-មិថុនា-១៨ | 1 642,73 | 1 690,50 | 1 697,85 | 1 719,61 | 1 739,75 | 1 746,36 |
| ៥-មិថុនា-១៨ | 1 683,15 | 1 672,13 | 1 686,09 | 1 705,94 | 1 722,11 | 1 730,19 |
| ៦-មិថុនា-១៨ | 1 655,96 | 1 682,42 | 1 691,24 | 1 708,14 | 1 726,52 | 1 733,13 |
| ៧-មិថុនា-១៨ | 1 653,02 | 1 694,18 | 1 703,00 | 1 717,70 | 1 729,46 | 1 742,69 |
| ៨-មិថុនា-១៨ | 1 655,96 | 1 651,55 | 1 698,59 | 1 678,01 | 1 701,53 | 1 703,00 |
| ១១-មិថុនា-១៨ | 1 614,06 | 1 650,81 | 1 656,69 | 1 675,80 | 1 695,65 | 1 700,06 |
| ១២-មិថុនា-១៨ | 1 619,94 | 1 644,93 | 1 653,02 | 1 675,80 | 1 694,91 | 1 697,12 |
| ១៣-មិថុនា-១៨ | 1 618,47 | 1 561,14 | 1 560,41 | 1 592,75 | 1 602,30 | 1 615,53 |
| ១៤-មិថុនា-១៨ | 1 618,47 | 1 558,20 | 1 576,58 | 1 589,07 | 1 605,24 | 1 606,71 |
| ១៥-មិថុនា-១៨ | 1 618,47 | 1 553,79 | 1 563,35 | 1 586,13 | 1 603,77 | 1 608,18 |
| ១៩-មិថុនា-១៨ | - | 1 473,68 | 1 470,00 | 1 497,93 | 1 503,81 | 1 519,25 |
| ២០-មិថុនា-១៨ | - | 1 486,91 | 1 500,14 | 1 521,45 | 1 534,68 | 1 543,50 |
| ២១-មិថុនា-១៨ | - | 1 489,85 | 1 494,99 | 1 519,98 | 1 536,89 | 1 544,24 |
| ២២-មិថុនា-១៨ | - | 1  506,75 | 1 508,96 | 1 540,56 | 1 548,65 | 1 564,08 |
| ២៥-មិថុនា-១៨ | - | 1 499,40 | 1 514,84 | 1 539,09 | 1 552,32 | 1 560,41 |
| ២៦-មិថុនា-១៨ | - | 1 504,55 | 1 519,25 | 1 497,20 | 1 552,32 | 1 565,55 |
| ២៧-មិថុនា-១៨ | - | 1 503,81 | 1 522,19 | 1 542,03 | 1 554,53 | 1 566,29 |
| ២៨-មិថុនា-១៨ | - | 1 510,43 | 1 528,80 | 1 536,89 | 1 550,12 | 1 562,61 |
| ២៩-មិថុនា-១៨ | - | 1 523,66 | 1 530,27 | 1 554,53 | 1 570,70 | 1 578,78 |

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែមិថុនា ឆ្នាំ២០១៨*

*អត្រា៖ ១ យ័ន = ០,១៤៧ដុល្លារ*

# ស្ថានភាពនៃការវិវត្តន៍ទីផ្សារកៅស៊ូធម្មជាតិ

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែមិថុនា ២០១៨*

***ប្រែសម្រួលដោយ លោក គុយ ភក្តី***

តម្លៃកៅស៊ូធម្មជាតិបានបង្ហាញការធ្លាក់ចុះក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ បើធៀបទៅនឹងខែឧសភា ឆ្នាំ២០១៨។ តម្លៃមធ្យមប្រចាំខែរបស់កៅស៊ូធម្មជាតិ នៅក្នុងទីផ្សារកៅស៊ូទិញលក់ភ្លាមៗក្នុងអំឡុងខែឧសភានិងមិថុនា ឆ្នាំ២០១៨ នឹងបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងទី៩៖ តម្លៃកៅស៊ូទិញលក់ភ្លាមៗប្រចាំថ្ងៃគិតជាមធ្យមក្នុងខែ** ($/kg)

| ប្រភេទ | ខែធ្នូ ២០១៧ | មករា ២០១៨ | បម្រែបម្រួល |
|---|---|---|---|
| ទឹកជ័រ (គួឡាឡាំពួរ) | 1,25 | 1,12 | **- 10,4** |
| RSS-3 (បាងកក) | 1,75 | 1,61 | **- 8** |
| RSS-4 (កូត្តយ៉ាម) | 1,84 | 1,87 | **1,6** |
| STR-20 (បាងកក) | 1,45 | 1,40 | **- 3,4** |
| SMR-20 (គួឡាឡាំពួរ) | 1,44 | 1,39 | **- 3,5** |

ចំពោះទីផ្សារកៅស៊ូធំ តម្លៃកៅស៊ូប្រភេទ SMR-20 នៅទីផ្សារគួឡាឡាំពួរ និងតម្លៃកៅស៊ូប្រភេទ STR-20 នៅក្នុងទីផ្សារបាងកក បានធ្លាក់ចុះដូចគ្នាចំនួន ០,០៥ដុល្លារសហរដ្ឋអាមេ៉រិក/គីឡូក្រាម ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ បើធៀបទៅនឹងខែមុន។

ចំពោះទឹកជ័រនៅទីផ្សារគួឡាឡាំពួរ ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ មានតម្លៃជាមធ្យម ១,១២ ដុល្លារសហរដ្ឋអាម៉េរិក/គីឡូក្រាម ធ្លាក់ចុះ ១០,៤% បើធៀបទៅនឹងខែមុនដែលមានតម្លៃទឹកជ័រ ១,២៥ ដុល្លារសហរដ្ឋអាម៉េរិក/គីឡូក្រាម។

ផ្ទុយទៅវិញ មានតែទីផ្សារទិញលក់កៅស៊ូ RSS-4 ភ្លាមៗនៅទីផ្សារកូត្តយ៉ាមតែមួយគត់ បានកើនឡើង ១,៦% ដែលមានតម្លៃ ១,៨៧ដុល្លារសហរដ្ឋអាម៉េរិក/គីឡូក្រាម ចំណែកឯ កៅស៊ូប្រភេទ RSS-3 ក៏បានធ្លាក់ចុះ ០,១៤ដុល្លារសហរដ្ឋអាម៉េរិក/គីឡូក្រាម ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ។

## ១. ឥទ្ធិពលនៃតម្លៃទិញលក់កៅស៊ូតាមកិច្ចសន្យានៅទីផ្សារហ៊ុនសៀងហៃ នៅលើតម្លៃទិញលក់កៅស៊ូ SMR-20 ភ្លាមៗ

តម្លៃទិញលក់កៅស៊ូ SMR-20 ភ្លាមៗនៅទីផ្សារគួរឡាឡាំពួរបានបង្ហាញពីនិន្នាការក្នុងតម្លៃទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនសៀងហៃចាប់ពីខែមករារហូតដល់ខែមិថុនា ឆ្នាំ២០១៨ ដូចដែលមាននៅតារាងខាងក្រោម។ ចលនាតម្លៃនៃទីផ្សារទិញលក់ភ្លាមៗ (SMR-20 នៅទីផ្សារគួឬឡាឡាំពួរ) មានទិសដៅបន្តបន្ទាប់ភាគច្រើនដូចនឹងទិសដៅតម្លៃកិច្ចសន្យាពាណិជ្ជកម្មរបស់កៅស៊ូ RSS-3 នៅក្នុងទីផ្សារហ៊ុនសៀងហៃ។

**ក្រាហ្វិទី១៖ ឥទ្ធិពលនៃតម្លៃទិញលក់កៅស៊ូតាមកិច្ចសន្យានៅទីផ្សារហ៊ុនសៀងហៃ នៅលើតម្លៃទិញលក់កៅស៊ូ SMR-20 ភ្លាមៗ**




## ២. ឥទ្ធិពលនៃតម្លៃប្រេងឆៅទៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារសៀងហៃ

តម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនសៀងហៃ បានបង្ហាញពីនិន្នាការដូចគ្នាទៅនឹងនិន្នាការប្រេងឆៅ ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ។ ក្រាហ្វិកទី២នេះនឹងបង្ហាញពី តម្លៃទិញលក់កៅស៊ូតាមកិច្ចសន្យានៅទីផ្សារហ៊ុនសៀងហៃបានធ្លាកចុះនៅពាក់កណ្តាលខែមិថុនា ឆ្នាំ២០១៨។ សេណារីយ៉ូនៃការធ្លាក់ចុះនេះ មានទំនាក់ទំនងយ៉ាងជិតស្និតនឹងការលក់ដ៏ធំនៃមូលនិធិការដោះដូរទំនិញពាណិជ្ជកម្មនៅក្នុងទីផ្សារហ៊ុនសៀងហៃ និងការធ្លាក់ចុះយ៉ាងខ្លាំងនៃតម្លៃប្រេងឆៅរបស់ក្រុមហ៊ុន Brent ។ ជាងនេះទៅទៀត ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក ដែលបណ្តាលមកពីភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មពិភពលោករវាងប្រទេសចិននិងសហរដ្ឋអាម៉េរិក និងក្តីបារម្ភនៃការកើនឡើងសន្និធិប្រចាំសប្តាហ៍ដែលបានដាក់សម្ពាធទៅលើទីផ្សារកៅស៊ូធម្មជាតិ។

## ក្រាហ្វិកទី២៖ ឥទ្ធិពលនៃតម្លៃប្រេងនៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យា នៅទីផ្សារសៀងហៃ




### ៣. ឥទ្ធិពលនៃតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូ នៅលើតម្លៃកៅស៊ូ SMR-20 នៅលើទីផ្សារទិញលក់ភ្លាមៗ

ទោះបីជាតម្លៃកៅស៊ូ RSS-3 ទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូមិនទទួលរងឥទ្ធិពលពីភាពចុះខ្សោយនៃប្រាក់យ៉េនជប៉ុនក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ។ តម្លៃកៅទិញលក់ភ្លាមៗនិងតាមកិច្ចសន្យា តម្លៃទាំង២ បានបង្ហាញពីនិន្នាការប្រហាក់ប្រហែលគ្នាក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ។ ក្រាហ្វិកទី៣ នឹងបង្ហាញពី ការប្រៀបធៀបពីនិន្នាការនៃតម្លៃកៅស៊ូ SMR-20 នៅទីផ្សារគួរឡាឡាំពួរ និងតម្លៃកៅស៊ូ RSS-3 ទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូ។

## ក្រាហ្វិកទី៣៖ ឥទ្ធិពលនៃតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូ នៅលើតម្លៃកៅស៊ូ SMR-20 នៅលើទីផ្សារទិញលក់ភ្លាមៗ



## ៤. ឥទ្ធិពលប្រាក់យ៉េនទៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យា នៅទីផ្សារហ៊ុនតូក្យូ

ការចុះខ្សោយនៃប្រាក់យ៉េនជប៉ុនក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨នេះ មិនមានឥទ្ធិពលលើតម្លៃកៅស៊ូ RSS-3 ទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូ។ ទោះបីយ៉ាងណាក៏ដោយ ការប្រើប្រាស់ប្រាក់យ៉េនជប៉ុនដើម្បីកំណត់អចនទ្រព្យក៏នៅតែមានការចាប់អារម្មណ៍ខ្លាំងចំពោះវិនិយោគិនបរទេស។ និន្នាការតម្លៃកៅស៊ូ RSS-3 ទិញលក់តាមកិច្ចសន្យា ដែលកំពុងធ្វើពាណិជ្ជកម្មជាមួយប្រាក់យ៉េនជាបន្តបន្ទាប់នៅក្នុងទីផ្សាហ៊ុនតូក្យូ។

### ក្រាហ្វិកទី៤៖ ឥទ្ធិពលប្រាក់យ៉េនទៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យា នៅទីផ្សារហ៊ុនតូក្យូ

